

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

សារណាបញ្ចប់ការសិក្សា

នីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា **ចិន ពិសី**

កញ្ញា **ង៉ោ វ៉ានីលីហ្សា**

ណែនាំដោយ

លោក **ហេង ម៉ូរ៉ា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤



សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

សារណាបញ្ចប់ការសិក្សា

នីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា **ឯន ពិសី**

កញ្ញា **ង៉ោ អ៉ានីលីហ្សា**

ណែនាំដោយ

លោក **ហេង ម៉ូរ៉ា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ឥន ពិសី** និងឈ្មោះ **ង៉ោ អ៉ានីលីហ្សា** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី២៤ ឆ្នាំសិក្សា២០២០-២០២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

សូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ៖

លោកឪពុក និងអ្នកម្តាយ ដែលជាអ្នកផ្តល់កំណើតព្រមទាំងការចិញ្ចឹមបីបាច់ថែរក្សាអប់រំ ផ្គត់ផ្គង់ទំនុកបម្រុង ទូន្មានប្រៀនប្រដៅប្រកបទៅដោយព្រហ្មវិហារធម៌ តាំងពីតូចដល់រហូតធំពេញវ័យ ទាំងកម្លាំងកាយកម្លាំងចិត្តមិនគិតពីភាពនឿយហត់លំបាកនោះទេ និងការឧបត្ថម្ភគ្រប់បែបយ៉ាង ដើម្បីឱ្យរូបយើងខ្ញុំមានឱកាស ព្រមទាំងពេលវេលាគ្រប់គ្រាន់ក្នុងការសិក្សារៀនសូត្រ និងអភិវឌ្ឍន៍សមត្ថភាពរបស់កូន តាំងពីដើមរហូតបានបញ្ចប់ការសិក្សាដោយភាពជោគជ័យ និងមានអនាគតល្អ។

សូមគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនដល់ ៖

ឯកឧត្តម សាកលវិទ្យាធិការ ព្រមទាំងលោក លោកស្រីសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀនដល់រូបយើងខ្ញុំនូវគ្រប់មុខវិជ្ជាដ៏មានតម្លៃ ដែលធ្វើឱ្យយើងខ្ញុំបានទទួលបានចំណេះដឹងដ៏ខ្ពង់ខ្ពស់រហូតដល់បានបញ្ចប់ការសិក្សាប្រកបដោយភាពជោគជ័យ ដើម្បីទុកជាទៀនសម្រាប់អុចបំភ្លឺផ្លូវនៃដំណើរជីវិតទៅថ្ងៃអនាគត។

ជាពិសេស យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ លោកគ្រូ **ហេង ម៉ូរ៉ា** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ និងកម្លាំងកាយចិត្ត ដើម្បីធ្វើការណែនាំ បង្ហាត់បង្ហាញ ផ្តល់យោបល់ និងផ្តល់នូវវិធីសាស្ត្រល្អៗក្នុងការសរសេរសារណាព្រមទាំងជួយកែលម្អរាល់ចំណុចខ្វះខាតទាំងឡាយ ដែលជាប្រយោជន៍ដល់ការសរសេរសារណារបស់យើងខ្ញុំឱ្យបានល្អប្រសើរហូតបានចងក្រងចេញជាសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រប្រកបដោយជោគជ័យ។

សូមអរគុណដល់លោកតា លោកយាយ បងប្អូន ព្រមទាំងសិស្សច្បង និងមិត្តភក្តិទាំងអស់ដែលបានផ្តល់ទាំងកម្លាំងកាយ កម្លាំងចិត្ត និងជួយផ្តល់មតិយោបល់ល្អៗដល់រូបយើងខ្ញុំក្នុងការសិក្សាពេលកន្លងមក។

ជាទីបញ្ចប់យើងខ្ញុំ សូមប្រសិទ្ធិពរជ័យជូនចំពោះ លោកឪពុក អ្នកម្តាយ ឯកឧត្តម លោក ជំទាវ លោក-លោកស្រី សាស្ត្រាចារ្យទាំងអស់ សូមឱ្យជួបប្រទះតែនឹងសេចក្តីសុខ សេចក្តីចម្រើន ជាពិសេសសូមឱ្យទទួលបានជោគជ័យគ្រប់ភារកិច្ចការងារ និងសូមឱ្យជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

អារម្ភកថា

បន្ទាប់ពីឆ្លងកាត់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រអស់រយៈពេលបួនឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំទទួលបាននូវចំណេះដឹងជាច្រើនពីសំណាក់ លោក លោកស្រី សាស្ត្រាចារ្យដែលបានខិតខំបង្រៀនយ៉ាងយកចិត្តទុកដាក់ ចាប់តាំងពីឆ្នាំមូលដ្ឋានរហូតដល់ឆ្នាំចុងក្រោយ។ តាមរយៈការសិក្សាកន្លងមកនេះ យើងខ្ញុំបានសម្រេចចិត្តជ្រើសរើសប្រធានបទមួយស្តីពី **«នីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ»** ដែលជាផ្នែកមួយនៃមុខវិជ្ជានីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ ដើម្បីធ្វើជាសារណាបញ្ចប់ការសិក្សា និងដើម្បីទុកតម្កល់ជាស្នាដៃមួយសម្រាប់ឱ្យមិត្តនិស្សិត អ្នកស្រាវជ្រាវ និងសាធារណៈជនគ្រប់មជ្ឈដ្ឋាន ក្នុងការសិក្សាស្រាវជ្រាវបន្ថែម ដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួនបន្ថែមទៀត។

លើសពីនេះទៅទៀត ក្នុងការសរសេរសារណានូវប្រធានបទនេះ យើងខ្ញុំមានគោលបំណងចង់បង្ហាញអំពីនីតិវិធីមួយក្នុងចំណោមនីតិវិធីដែលមាននៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី និងជាពិសេសជានីតិវិធីមួយដែលសិស្សនិស្សិតជំនាន់ក្រោយគួរតែយល់ដឹង ដើម្បីជាផលប្រយោជន៍ នៅពេលដែលជួបប្រទះភាពជាក់ស្តែងនូវបញ្ហានេះ និងដោះស្រាយវិវាទដែលកើតមានក្នុងកាលៈទេសៈ ឬ ស្ថានភាពមួយដែលបារម្ភថានឹងមានការខូចខាត ឬ ខូចប្រយោជន៍អ្វីមួយនាពេលអនាគតដែលមិនអាចអនុវត្តបានជាដើម។ ម្យ៉ាងវិញទៀត ក្នុងការបកស្រាយប្រធានបទមួយនេះ យើងខ្ញុំបានបកស្រាយដោយផ្អែកតាមមាត្រាច្បាប់ និងបទដ្ឋានគតិយុត្តនានា ព្រមទាំងភ្ជាប់ជាមួយឧទាហរណ៍យកមកបញ្ជាក់ចំពោះការបកស្រាយរបស់យើងខ្ញុំឱ្យកាន់តែមានភាពស៊ីជម្រៅនិងក្បោះក្បាយបន្ថែមទៀត។ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថាការបកស្រាយ និងចងក្រងនូវសារណាមួយនេះ ដែលជាស្នាដៃមួយរបស់យើងខ្ញុំ អាចជាជំនួយដល់មិត្តនិស្សិតជំនាន់ក្រោយ មិត្តអ្នកអាន និងអ្នកស្រាវជ្រាវនានា ក្នុងការយល់ដឹងបន្ថែមពីការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុនេះ ទោះបីជាក្នុងកម្រិតណាមួយក៏ដោយ។

យ៉ាងណាមិញ យើងខ្ញុំបានខិតខំប្រឹងប្រែងចងក្រងអត្ថបទនេះឡើង យ៉ាងអស់ពីសមត្ថភាពរបស់យើងខ្ញុំដូច្នេះ ក្នុងករណីដែលមានកំហុសដោយចេតនា ឬ អចេតនាណាមួយបានកើតមានឡើង ដូចជាការប្រើពាក្យពេចន៍មានភាពខុសឆ្គង ឃ្លោងឃ្លា និងប្រយោគណាមួយដែលមានចន្លោះខ្វះខាត សូមមិត្តនិស្សិតជំនាន់ក្រោយ មិត្តអ្នកអានធ្វើការកែលម្អ ដោយចូលរួមជាមតិស្ថាបនា និងកែតម្រូវនូវចំណុចខុសឆ្គងនោះ ដើម្បីទុកជាមេរៀនក្នុងការសិក្សាបន្តទៅមុខទៀត។

ជាពិសេស យើងខ្ញុំសង្ឃឹមថានឹងទទួលបានការយោគយល់អធ្យាស្រ័យពីសំណាក់ លោក លោកស្រី សាស្ត្រាចារ្យ សិស្សនិស្សិត មិត្តអ្នកអានដោយក្តីអនុគ្រោះ និងក្តីសោមនស្សរីករាយ ដើម្បីឱ្យសារណារបស់យើងខ្ញុំទាំងពីរកាន់តែមានភាពប្រសើរឡើងមួយកម្រិតទៀត។

មាតិកា

ទំព័រ

សេចក្តីផ្តើម ១

១. លំនាំបញ្ហានៃការស្រាវជ្រាវ ១

២. ចំណោទបញ្ហានៃការដោះស្រាយ ២

៣. គោលបំណងនៃការស្រាវជ្រាវ ២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ២

៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ២

៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ៣

ជំពូកទី១

សញ្ញាណទូទៅនៃការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ

ផ្នែកទី១ គោលបំណងនីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ ៤

ផ្នែកទី២ រចនាសម្ព័ន្ធនីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្ន ៤

២.១ ដំណាក់កាលនៅក្នុងនីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្ន ៤

២.២ លក្ខណៈពិសេសនៃការរឹបអូសជាបណ្តោះអាសន្ន ៥

២.២.១ លក្ខណៈបណ្តោះអាសន្ន ៥

២.២.២ លក្ខណៈបន្ទាន់បង្គំ ៦

២.២.៣ លក្ខណៈបន្ទាប់បន្សំ ៦

២.២.៤ លក្ខណៈសម្ងាត់ ៧

២.៣ កម្មវត្ថុ និងភាគីការរឹបអូសជាបណ្តោះអាសន្ន ៨

២.៣.១ កម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន ៨

២.៣.២ ភាគីនៃការរឹបអូសជាបណ្តោះអាសន្ន ១១

ផ្នែកទី៣ លក្ខខ័ណ្ឌនៃការរឹបអូសជាបណ្តោះអាសន្ន ១២

៣.១ លក្ខខ័ណ្ឌលើសិទ្ធិដែលត្រូវបានរក្សាការពារ ១២

៣.២ ភាពចាំបាច់នៃការរក្សាការពារ ១៣

ជំពូកទី២
នីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ

ផ្នែកទី១ នីតិវិធីក្នុងការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ... ១៥

១.១ សមត្ថកិច្ចតុលាការ ... ១៥

១.១.១ តុលាការនៃបណ្តឹងអង្គសេចក្តី ... ១៥

១.១.២ តុលាការនៃវត្ថុដែលត្រូវជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន ... ១៦

១.២ ការដាក់ពាក្យសុំ ... ១៦

១.២.១ អត្តសញ្ញាណគូភាគី និងអ្នកតំណាង ... ១៧

១.២.២ ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ ... ១៧

១.២.៣ សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ ... ១៧

១.២.៤ ភាពចាំបាច់នៃការរក្សាការពារ ... ១៨

១.៣ ឯកសារដែលត្រូវភ្ជាប់ជាមួយ ... ១៩

១.៣.១ ឯកសារសម្រាប់ធ្វើសេចក្តីបញ្ជាក់ដំបូង ... ១៩

១.៣.២ ឯកសារសម្រាប់បញ្ជាក់អំពីសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិ ... ២១

១.៣.៣ ឯកសារសម្រាប់បញ្ជាក់កម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន ... ២២

១.៣.៤ ឯកសារបញ្ជាក់ផ្សេងៗ ... ២២

១.៤ សោហ៊ុយ ... ២២

១.៤.១ ពន្ធដាក់ពាក្យសុំ ... ២២

១.៤.២ ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ ... ២៣

១.៤.៣ បន្ទុកនៃប្រាក់ប្រដាប់ក្តី ... ២៣

១.៥ ការពិនិត្យទៅលើពាក្យសុំដីកាសម្រេច ... ២៣

១.៦ ប្រាតិភោគ និងប្រាក់រំដោះ ... ២៤

១.៦.១ ប្រាតិភោគ ... ២៤

១.៦.២ ការដាក់ប្រាក់រំដោះ ... ២៧

១.៧ នីតិវិធីនៃការពិនិត្យរឿងក្តី និងការទាញហេតុផលដោយផ្ទាល់មាត់ ... ២៩

១.៧.១ នីតិវិធីនៃការពិនិត្យរឿងក្តី ... ២៩

១.៧.២ នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ... ៣០

១.៨ ការចេញ និងការបញ្ជូនដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ ៣១
១.៨.១ ការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ ៣១
១.៨.២ ការបញ្ជូនដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ ៣១
ផ្នែកទី២ នីតិវិធីនៃការអនុវត្តការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ ៣៥
២.១ ស្ថាប័នមានសមត្ថកិច្ច ៣៥
២.២ ការដាក់ពាក្យសុំអនុវត្ត ៣៥
២.២.១ ចំណុចដែលត្រូវសរសេរក្នុងពាក្យសុំអនុវត្តដីកាសម្រេច ៣៥
២.២.២ ឯកសារដែលត្រូវភ្ជាប់ជាមួយពាក្យសុំដីកាសម្រេច ៣៦
២.៣ ការពិនិត្យពាក្យសុំ និងល័ក្ខខ័ណ្ឌចាំបាច់ ៣៧
២.៣.១ ការពិនិត្យពាក្យសុំ ៣៧
២.៣.២ ការពិនិត្យលើល័ក្ខខ័ណ្ឌចាំបាច់ ៣៧
២.៤ របៀបនៃការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ៣៨
២.៥ ការផ្អាក និងការលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ៤0
២.៦ ការបំលែងពីការរឹបអូសជាបណ្តោះអាសន្នទៅជាការអនុវត្តដោយបង្ខំ ៤១
២.៧ ការលុបចោលប្រាតិភោគ ៤១
ផ្នែកទី៣ បណ្តឹងឧទ្ធរណ៍ចំពោះការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ ៤២
៣.១ ការតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ៤២
៣.១.១ ការដាក់ពាក្យតវ៉ា និង ល័ក្ខខ័ណ្ឌនៃពាក្យសុំតវ៉ា ៤៣
៣.១.២ ការវិនិច្ឆ័យអំពីពាក្យសុំតវ៉ា ៤៤
៣.១.៣ ដីកាសម្រេចអំពីពាក្យតវ៉ាចំពោះដីកាសម្រេច ៤៤
៣.២ ការលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ៤៦
៣.២.១ ការលុបចោលដោយការមិនដាក់ពាក្យបណ្តឹងអង្គសេចក្តី ៤៦
៣.២.២ ការលុបចោលដោយការផ្លាស់ប្តូរស្ថានភាព ៤៧
៣.២.៣ ការលុបចោលដោយការអស់សុពលភាពនៃដីកាសម្រេច ៤៨
៣.៣ បណ្តឹងជំទាស់ ៤៨
៣.៣.១ អត្ថន័យនៃបណ្តឹងជំទាស់ ៤៩
៣.៣.២ នីតិវិធី និង អំឡុងពេលនៃបណ្តឹងជំទាស់ ៤៩
៣.៣.៣ ការធ្វើបណ្តឹងជំទាស់ ៥0

៣.៣.៤ នីតិវិធីជំនុំជម្រះនៃបណ្តឹងជំទាស់ ៥០
៣.៣.៥ ការបញ្ចប់ការវិនិច្ឆ័យចំពោះបណ្តឹងជំទាស់ ៥១
៣.៣.៦ ការសម្រេចសេចក្តី ៥១

ជំពូកទី៣
បញ្ហាប្រឈម និងដំណោះស្រាយ

ផ្នែកទី១ បញ្ហាប្រឈម ៥៣
១.១ ភាពខ្វះចន្លោះនៃច្បាប់ ៥៣
១.២ កង្វះការយល់ដឹងផ្នែកច្បាប់របស់ប្រជាពលរដ្ឋ ៥៤
១.៣ ការយល់ដឹងរបស់មន្ត្រីអនុវត្តរឹបអូសជាបណ្តោះអាសន្ននៅមានកម្រិត ៥៤
១.៤ ភាពលំបាកក្នុងការស្វែងរកចលនវត្ថុរបស់កូនបំណុល ៥៥
១.៥ វប្បធម៌អន្តរាគមន៍ពីសំណាក់អ្នកមានអំណាច ៥៦
១.៦ ការចំណាយច្រើនលើបន្ទុកសោហ៊ុយរបស់ម្ចាស់បំណុល ៥៧
ផ្នែកទី២ ដំណោះស្រាយ ៥៧
២.១ ការបង្កើតលិខិតបទដ្ឋានគតិយុត្តបន្ថែម ៥៧
២.២ ការផ្សព្វផ្សាយច្បាប់ជាសាធារណៈ ៥៨
២.៣ ការបណ្តុះបណ្តាលមន្ត្រីអនុវត្តរឹបអូសជាបណ្តោះអាសន្ន ៥៩
២.៤ ការបង្កើតយន្តការក្នុងការស្វែងរកចលនវត្ថុរបស់កូនបំណុល ៥៩
២.៥ លុបបំបាត់វប្បធម៌អន្តរាគមន៍ពីសំណាក់អ្នកមានអំណាច ៦០
២.៦ ការបង្កើនយន្តការក្នុងការកាត់បន្ថយបន្ទុកសោហ៊ុយចំណាយរបស់ម្ចាស់បំណុល ៦០
សេចក្តីសន្និដ្ឋាន ៦២
អនុសាសន៍ ៦៣
គន្ថនិទ្ទេស
ឧបសម្ព័ន្ធ

សេចក្តីផ្តើម

សេចក្តីផ្តើម

១. ចំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងកិច្ចការជំនួញ តែងតែមានការជួញដូរ និងការធ្វើពាណិជ្ជកម្មដែលពាក់ព័ន្ធជាមួយនឹងទំនាក់ទំនងរវាងបុគ្គល និងនីតិបុគ្គល តាមរយៈសកម្មភាពគតិយុត្តដូចជា កិច្ចសន្យាលក់ទិញ, ប្រទានកម្ម, ភតិសន្យា និងកិច្ចសន្យាខ្ចីបរិភោគ ជាដើម ដែលអាចនាំឱ្យមានវិវាទកើតឡើងប៉ះពាល់ដល់ផលប្រយោជន៍ភាគី ដោយហេតុថាភាគីម្ខាងទៀតមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន។ សកម្មភាពគតិយុត្តទាំងនោះនាំឱ្យមានការកកើតសិទ្ធិ និងកាតព្វកិច្ចដែលភាគីម្ខាងហៅថា ម្ចាស់បំណុលដែលមានសិទ្ធិចំពោះកូនបំណុល និងភាគីម្ខាងទៀតហៅថា កូនបំណុលដែលមានកាតព្វកិច្ចចំពោះម្ចាស់បំណុល។

ទំនាក់ទំនងរបស់ម្ចាស់បំណុល និងកូនបំណុលមានភាពស្មុគស្មាញជាខ្លាំង នៅពេលដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ច ឧទាហរណ៍នៅក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានគោលបំណងឱ្យសងប្រាក់ ហើយម្ចាស់បំណុលមានការបារម្ភចំពោះការមិនអនុវត្តកាតព្វកិច្ចរបស់កូនបំណុលក្នុងការសងប្រាក់ ហើយមានការលំបាកក្នុងការអនុវត្តដោយបង្ខំនៅពេលអនាគត។ ម្ចាស់បំណុលអាចទៅពឹងពាក់តុលាការ ដើម្បីចេញដីកាសម្រេចរក្សាការពារ ដើម្បីទប់ស្កាត់ការប្រែប្រួលស្ថានភាពនៃទ្រព្យសម្បត្តិរបស់កូនបំណុល ដែលជាទូទៅគេហៅថា ការរក្សាការពារ។ ការរក្សាការពារបែងចែកជាពីរគឺ ការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ដែលជាប្រធានបទត្រូវលើកយកបង្ហាញ និងការចាត់ចែងរក្សាការពារចំពោះសិទ្ធិលើបំណុលដែលគ្មានគោលបំណងឱ្យសងជាប្រាក់។

ការចាត់ចែងរក្សាការពារ ជាវិធានការមួយដែលមានលក្ខណៈបន្ទាន់បង្ខំ ហើយត្រូវបានធ្វើឡើងដោយ មានលក្ខណៈសម្ងាត់ មុនពេលចេញដីកាសម្រេចរក្សាការពារនេះ ហើយជាយន្តការការពារជាបឋមចំពោះផលប្រយោជន៍របស់ម្ចាស់បំណុល។ ការចាត់ចែងរក្សាការពារអាចត្រូវបានចេញមុននីតិវិធីអង្គសេចក្តីក៏បាន ឬ ក្នុងអំឡុងពេលនីតិវិធីអង្គសេចក្តីក៏បាន។ ការចាត់ចែងរក្សាការពារ ត្រូវបានបែងចែងជា ៣ (បី) ប្រភេទរួមមាន ការរឹបអូសជាបណ្តោះអាសន្ន ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ និងការចាត់ចែងបណ្តោះអាសន្នដែលកំណត់ហានៈជាបណ្តោះអាសន្ន។ ប៉ុន្តែនៅក្នុងអត្ថបទសារណានេះ នឹងជ្រើសរើសយកតែ **"ការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ"** មកសិក្សាស្រាវជ្រាវតែប៉ុណ្ណោះ។ ទន្ទឹមនឹងនេះ អត្ថបទសារណានេះនឹងឆ្លើយតបចំពោះបញ្ហាប្រឈមមួយចំនួន ដែលត្រូវជួបប្រទះនៅក្នុងពេលអនុវត្តការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ និងដំណោះស្រាយផ្សេងៗ ដើម្បីជៀសវាងពីការបាត់បង់ផលប្រយោជន៍ស្របច្បាប់របស់ម្ចាស់បំណុលដោយសារបញ្ហាទាំងអស់នោះ។

២. ចំណោទបញ្ហានៃការដោះស្រាយ

ដើម្បីឆ្លើយតបទៅនឹងប្រធានបទ "នីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ" ខាងលើអត្ថបទសារណានេះ នឹងបង្ហាញអំពីចម្លើយគតិយុត្តដែលពាក់ព័ន្ធនឹងសំណួរគតិយុត្តដូចតទៅ៖ តើនីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុមានអត្ថន័យយ៉ាងដូចម្តេច? ដើម្បីធ្វើការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុបាន តើម្ចាស់បំណុលត្រូវគោរពតាមល័ក្ខខ័ណ្ឌនីតិវិធីអ្វីខ្លះ? តើនីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុមានបញ្ហាប្រឈម និងដំណោះស្រាយដូចម្តេចខ្លះ?

៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវអត្ថបទសារណានេះ គឺដើម្បីសិក្សាស្វែងយល់ឱ្យកាន់តែស៊ីជម្រៅពីនីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុទាំងផ្នែកទ្រឹស្តី និងការអនុវត្តជាក់ស្តែង។ ដោយហេតុថាក្នុងការអនុវត្តជាក់ស្តែង នៅក្នុងនីតិវិធីនៃការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុអាចកើតមានឡើងនូវបញ្ហាប្រឈមផ្សេងៗ ដូចជា នីតិវិធីមានភាពយឺតយ៉ាវ និងស្មុគស្មាញដែលខុសពីគោលគំនិតនៃការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុដែលត្រូវធ្វើឡើងដោយបន្ទាន់បង្គំ ក្នុងគោលបំណងការពារផលប្រយោជន៍ជូនម្ចាស់បំណុល។ ដូច្នេះ ការចងក្រងអត្ថបទសារណានេះឡើង ដើម្បីជួយឱ្យសិស្ស និស្សិត មិត្តអ្នកអានគ្រប់ជាន់ថ្នាក់ទាំងអស់ទុកសម្រាប់ជាមូលដ្ឋាន ក្នុងការសិក្សាស្រាវជ្រាវទាក់ទង នឹងប្រធានបទនេះឱ្យបានទូលំទូលាយ។

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការចាត់ចែងរក្សាការពារមាន ០៣ (បី) ប្រភេទ ហើយនីតិវិធីត្រូវបានបែងចែកដាច់ដោយឡែកពីគ្នា ប៉ុន្តែអត្ថបទសារណាមួយនេះ បានជ្រើសរើសនូវប្រធានបទដែលទាក់ទងទៅនឹង «នីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ» មកសិក្សាស្រាវជ្រាវដោយហេតុថា ការរឹបអូសជាបណ្តោះអាសន្នអាចធ្វើឡើង ចំពោះកម្មវត្ថុជាច្រើន។ ដូច្នេះ ប្រធានបទនេះ ត្រូវបានសិក្សាតែចំពោះករណីការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៤។ ម្យ៉ាងវិញទៀត ប្រធានបទសារណានេះ គឺផ្តោតសំខាន់លើទ្រឹស្តីច្បាប់ដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦ រហូតមកដល់បច្ចុប្បន្ននេះ សេចក្តីពន្យល់អំពីនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧ និងឯកសារពាក់ព័ន្ធផ្សេងៗទៀត ហើយចំពោះដែនកំណត់នៃការបកស្រាយ គឺកម្រិតក្នុងការអនុវត្តនៃការរឹបអូសជាបណ្តោះអាសន្ន និងបណ្តឹងឧបាស្រ័យចំពោះដីកាសម្រេចត្រឹមសាលាដំបូងប៉ុណ្ណោះ ។

៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

អត្ថបទសារណានេះ ជាសមិទ្ធផលដែលកើតចេញពីការខិតខំប្រឹងប្រែងព្យាយាមអស់ពីលទ្ធភាពក្នុងការរៀបរៀង និងសម្រិតសម្រាំងយ៉ាងយកចិត្តទុកដាក់បំផុត ដើម្បីទុកជាប្រភពឯកសារសម្រាប់ឱ្យសិស្ស និស្សិត

ជំនាន់ក្រោយអាចទទួលបានចំណេះដឹងបន្ថែមទាក់ទងទៅនឹងការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ។ មួយវិញទៀត សារៈសំខាន់នៃអត្ថបទសារណានេះ មានគោលបំណងបង្ហាញខ្លឹមសារក្នុងអត្ថបទ ដែលប្រាកដជាអាចឱ្យសិស្សនិស្សិតជំនាន់ក្រោយអាចយកទៅប្រើប្រាស់ ក្នុងករណីដើម្បីដោះស្រាយនូវបញ្ហាផ្សេងៗដែលកើតឡើងក្នុងជីវភាពជាក់ស្តែងនាពេលបច្ចុប្បន្ន។

៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទសារណានេះ ត្រូវបានធ្វើការសិក្សាស្រាវជ្រាវយ៉ាងលម្អិតនូវខ្លឹមសារដោយដកស្រង់ចេញពីក្នុងប្រភពជាច្រើន។ ប្រភពចម្បងដែលត្រូវបានដកស្រង់មកសិក្សាស្រាវជ្រាវភាគច្រើន គឺផ្អែកតាមក្រមនីតិវិធីរដ្ឋប្បវេណីដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខនស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ក្នុងគន្លឹទី៧។ ក្រមនីតិវិធីរដ្ឋប្បវេណី ជាកម្រងនៃច្បាប់ទម្រង់ដែលជាមូលដ្ឋានសម្រាប់ឱ្យយើងអាចយកទៅអនុវត្ត តាមរយៈនីតិវិធីបណ្តឹងក្នុងវិវាទរដ្ឋប្បវេណីស្របតាមបរិបទនៃសង្គមជាក់ស្តែង។ មួយវិញទៀត អត្ថបទសារណានេះក៏បានសិក្សាស្រាវជ្រាវទៅលើប្រភពផ្សេងទៀតរួមមាន ដូចជា សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី និងសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណីផងដែរ។ ក្រៅពីប្រភពខាងលើអត្ថបទសារណានេះ ក៏បានប្រមូលព័ត៌មានទិន្នន័យផ្សេងទៀតមកសិក្សាស្រាវជ្រាវរួមមាន អ្នកដែលបំពេញមុខងារក្នុងវិជ្ជាជីវៈច្បាប់ និងសេចក្តីសម្រេចរបស់តុលាការជាដើម។ លើសពីនេះទៅទៀត យើងខ្ញុំក៏បានបញ្ចូលនូវបញ្ហាប្រឈមមួយចំនួនកើតចេញពីការវិភាគទ្រឹស្តី និងការអនុវត្តជាក់ស្តែងដោយផ្តោតទៅលើការវិភាគបញ្ហាប្រឈម និងដំណោះស្រាយចូលទៅក្នុងសារណានេះ ដោយយកចិត្តទុកដាក់ជាទីបំផុត។

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវលើប្រធានបទសារណានេះ ត្រូវបានចែកចេញជា ០៣ (បី) ជំពូក ដូចខាងក្រោម៖

- **ជំពូកទី១ សញ្ញាណទូទៅនៃការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ។**
- **ជំពូកទី២ នីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ។**
- **ជំពូកទី៣ បញ្ហាប្រឈម និងដំណោះស្រាយ។**

ជំពូកទី១

សញ្ញាណទូទៅនៃការរៀបរៀបចំជាបណ្តោះអាសន្នលើចលនវត្ថុ

ជំពូកទី១

សញ្ញាណទូទៅនៃការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ

ផ្នែកទី១ គោលបំណងនីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ

ការចាត់ចែងរក្សាការពារ គឺជានីតិវិធីដែលមានគោលបំណងការពារ និងថែរក្សាស្ថានភាពបច្ចុប្បន្នដោយប្រើអំណាចរបស់រដ្ឋ ដើម្បីការពារសិទ្ធិរបស់បុគ្គលណាម្នាក់ នៅពេលដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត ឬ នៅពេលដែលមានការបារម្ភថានឹងមានការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដល់ហានៈរបស់ភាគីណាមួយ ដោយសារមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិ។[1]

ជាការពិតណាស់ ការចាប់ផ្តើមការអនុវត្តដោយបង្ខំ គឺតម្រូវឱ្យបំពេញល័ក្ខខ័ណ្ឌដូចជាអត្ថិភាពនៃលិខិតអនុវត្ត និងការមកដល់នៃពេលវេលាកំណត់នៃការសងជាអាទិ៍ ក៏ប៉ុន្តែ ទោះបីជាការអនុវត្តដោយបង្ខំ មិនអាចចាប់ផ្តើមបានបើខ្វះល័ក្ខខ័ណ្ឌណាមួយក៏ដោយ ក៏ត្រូវតែទប់ស្កាត់ជាមុន មិនឱ្យមានការប្រែប្រួលផ្លូវច្បាប់ និងស្ថានភាពជាក់ស្តែងផងដែរ ក្នុងករណីដែលការសម្រេចសិទ្ធិទាមទារដោយការអនុវត្តដោយបង្ខំទំនងជាមិនអាចធ្វើទៅបាន ឬ ទំនងជាមានការលំបាកយ៉ាងខ្លាំង នៅពេលដែលគ្រប់ល័ក្ខខ័ណ្ឌទាំងអស់សម្រាប់ការអនុវត្តត្រូវបានបំពេញនាពេលអនាគត ប្រសិនបើកូនបំណុលត្រូវបានអនុញ្ញាតឱ្យធ្វើសកម្មភាពដោយសេរីនោះ។

នៅក្នុងការចាត់ចែងរក្សាការពារមាន ការរឹបអូសជាបណ្តោះអាសន្ន និងការចាត់ចែងជាបណ្តោះអាសន្ន។ ប៉ុន្តែនៅក្នុងប្រធានបទសារណានេះ គឺសិក្សាតែលើការរឹបអូសជាបណ្តោះអាសន្នតែប៉ុណ្ណោះ។ ការរឹបអូសជាបណ្តោះអាសន្ន ត្រូវធ្វើឡើងក្នុងករណីសិទ្ធិដែលត្រូវរក្សាការពារ គឺជាសិទ្ធិទាមទារឱ្យសងជាប្រាក់។ ទន្ទឹមនឹងនេះ ការរឹបអូសជាបណ្តោះអាសន្ន គឺជាការកម្រិតនូវការចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុលសម្រាប់ការអនុវត្តដោយបង្ខំនាពេលអនាគត។

ផ្នែកទី២ រចនាសម្ព័ន្ធនីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្ន

២.១ ដំណាក់កាលនៅក្នុងនីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្ន

ជាទូទៅ នីតិវិធីចាត់ចែងរក្សាការពារមានចរិតលក្ខណៈ ជានីតិវិធីដែលបំពេញបន្ថែមទៅលើការអនុវត្តដោយបង្ខំដែលនៅក្នុងនោះមានការបែងចែកជា២(ពីរ) ដំណាក់កាលដូចជា នីតិវិធីនៃការសម្រេចសេចក្តីដែលវិនិច្ឆ័យទៅលើភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ និងនីតិវិធីនៃការអនុវត្តដែល

[1]ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២, ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០, ទំព័រ១៩៤។

សម្រេចដោយបង្ខំ នូវខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលបានចេញដោយដីកាសម្រេចនេះ មកធ្វើជាលិខិតអនុវត្ត។

ដំណាក់កាលទីមួយ អាចហៅថាការសម្រេចរក្សាការពារ ឯដំណាក់កាលទីពីរ អាចហៅថា ការអនុវត្តរក្សាការពារ។ ការបែងចែកនេះមានលក្ខណៈដូចគ្នានឹងការបែងចែករវាងនីតិវិធីបណ្តឹង និងនីតិវិធីនៃការអនុវត្តដោយបង្ខំដែរ។ ក៏ប៉ុន្តែគោលបំណងនៃដីកាសម្រេចរក្សាការពារ អាចសម្រេចបានលុះត្រាតែមានការអនុវត្តដោយបង្ខំ។ ហេតុនេះហើយទំនាក់ទំនងរវាងការសម្រេចរក្សាការពារនិងការអនុវត្តរក្សាការពារមានលក្ខណៈជិតស្និទ្ធជាងទំនាក់ទំនងរវាងនីតិវិធីបណ្តឹង និងនីតិវិធីនៃការអនុវត្តដោយបង្ខំ។[2]

២.២ លក្ខណៈពិសេសនៃការរឹបអូសជាបណ្តោះអាសន្ន

ការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ ជាវិធានការមួយដែលមានលក្ខណៈបន្ទាន់បង្ខំ ហើយត្រូវបានធ្វើឡើងដោយមានលក្ខណៈសម្ងាត់ មុនពេលចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននេះហើយជាយន្តការការពារជាបឋមចំពោះផលប្រយោជន៍របស់ម្ចាស់បំណុល។ ការចាត់ចែងរក្សាការពារ អាចត្រូវបានចេញមុននីតិវិធីនៃបណ្តឹងអង្គសេចក្តីក៏បាន ឬ ក្នុងអំឡុងពេលនីតិវិធីនៃបណ្តឹងអង្គសេចក្តីក៏បាន។ ដូច្នេះ លក្ខណៈពិសេសនៃការរឹបអូសបណ្តោះអាសន្នលើចលនវត្ថុរួមមាន (២.១) លក្ខណៈបណ្តោះអាសន្ន (២.២) លក្ខណៈបន្ទាន់បង្ខំ (២.៣) លក្ខណៈបន្ទាប់បន្សំ និង (២.៤) លក្ខណៈសម្ងាត់ ដែលចរិតលក្ខណៈពិសេសទាំងអស់នេះត្រូវបានដកស្រង់ចេញពីក្រមនីតិវិធីរដ្ឋប្បវេណី។[3]

២.២.១ លក្ខណៈបណ្តោះអាសន្ន

វិធានរក្សាការពារ មានលក្ខណៈបណ្តោះអាសន្នពុំមានឥទ្ធិពលលើសេចក្តីសម្រេចនៃបណ្តឹងអង្គសេចក្តីឡើយ ទោះបីជាតុលាការបានចេញដីកាសម្រេចរក្សាការពារតាមការស្នើសុំរបស់ម្ចាស់បំណុលក៏ដោយ ក៏ពុំមានន័យថា តុលាការត្រូវទទួលស្គាល់ការទាមទាររបស់ដើមចោទ ក្នុងបណ្តឹងអង្គសេចក្តីនោះដែលដោយផ្អែកតាមមាត្រា៥៣១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ ជានីតិវិធីមួយដែលធ្វើឡើងដោយបណ្តោះអាសន្ន បានន័យថា ដីកាសម្រេចរក្សាការពារពុំមានឥទ្ធិពលទៅលើសេចក្តីសម្រេច ដោយសាលក្រមក្នុងបណ្តឹងអង្គសេចក្តីឡើយ ឬ ធ្វើឱ្យសេចក្តីសម្រេចប្រែប្រួលទេ។ ទោះបីដីកាសម្រេចរក្សាការពារដែលបានចេញដោយតុលាការក៏

[2]ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២, ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០, ទំព័រ១៩៤។

[3] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៥១ មាត្រា៥៥៧ មាត្រា៥៦២។

ដោយ ក៏សិទ្ធិលើបំណុល ឬ សិទ្ធិទាមទារផ្សេងៗទៀតរបស់បណ្តឹងអង្គសេចក្តីមិនត្រូវបានបញ្ជាក់ថាមានអត្ថិភាព ឬ នត្ថិភាពឡើយ។

២.២.២ លក្ខណៈបន្ទាន់បង្គំ

ការចាត់ចែងរក្សាការពារមានលក្ខណៈ "បន្ទាន់បង្គំ" គឺត្រូវអនុវត្តឱ្យបានលឿនជាងមុន ពេលកូនបំណុលចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុល ហេតុនេះការអនុវត្តរក្សាការពារអាចធ្វើទៅបានមុនពេលដីកាសម្រេចរក្សាការពារត្រូវបានបញ្ជូនទៅកូនបំណុលដោយ ផ្អែកតាមមាត្រា ៥៦២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ វិធានរក្សាការពារមានលក្ខណៈប្រញាប់ ដើម្បីការពារផលប្រយោជន៍ស្របច្បាប់ ឬ បង្ការកុំឱ្យមានការខូចខាតធ្ងន់ធ្ងរកើតមានឡើងចំពោះម្ចាស់បំណុលតាមរយៈការទទួលស្គាល់សិទ្ធិរបស់ម្ចាស់បំណុល នៅពេលមានការស្នើសុំដោយមិនចាំបាច់ធ្វើការសាកសួរកូនបំណុលនោះទេ គ្រាន់តែពិនិត្យសេចក្តីបញ្ជាក់ដំបូងជាការគ្រប់គ្រាន់។

នីតិវិធីនៃការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន គឺជាការប្រញាប់ដើម្បីការពារផលប្រយោជន៍ស្របច្បាប់ ឬ ការពារការខូចខាតដែលរំពឹងថានឹងកើតឡើងនាពេលឆាប់ៗខាងមុខជាក់ជាមិនខាន ដូច្នេះចៅក្រមមានឆន្ទានុសិទ្ធិជ្រើសរើសយកនីតិវិធីណាមួយក៏បាន ប៉ុន្តែនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ចៅក្រមកម្រនឹងធ្វើណាស់ ព្រោះពេលខ្លះធ្វើឱ្យខូចខាតដល់កម្មវត្ថុដែលត្រូវរក្សាការពារ ដែលបង្កឡើងដោយកូនបំណុល ចៅក្រមច្រើនជ្រើសរើសយកនីតិវិធីការសាកសួរម្ចាស់បំណុល គឺមានលក្ខណៈល្អជាងគ្រាន់តែពិនិត្យភស្តុតាងជាឯកសារ ឬ ឱ្យភាគីធ្វើសេចក្តីបញ្ជាក់ដំបូងល្មមៗបានហើយ។ សេចក្តីបញ្ជាក់ដំបូងត្រូវធ្វើដោយផ្អែកទៅលើភស្តុតាងដែលអាចឱ្យគេពិនិត្យបានភ្លាមៗ។ បន្ទាប់ពីធ្វើសេចក្តីបញ្ជាក់ដំបូងដែលនាំឱ្យចេញរក្សាការពារ ហើយដីកាសម្រេចនេះត្រូវទុករយៈពេលនៃការអនុវត្តក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ចាប់ពីថ្ងៃដែលចាប់បញ្ជូនទៅម្ចាស់បំណុល បើម្ចាស់បំណុលមិនសុំអនុវត្តទេនោះដីកាសម្រេចត្រូវអស់អានុភាព ប៉ុន្តែពេលអនុវត្តដីកាសម្រេចនេះមិនចាំបាច់មានរូបមន្តអនុវត្ត។ ម្យ៉ាងទៀតដើម្បីឱ្យបានលឿននិងបន្ទាន់ផងច្បាប់បានតម្រូវទៅលើសមត្ថកិច្ចផ្តាច់មុខបាននិយាយថា ភាគីមិនអាចផ្លាស់ប្តូរសមត្ថកិច្ចដោយការព្រមព្រៀងឡើយ។

២.២.៣ លក្ខណៈបន្ទាប់បន្សំ

វិធានរក្សាការពារមានលក្ខណៈរណបឱ្យបណ្តឹងអង្គសេចក្តី មានខ្លឹមសារថា តុលាការបង្គាប់ឱ្យម្ចាស់បំណុលដាក់បណ្តឹងអង្គសេចក្តីក្នុងអំឡុងពេលសមរម្យ ប្រសិនបើមានការស្នើសុំរបស់កូនបំណុល។ ក្នុងករណីនេះប្រសិនបើម្ចាស់បំណុលមិនដាក់ពាក្យបណ្តឹងលើអង្គសេចក្តីក្នុងអំឡុងពេលកំណត់ តុលាការត្រូវលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុនោះ តាមការស្នើសុំរបស់កូនបំណុល។ ផ្អែកតាមមាត្រា ៥៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ការចាត់ចែងរក្សាការពារមានលក្ខណៈ "បន្ទាប់បន្សំ" ពីព្រោះក្នុងករណីម្ចាស់បំណុលមិនដាក់ពាក្យបណ្តឹងអង្គសេចក្តីតាមពាក្យសុំរបស់កូនបំណុល ក្នុងអំឡុងពេលដែលច្បាប់បានកំណត់

ទេនឹងក្លាយជាមូលហេតុនៃការលុបចោលដីកាសម្រេចរក្សាការពារដែលបានចេញពីមុន។ មួយវិញទៀត វិធានរក្សាការពារស្តីពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវការពារ គឺមានលក្ខណៈដូចគ្នានឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារក្នុងបណ្តឹងអង្គសេចក្តី មានន័យថាប្រសិនបើគ្មានសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ តុលាការនឹងមិនចេញដីកាសម្រេចរក្សាការពារតាមការស្នើសុំរបស់ម្ចាស់បំណុលនោះទេ ឬ ក្នុងករណីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ ត្រូវបានរលត់នាពេលក្រោយ ដោយមូលហេតុកាតព្វកិច្ចរបស់កូនបំណុល ឬ ម្ចាស់បំណុលចាញ់បណ្តឹងអង្គសេចក្តី សេចក្តីសម្រេចនៃបណ្តឹងអង្គសេចក្តីបានចូលជាស្ថាពរ ជាមូលហេតុដែលតុលាការអាចលុបចោលដីកាសម្រេចរក្សាការពារនោះវិញបានតាមពាក្យសុំរបស់កូនបំណុល។

នីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ គឺជានីតិវិធីបន្ទាប់បន្សំដើម្បីធ្វើបណ្តឹងអង្គសេចក្តីនៅក្នុងចំណុចមួយចំនួន។ ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ ជានីតិវិធីមួយដែលធ្វើឡើងបណ្តោះអាសន្នវាពុំមានឥទ្ធិពលទៅលើបណ្តឹងអង្គសេចក្តីទៅតុលាការដែលមានសមត្ថកិច្ចនោះការរក្សាការពារត្រូវតែសុំទៅតុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តីនោះដែរ។ ដូច្នេះ រឿងក្តីនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការ ដែលមានសមត្ថកិច្ចលើអង្គសចក្តី ឬ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុនឹងត្រូវរឹបអូសជាបណ្តោះអាសន្ន ឬ វត្ថុដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅ។[4]

ឧទាហរណ៍៖ ការរឹបអូសជាបណ្តោះអាសន្នទៅលើរថយន្តមួយគ្រឿងរបស់កូនបំណុល គឺត្រូវបានធ្វើឡើងដើម្បីធានាការសងសិទ្ធិលើបំណុលដល់ម្ចាស់បំណុល។ ប្រសិនបើកូនបំណុលបានយកប្រាក់ដែលជំពាក់ទៅសងដល់ម្ចាស់បំណុលតាមការទាមទារនោះសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តរវាងកូនបំណុល និងម្ចាស់បំណុលនឹងត្រូវបានរលត់។ ដូច្នេះ មិនត្រឹមតែតុលាការដែលបានចេញដីកាសម្រេចរក្សាការពារប៉ុណ្ណោះទេ ដែលអាចលុបចោលដីកាសម្រេចរក្សាការពារនេះបាន គឺថែមទាំងតុលាការដែលវិនិច្ឆ័យលើបណ្តឹងអង្គសេចក្តី អាចលុបចោលដីកាសម្រេចរក្សាការពារនោះវិញបានទៅតាមពាក្យសុំរបស់ភាគី (មាត្រា៥៥៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

២.២.៤ លក្ខណៈសម្ងាត់

វិធានរក្សាការពារត្រូវបានបង្កើតឡើង ក្នុងគោលបំណងការពារផលប្រយោជន៍ស្របច្បាប់របស់ម្ចាស់បំណុល ដោយមិនឱ្យកូនបំណុលបានដឹងខ្លួនជាមុន តាមរយៈការអនុវត្តដីកាសម្រេចរក្សាការពាររួចរាល់ ទើបជូនដំណឹងទៅកូនបំណុលជាក្រោយ ពីព្រោះប្រសិនបើកូនបំណុលបានដឹងជាមុននោះ ការអនុវត្តដីកា

[4] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤០ កថាខណ្ឌទី១។

សម្រេចរក្សាការពារអាចនឹងមិនទទួលបានជោគជ័យទេ។ ហេតុនេះ ដើម្បីបញ្ចៀសនូវហានិភ័យបែបនេះ តុលាការត្រូវអនុវត្តនីតិវិធីរក្សាការពារដោយសម្ងាត់។ ករណីនេះប្រសិនបើកូនបំណុលយល់ថាប៉ះពាល់ផលប្រយោជន៍ស្របច្បាប់របស់ខ្លួនអាចធ្វើការតវ៉ាបាន ហើយប្រសិនបើតុលាការទទួលស្គាល់ការតវ៉ារបស់កូនបំណុល តុលាការនឹងលុបចោល ឬ ផ្លាស់ប្តូរសេចក្តីសម្រេចដើម។

ម្ចាស់បំណុល ឬ អ្នកដាក់ពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ តែងតែបារម្ភថា នៅពេលដែលតុលាការកំណត់សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តជាស្ថាពរហើយ ខ្លួនមិនអាចអនុវត្តនូវកិច្ចការទាំងនោះបានទេ ហើយម្ចាស់បំណុលតែងតែស្នើសុំមកតុលាការឱ្យចាត់ចែងការរក្សាការពារ ប៉ុន្តែពេលខ្លះតុលាការតម្រូវឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ ដើម្បីកុំឱ្យប្រើសិទ្ធិនេះហួសហេតុពេក រីឯកូនបំណុលវិញ កាលបើខ្លួនដឹងថាចាញ់ក្តី ពេលនោះខ្លួនក៏បានលួចចាត់ចែងទ្រព្យនោះទៅឱ្យអ្នកដទៃផ្សេងទៀត ក្នុងគោលបំណងគេចវេសមិនទទួលខុសត្រូវ។ ភាពសម្ងាត់នេះ គឺរក្សាផលប្រយោជន៍ឱ្យម្ចាស់បំណុល ឬ អ្នកដាក់ពាក្យសុំ ដែលនីតិវិធីនេះធ្វើឱ្យបាត់បង់គោលការណ៍ចំពោះមុខ ប៉ុន្តែដោយសារមានលក្ខណៈសម្ងាត់បែបនេះហើយ ទើបច្បាប់តម្រូវឱ្យម្ចាស់បំណុល ដែលជាអ្នកដាក់ពាក្យសុំយកដីកាសម្រេចនេះ ទៅអនុវត្តមុនការបញ្ជូនទៅដល់កូនបំណុលបានទៀតផង។ [5] ម្យ៉ាងវិញទៀតចៅក្រមអាចជ្រើសរើសយកនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ដូចជា ការពិនិត្យភស្តុតាង និងការសាកសួរភាគីបានដែរ ប៉ុន្តែនីតិវិធីនេះអាចធ្វើជាសាធារណៈ ដូច្នេះអាចមានហានិភ័យកើតឡើងដោយកូនបំណុល ឬ តតិយជនផ្សេងទៀតធ្វើឱ្យខូចប្រយោជន៍របស់ម្ចាស់បំណុល។ ដើម្បីចៀសវាងនូវហានិភ័យនេះតុលាការត្រូវធ្វើនីតិវិធីរក្សាការពារជាសម្ងាត់ ដូច្នេះតុលាការអាចជ្រើសរើសនីតិវិធីនៃការពិនិត្យឯកសារ ឬ សាកសួរម្ចាស់បំណុលដើម្បីចេញដីកាសម្រេច។ [6] ប្រសិនបើកូនបំណុលយល់ឃើញថា ការចាត់ចែងរក្សាការពាររឹបអូសជាបណ្តោះអាសន្ននេះប៉ះពាល់ផលប្រយោជន៍របស់ខ្លួនដោយមិនសមរម្យ ទើបរបបចាត់ចែងរក្សាការពារនេះអាចអនុញ្ញាតឱ្យកូនបំណុលមានសិទ្ធិប្តឹងតវ៉ាបាន ហើយតុលាការក៏ពិចារណាពីបណ្តឹងតវ៉ានេះ ដែលនាំឱ្យតុលាការទទួលស្គាល់ផ្លាស់ប្តូរ ឬ លុបចោលការចាត់ចែងរក្សាការពារនេះបានតែម្តង។

២.៣ កម្មវត្ថុ និងភាគីការរឹបអូសជាបណ្តោះអាសន្ន

២.៣.១ កម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន

កម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ននៅក្នុងប្រធានបទសារណានេះ គឺសំដៅទៅលើចលនវត្ថុដែលពាក់ព័ន្ធជាមួយ (ម៉ូតូ រថយន្ត សម្ភារៈ និងកុងធនាគារ)។

[5] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៦២ កថាខណ្ឌទី៣។

[6] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា១១៤ កថាខណ្ឌទី២។

យោងតាមក្រមរដ្ឋប្បវេណី ចលនវត្ថុ សំដៅលើទៅលើវត្ថុក្រៅពីអចលនវត្ថុ។[7] ក្នុងន័យទូទៅ ចលនវត្ថុជាវត្ថុដែលអាចរំកិល ឬ ផ្លាស់ប្តូរទីតាំងបានមានដូចជា: តុ ទូរ កៅអី ទោចក្រយានយន្ត ត្រីចក្រយានយន្ត...។ ចំពោះវត្ថុដែលគ្មានរូបរាង ហើយអាចប្រើគ្រប់គ្រងបានក៏ត្រូវបានចាត់ទុកជាចលនវត្ថុផងដែរ។[8] ឧទាហរណ៍: ចរន្តអគ្គីសនីឧស្ម័នហ្គាស...។

ជាគោលការណ៍ ការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ គឺត្រូវធ្វើតែចំពោះចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុលតែប៉ុណ្ណោះ។ ប៉ុន្តែកម្មសិទ្ធិនៃចលនវត្ថុមានការលំបាក និងដឹងណាស់តាមការមើលពីក្រៅម្យ៉ាងទៀតចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្តនោះ ភាគច្រើនជាកម្មសិទ្ធិរបស់កូនបំណុលនោះ ហេតុនេះហើយបានជាចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលអាចត្រូវរឹបអូសបានទាំងអស់។ ចំពោះករណីដែលអ្នកផ្សេងក្រៅពីកូនបំណុលនៃការអនុវត្តមានកម្មសិទ្ធិលើចលនវត្ថុដែលរឹបអូសនោះ ម្ចាស់កម្មសិទ្ធិត្រូវប្តឹងតវ៉ាក្នុងហាន:ជាតិយជនដើម្បីការពារវត្ថុរបស់ខ្លួន។[9]

ចំណែកឯចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូសត្រូវបានកំណត់ដូចខាងក្រោម:

ក- ប្រដាប់ស្លៀកពាក់ ប្រដាប់សម្រាប់ដំណេក តុ ទូ ប្រដាប់សម្រាប់ដាំស្ល និងប្រដាប់សម្រាប់បិទឃាំងបន្ទប់របស់កូនបំណុលនៃការអនុវត្ត និងញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នា។

ខ- គ្រឿងបរិភោគ និងទហានវត្ថុ ដែលត្រូវការចាំបាច់ដើម្បីចិញ្ចឹមជីវិតក្នុងអំឡុងពេល ២ (ពីរ) ខែ របស់កូនបំណុលនៃការអនុវត្ត និងញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នា។

គ- របបឧបត្ថម្ភជីវភាព របបឧបត្ថម្ភផ្នែកអប់រំ របបឧបត្ថម្ភសុខភាព និងប្រាក់ ឬ វត្ថុឧបត្ថម្ភផ្សេងទៀតដែល ផ្តល់ពីរដ្ឋ ឬ ពីអាជ្ញាធរដែនដី ដើម្បីការពារដល់ជីវភាពរបស់កូនបំណុលនៃការអនុវត្ត។

ឃ- ផ្នែកប្រាក់តិចជាង ឬ ស្មើនឹង ១.000.000 (មួយលាន) រៀល ក្រៅពីប្រាក់ដែលបានកំណត់នៅក្នុងចំណុច គ ខាងលើនេះ។

ង- ឧបករណ៍ ជី សត្វពាហន:ដែលជាចាំបាច់សម្រាប់ការងារកសិកម្មរបស់ខ្លួន និងចំណីសត្វទាំងនេះព្រមទាំង គ្រាប់ពូជ ឬ កសិផលដែលមានប្រភេទដូចគ្នា ដែលត្រូវការចាំបាច់សម្រាប់បន្តការងារកសិកម្មរហូតដល់រដូវបានផលបន្ទាប់ របស់កសិករក្នុងការប្រកបរបរកសិកម្ម។

[7] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣១, ០៨ ធ្នូ ២០០៧, មាត្រា១២០ កថាខណ្ឌទី៣។

[8] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣១, ០៨ ធ្នូ ២០០៧, មាត្រា១២០ កថាខណ្ឌទី៣។

[9] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៣៨៥ មាត្រា៣៨៦។

ច- មង សំណាញ់ ឬ នេសាទុបករណ៍ផ្សេងៗចាំបាច់ ចំណី និងកូនត្រី ឬ ជលផលប្រភេទដូចគ្នា ដែលត្រូវការចាំបាច់ សម្រាប់រកជលផល ឬ ចិញ្ចឹមជលផលរបស់អ្នកប្រកបរបរនេសាទ ។

ឆ- ឧបករណ៍ និងវត្ថុផ្សេងៗ ដែលចាំបាច់សម្រាប់អ្នកបច្ចេកទេស សិប្បករ កម្មករ និងអ្នកផ្សេងទៀត ដែល ប្រកបរបរវិជ្ជាជីវៈ ឬ សាជីវកម្ម ដោយប្រើកម្លាំងប្រាជ្ញា កម្លាំងកាយ ។ ប៉ុន្តែ បើជាវត្ថុដែលអ្នកនោះមានក្នុងគោលបំណងសម្រាប់លក់ ឬ ជួលវិញ អាចរឹបអូសយកបាន។

ជ- ព្រះពុទ្ធរូប ក្បួនរីតីសាសនា និងវត្ថុផ្សេងៗដែលចាំបាច់សម្រាប់ពិធីក្នុងសាសនា។

ឈ- ពង្សាវលី កំណត់ប្រចាំថ្ងៃ បញ្ជីប្រកបមុខរបរ និងឯកសារប្រភេទដូចគ្នា ដែលចាំបាច់របស់កូនបំណុលនៃការអនុវត្ត។

ញ- គ្រឿងឥស្សរិយយស និងប័ណ្ណសរសើរផ្សេងទៀតរបស់កូនបំណុលនៃការអនុវត្ត ឬ របស់ញាតិរបស់ជននោះ។

ដ- ឯកសារ និងឧបករណ៍ ដែលចាំបាច់ក្នុងការសិក្សា នៅសាលា ឬ នៅស្ថាប័នអប់រំផ្សេងទៀត របស់កូនបំណុល នៃការអនុវត្ត និងញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នា។

ឋ- វត្ថុដែលទាក់ទងនឹងតក្កកម្ម ឬ ស្នាដៃនិពន្ធ ដែលមិនទាន់បានផ្សាយជាសាធារណៈ។

ឌ- អវយវៈសិប្បនិមិត្ត សរីរាង្គសិប្បនិមិត្តផ្សេងទៀត និងឧបករណ៍ជំនួយខ្លួនប្រាណផ្សេងទៀត ដែលចាំបាច់របស់កូនបំណុលនៃការអនុវត្ត និងញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នា ព្រមទាំងវត្ថុផ្សេងៗសម្រាប់ថែទាំអ្នកជម្ងឺ ដែលជាកូនបំណុលនៃការអនុវត្ត និងញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នា។

ណ- ម៉ាស៊ីន ឬ ឧបករណ៍ពន្លត់ភ្លើង ឧបករណ៍ជន្លៀសខ្លួនពេលមានអាសន្ន ឬ ឧបករណ៍ផ្សេងទៀត សម្រាប់អាគារ ឬ សំណង់ផ្សេងទៀត ដែលច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងៗតម្រូវឱ្យមានបរិក្ខារ ដើម្បីបង្ការមហន្តរាយ ឬ ការពារសន្តិសុខ។ [10]

ជាធម្មតា ក្រមនីតិវិធីរដ្ឋប្បវេណីបានចែងច្បាស់លាស់អំពីចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូសបាន ប៉ុន្តែមានបញ្ហាខ្លះដែលអាចកើតឡើងក្នុងករណីជាក់ស្តែង។ ហេតុនេះហើយបានជាមាត្រា៣៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានចែងអាចឱ្យតុលាការអាចពង្រីក ឬ កម្រិតនូវទំហំនៃចលនវត្ថុដែលមិនអាចត្រូវរឹបអូសបានតាមឆន្ទៈរបស់ខ្លួនបាន ដើម្បីតម្រូវទៅតាមស្ថានភាពនៃករណីនីមួយៗ នៅពេលដែលមានពាក្យសុំ។ នៅពេលធ្វើការពង្រីក ឬ កម្រិតនូវទំហំនៃចលនវត្ថុដែលមិនអាចត្រូវរឹបអូសនោះ តុលាការត្រូវពិចារណាអំពីជីវភាពរស់នៅ និងស្ថានភាពផ្សេងៗរបស់កូនបំណុល និងម្ចាស់បំណុលនោះ។

[10] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៣៨០។

ឧទាហរណ៍៖ ចំពោះករណីដែលជីវភាពរបស់កូនបំណុលនៃការអនុវត្ត និងអាចធ្លាក់ចុះយ៉ាងដុនដាប ដោយសារការរឹបអូសនោះជាដើម ទំហំនៃចលនវត្ថុដែលមិនអាចរឹបអូសបានក៏ត្រូវតែពង្រីក រីឯចំពោះករណីម្ចាស់បំណុលនៃមានជីវភាពរស់នៅយ៉ាងទាបបំផុតហើយទាមទារឱ្យអនុវត្តដោយបង្ខំ ចំពោះសិទ្ធិលើបំណុលដែលជាប្រាក់ដើម្បីគាំទ្រជីវភាពរបស់ខ្លួននោះ ទំហំនៃចលនវត្ថុដែលមិនអាចត្រូវរឹបអូសបាននោះក៏ត្រូវកម្រិតទៅតាមសភាពនោះដែរ។

២.៣.២ តាគីនៃការរឹបអូសជាបណ្តោះអាសន្ន

ភាគីនៅក្នុងការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុមាន ភាគីដែលដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសបណ្តោះអាសន្នចំពោះចលនវត្ថុហៅថា អ្នកដាក់ពាក្យសុំ ឬ ម្ចាស់បំណុល ហើយចំណែកឯភាគីម្ខាងទៀតហៅថា កូនបំណុល។[11] រីឯ បុគ្គលដែលអះអាងថាខ្លួនមានសិទ្ធិដែលនឹងត្រូវបានរក្សាការពារហើយបានដាក់ពាក្យសុំរក្សាការពារមកតុលាការហៅថាម្ចាស់បំណុល រីឯភាគីម្ខាងទៀតនៃពាក្យសុំនេះហៅថាកូនបំណុល (សំណុំរឿងរក្សាការពារ)។

ជាងនេះទៅទៀត ចំពោះសំណុំរឿងអនុវត្តរក្សាការពារ បុគ្គលដែលបានទទួលសេចក្តីសម្រេចពីតុលាការដែលបានចេញដីកាសម្រេចចាត់ចែងរក្សាការពារ និងបានដាក់ពាក្យសុំអនុវត្តដីកាសម្រេចនេះហៅថា ម្ចាស់បំណុល រីឯភាគីម្ខាងទៀតនៃពាក្យសុំនេះ ហៅថា កូនបំណុល (សំណុំរឿងអនុវត្តរក្សាការពារ) ពីព្រោះនៅក្នុងមាត្រា៥៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនរាប់បញ្ចូលមាត្រា៣៤៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីទេ នាំឱ្យបកស្រាយថាមិនអាចប្រើពាក្យម្ចាស់បំណុលនិងកូនបំណុលនៃការអនុវត្ត នៅក្នុងសំណុំរឿងអនុវត្តរក្សាការពារបានឡើយ ហើយការអនុវត្តរក្សាការពារមិនមានលំហូរនីតិវិធីស្មុគស្មាញនិងវែងឆ្ងាយដូចសំណុំរឿងអនុវត្តដោយបង្ខំឡើយ។

ក្នុងករណីដែលចាំបាច់ដើម្បីរក្សាការពារសិទ្ធិលើបំណុលរបស់ខ្លួន ម្ចាស់បំណុល អាចអនុវត្តសិទ្ធិដែលកូនបំណុលមានជំនួសកូនបំណុលបាន។[12] ចំពោះកូនបំណុលមិនអាចទទួលតាវកាលិកពីកូនបំណុលទី៣បានទេ ម្ចាស់បំណុលដែលអនុវត្តសិទ្ធិឧបាទេសកម្មអាចទាមទារឱ្យកូនបំណុលទី៣នោះ ផ្តល់តាវកាលិកចំពោះខ្លួនផ្ទាល់បាន។[13]

ឧទាហរណ៍៖ លោក ក បានឱ្យ **លោក ខ** ខ្ចីប្រាក់ចំនួន **១០ ០០០ ដុល្លារ**។ កំណត់ពេលសង់ត្រឹម១ខែ លុះហួសពេលកំណត់សង **លោក ខ** មិនបានមិនបានអនុវត្តកាតព្វកិច្ចសងប្រាក់ដល់ **លោក ក** នោះទេ។ **លោក**

[11] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២, ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០, ទំព័រ១៩៤។

[12] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៤២២ កថាខណ្ឌទី១។

[13] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៤២៦ កថាខណ្ឌទី២។

ក ក៏បានដឹងថា **លោក ខ** មានសិទ្ធិលើបំណុលចំពោះ **លោក គ** ចំនួន **១០ ០០០ ដុល្លារ** ហើយ **លោក ខ** គ្មានទ្រព្យសម្បត្តិអ្វីផ្សេងទៀតនោះទេ។ នោះ **លោក ក** អាចអនុវត្តសិទ្ធិឧបាទេសកម្មទៅលើ **លោក គ** បាន។

ផ្នែកទី៣ លក្ខខ័ណ្ឌនៃការរឹបអូសជាបណ្តោះអាសន្ន

៣.១ លក្ខខ័ណ្ឌលើសិទ្ធិដែលត្រូវបានរក្សាការពារ

លក្ខខ័ណ្ឌលើសិទ្ធិដែលត្រូវបានរក្សាការពារមានដូចខាងក្រោម ៖

- **សិទ្ធិដែលត្រូវបានរក្សាការពារ**

សិទ្ធិដែលត្រូវរក្សាការពារដោយការរឹបអូសជាបណ្តោះអាសន្ន ចាំបាច់ត្រូវតែជាសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់(សិទ្ធិទាមទារឱ្យសងជាប្រាក់)។[14] ជាក់ស្តែង សិទ្ធិដែលត្រូវរក្សាការពារជាសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ដូចជាម្ចាស់បំណុលមានសិទ្ធិលើបំណុល ចំពោះកូនបំណុលចំនួន **១០ ០០០ ០០០ រៀល** ផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ ជាអាទិ៍។ មួយវិញទៀត សិទ្ធិលើទ្រព្យសម្បត្តិប្រសិនបើចង់សម្រេចដោយការសងជាប្រាក់ក៏អាចសុំឱ្យចាត់ចែងរក្សាការពារ តាមរយៈការរឹបអូសជាបណ្តោះអាសន្នដែរ។[15]

ឧទាហរណ៍៖ លោក ក ជំពាក់ប្រាក់ **លោក ខ** ចំនួន **១៥០ ០០០ ដុល្លារ**។ **លោក ក** ជាកូនបំណុលមានរថយន្ត១គ្រឿង ដែលមានតម្លៃប្រហែល **១០០ ០០០ ដុល្លារ**។ នៅក្នុងនីតិវិធីបណ្តឹងទាមទារប្រាក់នេះ ត្រូវចំណាយពេលវេលាច្រើន ករណីនេះម្ចាស់បំណុល **លោក ខ** អាចនឹងបាត់បង់ផលប្រយោជន៍ក្នុងករណីដែលកូនបំណុល **លោក ក** យករថយន្តនោះទៅចាត់ចែងអស់។ ដូច្នេះ ដើម្បីការពារផលប្រយោជន៍របស់ខ្លួនម្ចាស់បំណុល **លោក ខ** ត្រូវដាក់ពាក្យសុំឱ្យតុលាការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុរបស់កូនបំណុល **លោក ក**ដើម្បីធានាការអនុវត្តរបស់ម្ចាស់បំណុល **លោក ខ** នៅពេលដែលគាត់ឈ្នះក្តី។ ដូច្នេះក្រោយពេលចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុរបស់កូនបំណុល **លោក ក** ហើយកូនបំណុល **លោក ក** ត្រូវបានកម្រិតនូវសិទ្ធិចាត់ចែងខ្លួនលើចលនវត្ថុដែលត្រូវរឹបអូសជាបណ្តោះអាសន្ន។

- **សិទ្ធិទាមទារដែលភ្ជាប់នឹងលក្ខខ័ណ្ឌ ឬ ពេលកំណត់**

សិទ្ធិទាមទារដែលត្រូវបានរក្សាការពារ អាចជាសិទ្ធិដែលភ្ជាប់នឹងលក្ខខ័ណ្ឌ ឬ ពេលកំណត់បាន។[16] ប៉ុន្តែ ចំពោះសិទ្ធិទាមទារដែលភ្ជាប់នឹងលក្ខខ័ណ្ឌបង្អង់ ចាំបាច់មានអត្ថិភាពមូលដ្ឋាននៃសិទ្ធិ។ បើមានសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ ទោះបីជាសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់

[14] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៣១។

[15] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤៥ កថាខណ្ឌទី១។

[16] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤៥ កថាខណ្ឌទី១។

នេះភ្ជាប់នឹងលក្ខខ័ណ្ឌ ឬ ពេលកំណត់ក៏ដោយក៏អាចក្លាយជាសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ។ ជាក់ស្តែង សិទ្ធិទាមទារឱ្យសងសំណងនាពេលអនាគតរបស់អ្នកធានា និងសិទ្ធិរបស់អ្នកដាក់ពាក្យបណ្តឹងក្នុងការទាមទារឱ្យសងវិញនូវប្រាក់ប្រដាប់ក្តីនាពេលអនាគតចំពោះភាគីម្ខាងទៀត។ ចំពោះសិទ្ធិទាមទារដែលពុំមានការទទួលស្គាល់តម្លៃជាទ្រព្យសម្បត្តិបច្ចុប្បន្ន ដូចជាករណីដែលលក្ខខ័ណ្ឌរបស់វាកម្រនឹងបានសម្រេច ឬ ករណីដែលពេលកំណត់ស្ថិតនៅឆ្ងាយពេកជាដើមនោះ មិនអាចត្រូវបានទទួលស្គាល់នូវលក្ខខ័ណ្ឌនៃសិទ្ធិដែលត្រូវរក្សាការពារទេ។[17]

ឧទាហរណ៍៖ លោក ក អះអាងសិទ្ធលើបំណុលនៃប្រាក់កម្ចីជាសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារដោយផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគប្រាក់ដែលបានបង្កើត នៅថ្ងៃទី១ ខែតុលា ឆ្នាំ ២០២២ ជាមួយ **លោក ខ** ដោយយកថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ ជាពេលកំណត់សង។ ទោះបីជាការកំណត់នៃការសងប្រាក់មិនទាន់បានមកដល់ ក៏អ្នកឱ្យខ្ចីអាចយកសិទ្ធិលើបំណុលរបស់ខ្លួនដែលមានលក្ខខ័ណ្ឌ ឬ ពេលកំណត់ទៅដាក់ពាក្យសុំរឹបអូសបណ្តោះអាសន្នលើរថយន្តនោះបានផងដែរ។

- **បណ្តឹងអង្គសេចក្តីអំពីសិទ្ធិដែលពាក់ព័ន្ធ**

បណ្តឹងអង្គសេចក្តីអំពីសិទ្ធិដែលមានការពាក់ព័ន្ធនោះ មិនអាចដាក់ទៅតុលាការកម្ពុជាបាន ដូចជាករណីនៃសិទ្ធិទាមទារដែលភ្ជាប់នឹងកិច្ចសន្យាមជ្ឈត្តកម្ម ឬ សិទ្ធិទាមទារដែលស្ថិតក្រោមសិទ្ធិជម្រះក្តីរបស់តុលាការបរទេសជាអាទិ៍ ក៏អាចអនុវត្តការរឹបអូសជាបណ្តោះអាសន្នបានដែរ ដោយយោងទៅលើភាពចាំបាច់នៃការរក្សាការពារ។ ចំពោះ សិទ្ធិទាមទារដែលកើតចេញពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងដូចជា ការទាមទារឱ្យផ្តល់អាហារកាតព្វកិច្ច ការទាមទារឱ្យបែងចែងទ្រព្យសម្បត្តិ ជាអាទិ៍ ក៏ត្រូវអនុវត្តដូចគ្នាដែរ។

៣.២ ភាពចាំបាច់នៃការរក្សាការពារ

ការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន មិនត្រឹមតែផ្អែកទៅលើអត្ថិភាពនៃសិទ្ធិដែលត្រូវបានរក្សាការពារប៉ុណ្ណោះទេ តែត្រូវផ្អែកលើភាពចាំបាច់នៃការរក្សាការពារផងដែរ។ មានន័យថា មានតែក្នុងករណីដែលការអនុវត្តដោយបង្ខំនាពេលអនាគតនឹងមិនអាចធ្វើបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ បើបណ្តោយឱ្យស្ថានភាពបច្ចុប្បន្នស្ថិតនៅដដែលប៉ុណ្ណោះទេ ដែលត្រូវចាត់ទុកថា ការរក្សាការពារមានភាព

[17] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២, ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០, ទំព័រ១៩៤។

ចាំបាច់។ [18] ដូច្នេះ ប្រសិនបើមានត្រឹមតែអត្ថិភាពនៃសិទ្ធិដែលត្រូវរក្សាការពារ ហើយពុំមានភាពចាំបាច់ដែលត្រូវរក្សាការពារនោះការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នក៏ពុំអាចធ្វើទៅបានផងដែរ។

ម៉្យាងវិញទៀត ការរក្សាការពារត្រូវបានចាត់ទុកថាមានភាពចាំបាច់ នៅក្នុងករណីដែលស្ថានភាពទ្រព្យសម្បត្តិរបស់កូនបំណុលទំនងជានឹងធ្លាក់តម្លៃជាបរិមាណ ឬ ជាគុណភាព ឬ នឹងមានតែទ្រព្យសម្បត្តិដែលពិបាកប្តូរជាប្រាក់នៅក្នុងការអនុវត្តដោយបង្ខំប៉ុណ្ណោះ ដែលនៅសល់ដោយសារការចាយវាយខ្ជះខ្ជាយ ការលក់ក្នុងតម្លៃថោក ការខូចខាត ការបំបាត់ ជាអាទិ៍។ ការរក្សាការពារ ក៏ត្រូវបានចាត់ទុកថាមានភាពចាំបាច់ដែរ នៅក្នុងករណីដែលកូនបំណុលបានគេចខ្លួន ឬ បានប្តូរលំនៅឋានជាច្រើនលើកជាច្រើនសារបង្កឱ្យមានការពិបាកក្នុងការដឹងពីទ្រព្យសម្បត្តិរបស់កូនបំណុល ហើយបើការណ៍នោះ ត្រូវបានយល់ឃើញថាជាឧបសគ្គចំពោះការអនុវត្តដោយបង្ខំ។ ចំពោះភាពចាំបាច់នៃការរក្សាការពារចាំបាច់ត្រូវសរសេរអង្គហេតុបង្ហាញស្ថានភាពទាំងនោះឱ្យបានលម្អិត។ ការកំណត់នេះ មិនត្រូវកម្រិតតែត្រឹមអ្វីដែលផ្អែកលើទង្វើផ្ទាល់ខ្លួនរបស់កូនបំណុលតែប៉ុណ្ណោះទេ។ ក៏ប៉ុន្តែ ដោយសារថាគោលបំណងនៃការរឹបអូសជាបណ្តោះអាសន្នមិនមែនដើម្បីទទួលបានការសម្រេចសិទ្ធិដែលពេញលេញជាងពេលបច្ចុប្បន្នទេនោះអសាធនភាពនាពេលបច្ចុប្បន្នរបស់កូនបំណុលតែឯកឯង មិនអាចធ្វើឱ្យការរក្សាការពារមានភាពចាំបាច់ទេ។ ដោយឡែក ប្រសិនបើសាធនភាពរបស់កូនបំណុលមានភាពគ្រប់គ្រាន់ ហើយទំនងជានឹងអាចសម្រេចសិទ្ធិទាមទារបានដោយងាយស្រួលនោះ ភាពចាំបាច់នៃការរក្សាការពារនឹងត្រូវបានបដិសេធ។ ការបដិសេធរបស់កូនបំណុលចំពោះសិទ្ធិដែលត្រូវបានរក្សាការពារ ឬ ឥរិយាបថរបស់កូនបំណុលក្នុងការមិនព្រមអនុវត្តកាតព្វកិច្ចចំពោះសិទ្ធិនោះ ពុំមែនជាមូលហេតុនៃការបញ្ជាក់អំពីភាពចាំបាច់នៃការរក្សាការពារទេ ព្រោះសកម្មភាពទាំងនោះមិនមែនជាឧបសគ្គចំពោះការអនុវត្តដោយបង្ខំឡើយ។ ត្រង់ចំណុចនេះ ចរិតលក្ខណៈរបស់ភាពចាំបាច់ក្នុងការរក្សាការពារ គឺខុសគ្នាពី "ភាពចាំបាច់ដែលតម្រូវឱ្យធ្វើការទាមទារជាមុន" ដែលជាលក្ខខ័ណ្ឌសម្រាប់ធ្វើបណ្តឹងទាមទារឱ្យផ្តល់តារាកាលិកនាពេលអនាគត។

ក្នុងករណីដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំទំនងជានឹងត្រូវធ្វើនៅបរទេសនោះការរក្សាការពារត្រូវចាត់ទុកថាមានភាពចាំបាច់។ តួយ៉ាង ករណីដែលកូនបំណុលបានបង្ហាញសញ្ញានៃការចាត់ចែងទ្រព្យសម្បត្តិ និងការធ្វើអន្តោប្រវេសន៍ទៅបរទេស ជាអាទិ៍។ មួយវិញទៀត ទោះបីជាក្នុងករណីដែលបានបំពេញតាមលក្ខខ័ណ្ឌទូទៅហើយក៏ដោយ ក៏ភាពចាំបាច់នៃការរក្សាការពារអាចនឹងត្រូវបានបដិសេធដែរ។

ឧទាហរណ៍៖ ករណីដែលសិទ្ធិលើបំណុល មានភ្ជាប់នឹងសិទ្ធិប្រាតិភោគប្រត្យក្សគ្រប់គ្រាន់ហើយ ឬ ករណីដែលសិទ្ធិលើបំណុលបំពេញលក្ខខ័ណ្ឌគ្រប់គ្រាន់ ដើម្បីធ្វើការអនុវត្តដោយបង្ខំដោយគ្មានលក្ខខ័ណ្ឌ។

[18] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤៥ កថាខណ្ឌទី១។

ជំពូកទី២
នីតិវិធីនៃការបើបអូសជាបណ្តោះអាសន្ន
លើចលនវត្ថុ

ជំពូកទី២

នីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ

ផ្នែកទី១ នីតិវិធីក្នុងការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ

១.១ សមត្ថកិច្ចតុលាការ

សមត្ថកិច្ចរបស់តុលាការ គឺជាទំហំនៃសិទ្ធិអំណាច ដែលអាចអនុវត្តសិទ្ធិនៃការសម្រេចសេចក្តី ហើយសិទ្ធិអំណាចទាំងនេះ ត្រូវបានប្រគល់ឱ្យទៅតុលាការគ្រប់ជាន់ថ្នាក់។ ដូច្នេះ តុលាការដែលមានសមត្ថកិច្ច គឺជាតុលាការដែលអាចទទួលដោយស្របច្បាប់នូវពាក្យបណ្តឹង វិនិច្ឆ័យលើរឿងក្តី ហើយចេញសាលក្រម ឬសាលដីកាបាន។[19] សមត្ថកិច្ចតុលាការនៃការរឹបអូសជាបណ្តោះអាសន្ននេះ ជាសមត្ថកិច្ចផ្តាច់មុខ។[20] ហើយតុលាការមាន សមត្ថកិច្ចលើរឿងក្តីនៃការរឹបអូសជាបណ្តោះអាសន្ន រួមមាន (១.១.១) តុលាការនៃបណ្តឹងអង្គសេចក្តី (១.១.២) តុលាការនៃវត្ថុដែលត្រូវជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន។[21]

១.១.១ តុលាការនៃបណ្តឹងអង្គសេចក្តី

តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី គឺសំដៅលើរឿងក្តីនៃពាក្យបណ្តឹងត្រូវបានដាក់ចំពោះសិទ្ធិលើបំណុលដែលត្រូវបានរឹបអូសជាបណ្តោះអាសន្ន អង្គសេចក្តីក៏អាចជារឿងក្តីមជ្ឈត្តកម្ម ឬ រឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងដែរ។[22]

នៅមុនពេលដាក់ពាក្យបណ្តឹងអង្គសេចក្តី តុលាការមានសមត្ថកិច្ច គឺតុលាការដែលមានសមត្ថកិច្ចលើរឿងក្តីនៃបណ្តឹងដែលនឹងធ្វើនាពេលអនាគត ហើយបើមានតុលាការដែលមានសមត្ថកិច្ចបែបនេះច្រើន នោះអាចជ្រើសរើសយកតុលាការណាមួយក្នុងចំណោមតុលាការទាំងនោះបាន។ នៅពេលដែលអង្គសេចក្តីកំពុងត្រូវបានចាត់ការ ជាគោលការណ៍តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី គឺតុលាការនៃការជំនុំជម្រះលើកទី១។ ប៉ុន្តែ ប្រសិនបើអង្គសេចក្តីកំពុងត្រូវបានចាត់ការនៅក្នុងនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី គឺតុលាការនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ (មាត្រា៥៤០ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ក្នុងករណីដែលអង្គសេចក្តីកំពុងត្រូវបានចាត់ការនៅក្នុងនីតិវិធីនៃបណ្តឹងសាទុក្ខនោះ គឺតុលាការដែលជាអ្នកមានសមត្ថកិច្ចលើអង្គសេចក្តី គឺតុលាការនៃការជំនុំជម្រះលើកទី១។ ជាគោលការណ៍ តុលាការកំពូលជាតុលាការអង្គច្បាប់មិនវិនិច្ឆ័យលើអង្គហេតុនោះទេ។ ចំពោះសិទ្ធិជម្រះពីរដងរបស់គូភាគីនៃសំណុំរឿងរក្សា

[19] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៧។

[20] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៣៣។

[21] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤០ កថាខណ្ឌទី១។

[22] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤០។

ការពារមិនអាចត្រូវបានផ្តល់ជូនឡើយ បើទទួលស្គាល់តុលាការកំពូលក្នុងនាមជាតុលាការអង្គសេចក្តីចំពោះសំណុំរឿងរក្សាការពារ ដូច្នេះ ប្រសិនបណ្តឹងអង្គសេចក្តីត្រូវបានជំនុំជម្រះតុលាការកំពូលហើយមានភាគីណាមួយយល់ថា ត្រូវធ្វើនីតិវិធីចាត់ចែងរក្សាការពារត្រូវដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារនោះ ទៅតុលាការនៃការជំនុំជម្រះលើកទី១វិញ (តុលាការមានសមត្ថកិច្ចលើបណ្តឹងអង្គសេចក្តី)។

ឧទាហរណ៍៖ លោក ក មានសិទ្ធិលើបំណុលចំពោះ**លោក ខ** ចំនួន **១០០ ០០០ដុល្លារ** ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ ក្រោយមក**លោក ក** មិនបានអនុវត្តកាតព្វកិច្ចសងប្រាក់របស់ខ្លួន។ **លោក ក** មានរថយន្តមួយគ្រឿងស្ថិតនៅរាជធានីភ្នំពេញ។ ករណីនេះ សំណុំរឿងបណ្តឹងតាមអង្គសេចក្តីរបស់**លោក ខ** កំពុងចាត់ការនៅសាលាឧទ្ធរណ៍ភ្នំពេញ។ ដូច្នេះ **លោក ក** ក៏អាចដាក់ពាក្យសុំរក្សាការពាររថយន្តមួយគ្រឿងរបស់**លោក ខ** នៅសាលាឧទ្ធរណ៍ភ្នំពេញបានផងដែរ ដោយផ្អែកលើសមត្ថកិច្ចតាមបណ្តឹងអង្គសេចក្តី។

គួរបញ្ជាក់បន្ថែមថា ទោះបីជាពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ត្រូវបានដាក់ទៅតុលាការដែលអាចធ្វើបានដោយមិនចាំបាច់ឱ្យតុលាការនៃបណ្តឹងអង្គសេចក្តីផ្ញើសំណុំរឿងអង្គសេចក្តីមកតុលាការ ដែលកំពុងចាត់ការសំណុំរឿងរក្សាការពារឡើយ ពីព្រោះតុលាការរក្សាការពារពិនិត្យសេចក្តីបញ្ជាក់ដំបូងតែប៉ុណ្ណោះ។

១.១.២ តុលាការនៃវត្ថុដែលត្រូវជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន

នៅក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន បើវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន គឺជាចលនវត្ថុត្រូវបញ្ជាក់អំពីទីកន្លែងនៃចលនវត្ថុនោះ ប៉ុន្តែមិនចាំបាច់កំណត់បញ្ជាក់វត្ថុដែលជាកម្មវត្ថុនោះទេ តែត្រូវបញ្ជាក់អំពីទីកន្លែងនៃចលនវត្ថុស្ថិតនៅ។ ហើយបើវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន គឺជាវត្ថុក្រៅពីចលនវត្ថុនោះត្រូវបញ្ជាក់អំពីវត្ថុដែលជាកម្មវត្ថុនោះ។ ក្នុងករណីដែលកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន គឺជាសិទ្ធិលើបំណុល ឬ សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ត្រូវចាត់ទុកថា សិទ្ធិនោះស្ថិតនៅឯលំនៅឋានជាអាទិ៍របស់កូនបំណុលទី ៣ ឬ បុគ្គលដែលមានលក្ខណៈដូចជាកូនបំណុលទី ៣។

១.២ ការដាក់ពាក្យសុំ

ការដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវសរសេរជាលាយលក្ខណ៍អក្សរ។[23] ការកំណត់បែបនេះ គឺមានគោលបំណងដើម្បីធានានូវភាពច្បាស់លាស់។ ការដាក់ពាក្យសុំនេះត្រូវបង់ពន្ធចំនួន ៥ ០០០ (ប្រាំពាន់) រៀល។[24] ម្យ៉ាងវិញទៀត ផ្អែកតាមមាត្រា៥៤១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន មានដូចខាងក្រោម៖

[23] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៣៤ ចំណុច ក។

[24] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៣៧ កថាខណ្ឌទី១។

(១) ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

(២) ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ។

(៣) សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ។

(៤) ភាពចាំបាច់នៃការរក្សាការពារ។

ចំពោះចំណុចទី៣ និង ចំណុចទី៤ នៃកថាខណ្ឌទី១ខាងលើ អ្នកដាក់ពាក្យសុំ គប្បីសរសេរឱ្យបានច្បាស់លាស់ និងត្រូវសរសេរនូវភស្តុតាងតាមហេតុនីមួយៗដែលត្រូវបញ្ជាក់។

១.២.១ អត្តសញ្ញាណភូគាគី និងអ្នកតំណាង

នៅក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវសរសេរនូវអត្តសញ្ញាណរបស់ភាគីឱ្យបានច្បាស់លាស់ ដូចជាឈ្មោះ អាយុ លេខអត្តសញ្ញាណប័ណ្ណ អាសយដ្ឋានបច្ចុប្បន្នជាដើម។ មិនតែប៉ុណ្ណោះ អ្នកតំណាងដែលច្បាប់បានកំណត់ក៏ដូចទៅនឹងភាគី គឺត្រូវសរសេរនូវអត្តសញ្ញាណឱ្យបានច្បាស់លាស់ នៅក្នុងពាក្យសុំនោះ។ ជាពិសេស ដើម្បីឱ្យមានភាពងាយស្រួលក្នុងការជូនដំណឹងភាគី និងអ្នកតំណាងដែលច្បាប់បានកំណត់ គប្បីសរសេរនូវលេខទូរស័ព្ទបន្ថែមនៅក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។

១.២.២ ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ

ជាគោលការណ៍ កម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន ត្រូវកំណត់ឱ្យបានជាក់លាក់។[25] ប៉ុន្តែក្នុងករណីដែលកម្មវត្ថុនោះ គឺជាចលនវត្ថុមិនចាំបាច់កំណត់ជាក់លាក់អំពីចលនវត្ថុនីមួយៗនោះទេ[26] តែត្រូវបញ្ជាក់អំពីទីកន្លែងនៃចលនវត្ថុ។[27] មានន័យថា ខ្លឹមសារនៃដីកាសម្រេចរក្សាការពារ ជាចំណុចសំខាន់ដែលពុំអាចខ្វះបាន និងត្រូវមានសរសេរនូវអត្ថន័យឱ្យបានច្បាស់លាស់ ដោយសារតែខ្លឹមសារនៃការចេញដីកាសម្រេចរក្សាការពារនេះជាកម្មវត្ថុនៃការចេញដីកាសម្រេចការពារ។

ឧទាហរណ៍៖ ការរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ ច្បាប់មិនតម្រូវឱ្យកំណត់អត្តសញ្ញាណជាក់លាក់នោះទេ ពោលគឺ ចង្អុលទីតាំងចលនវត្ថុនោះស្ថិតនៅជាការគ្រាប់គ្រាន់ហើយ។

១.២.៣ សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ

សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ គឺសិទ្ធិទាមទារដែលមានកំណត់នៅក្នុងច្បាប់សារធាតុ ដែលដូចគ្នានឹងសិទ្ធិទាមទារនៅក្នុងបណ្តឹងអង្គសេចក្តីដែរ។ ផ្អែកតាមមាត្រា៥៤១ កថាខណ្ឌទី១

[25] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤៦ វាក្យខណ្ឌទី១។

[26] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤៦ វាក្យខណ្ឌទី២។

[27] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៦៥ វាក្យខណ្ឌទី១។

ចំណុច "គ" នៃក្រមនីតិវិធីរដ្ឋប្បវេណី ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវសរសេរអំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ។ ម្យ៉ាងវិញទៀត សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវរក្សាការពារ ត្រូវជាសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់។

ផ្អែកតាមមាត្រា៥៤១ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី អ្នកដាក់ពាក្យសុំគប្បីសរសេរឱ្យច្បាស់លាស់ និងសរសេរនូវភស្តុតាងតាមអង្គហេតុនីមួយៗ ដែលត្រូវបញ្ជាក់ចំពោះចំណុចស្តីពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលដូចនឹងត្រូវបានរក្សាការពារ។ ហេតុនេះ ដើម្បីឱ្យមានភាពច្បាស់លាស់ អ្នកដាក់ពាក្យសុំគប្បីសរសេរនូវអង្គហេតុដែលជាមូលហេតុនៃការទាមទារ និងអង្គហេតុសំខាន់ៗក្នុងចំណោមអង្គហេតុដែលជាមូលហេតុនៃការទាមទារដូចមានបញ្ញត្តិនៅក្នុងមាត្រា៧៥ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី។

ដូច្នេះ សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ ត្រង់ចំណុចនេះត្រូវសរសេរពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ និងអង្គហេតុសំខាន់ៗផ្សេងទៀត ព្រោះថាការសរសេរអំពីអង្គហេតុទាំងពីរនេះ គឺដើម្បីបង្កើតសិទ្ធិ។ ជាការពិតអង្គហេតុដែលជាមូលហេតុនៃការទាមទារ គឺត្រូវសរសេរនៅក្នុងពាក្យបណ្តឹង ប៉ុន្តែដីការក្សាការពារអាចចេញបានមុនការដាក់ពាក្យបណ្តឹង ត្រង់នេះមានន័យថា សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវរក្សាការពារត្រូវសរសេរយ៉ាងណាឱ្យអត្ថន័យ និងខ្លឹមសារ ដូចជាការសរសេរអង្គហេតុដែលជាមូលហេតុនៃការទាមទារ។ [28] បើម្ចាស់បំណុលអាចមើលឃើញអង្គហេតុតវ៉ាដែលនឹងអះអាងដោយកូនបំណុលជាចំណុចប្រសើរដោយម្ចាស់បំណុលត្រូវបញ្ចូលនូវការបដិសេធអំពីអង្គហេតុតវ៉ានោះ ព្រោះថាមានប្រយោជន៍សម្រាប់តុលាការក្នុងការចេញដីកាសម្រេច និងសម្រេចអំពីចំនួនប្រាតិភោគ។

១.២.៤ ភាពចាំបាច់នៃការរក្សាការពារ

ភាពចាំបាច់នៃការរក្សាការពារ ជាអង្គហេតុទាំងឡាយណាដែលបញ្ជាក់អំពីការបារម្ភរបស់ម្ចាស់បំណុលថា មិនអាចធ្វើបាន ឬ មានការលំបាកខ្លាំងក្នុងការអនុវត្តដោយបង្ខំ។ ផ្អែកតាមមាត្រា៥៤៥ កថាខណ្ឌទី១ ចំណុច ឃ នៃក្រមនីតិវិធីរដ្ឋប្បវេណី ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវសរសេរនូវភាពចាំបាច់នៃការរក្សាការពារ។

ឧទាហរណ៍៖ កូនបំណុលកំពុងតែប្រកាសលក់រថយន្ត ឬ ម្ចាស់បំណុលមិនបានស្គាល់ទ្រព្យសម្បត្តិមានតម្លៃផ្សេងទៀតរបស់កូនបំណុលក្រៅពីសម្បត្តិទាំងនេះ ជាអាទិ៍។ ការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន មិនត្រឹមតែត្រូវផ្អែកទៅលើអត្ថិភាពនៃសិទ្ធិដែលត្រូវបានរក្សាការពារប៉ុណ្ណោះទេ តែត្រូវផ្អែកលើភាពចាំបាច់នៃការរក្សាការពារផងដែរ។ មានន័យថា មានតែក្នុងករណីដែលការអនុវត្តដោយបង្ខំនាពេលអនាគតនឹង

[28] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៧៥។

មិនអាចធ្វើបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ បើបណ្តោយឱ្យស្ថានភាពបច្ចុប្បន្នស្ថិតនៅដដែលប៉ុណ្ណោះទេ ដែលត្រូវចាត់ទុកថាការរក្សាការពារមានភាពចាំបាច់។[29]

ការរក្សាការពារត្រូវបានចាត់ទុកថាមានភាពចាំបាច់ នៅក្នុងករណីដែលស្ថានភាពទ្រព្យសម្បត្តិរបស់កូនបំណុលទំនងជានឹងធ្លាក់តម្លៃ ជាបរិមាណ ឬ ជាគុណភាព ឬ នឹងមានតែទ្រព្យសម្បត្តិដែលពិបាកប្តូរជាប្រាក់នៅក្នុងការអនុវត្តដោយបង្ខំប៉ុណ្ណោះដែលនៅសល់ ដោយសារការចាយវាយខ្ជះខ្ជាយ ការលក់ក្នុងតម្លៃថោកការខូចខាត ការបំបាត់ ជាអាទិ៍។ ការរក្សាការពារក៏ត្រូវបានចាត់ទុកថាមានភាពចាំបាច់ដែរ នៅក្នុងករណីដែលកូនបំណុលបានគេចខ្លួន ឬ បានប្តូរលំនៅឋានជាច្រើនលើកច្រើនសារ ហើយបើការណ៍នោះ ត្រូវបានយល់ឃើញថាជាឧបសគ្គចំពោះការអនុវត្តដោយបង្ខំ។ ការកំណត់នេះមិនត្រូវកម្រិតតែត្រឹមអ្វី ដែលផ្អែកលើទង្វើផ្ទាល់ខ្លួនរបស់កូនបំណុលតែប៉ុណ្ណោះទេ។

ក្នុងករណីដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំទំនងជានឹងត្រូវធ្វើនៅបរទេស នោះការរក្សាការពារត្រូវចាត់ទុកថាមានភាពចាំបាច់។ តួយ៉ាង ករណីដែលកូនបំណុលបានបង្ហាញសញ្ញានៃការចាត់ចែងទ្រព្យសម្បត្តិ និងការធ្វើអន្តោប្រវេសន៍ទៅបរទេស ជាអាទិ៍។

ទោះបីជាក្នុងករណីដែលបានបំពេញតាមល័ក្ខខ័ណ្ឌទូទៅហើយក៏ដោយ ក៏ភាពចាំបាច់នៃការរក្សាការពារអាចនឹងត្រូវបានបដិសេធដែរ។ ជាក់ស្តែង ករណីដែលសិទ្ធិលើបំណុល មានភ្ជាប់នឹងសិទ្ធិប្រាតិភោគប្រត្យក្សគ្រប់គ្រាន់ហើយ ឬ ករណីដែលសិទ្ធិលើបំណុលបំពេញល័ក្ខខ័ណ្ឌគ្រប់គ្រាន់ ដើម្បីធ្វើការអនុវត្តដោយបង្ខំដោយគ្មានល័ក្ខខ័ណ្ឌ។

១.៣ ឯកសារដែលត្រូវភ្ជាប់ជាមួយ

នៅក្នុងពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឯកសារដែលភ្ជាប់ជាមួយពាក្យសុំនេះមានច្រើនប្រភេទដូចជា ឯកសារសម្រាប់ធ្វើសេចក្តីបញ្ជាក់ដំបូង (មាត្រា៥៤១ កថាខណ្ឌទី ៣) ឯកសារសម្រាប់បញ្ជាក់អំពីសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិ (មាត្រា៥៣ កថាខណ្ឌទី ២) ឯកសារសម្រាប់បញ្ជាក់កម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន (មាត្រា ៥៤១ កថាខណ្ឌទី១ ចំណុច ខ) , មាត្រា៥៤៦ និងឯកសារផ្សេងៗទៀត។

១.៣.១ ឯកសារសម្រាប់ធ្វើសេចក្តីបញ្ជាក់ដំបូង

យោងតាមមាត្រា ១៣១ សេចក្តីបញ្ជាក់ដំបូងត្រូវធ្វើឡើងដោយភស្តុតាងដែលអាចពិនិត្យបានភ្លាមៗ ដូច្នេះ ឯកសារសម្រាប់ធ្វើសេចក្តីបញ្ជាក់ដំបូង គឺជាឯកសារធ្វើភស្តុតាងត្រូវជាឯកសារមួយដែល អាចពិនិត្យបានភ្លាមៗ ដោយមិនប្រើរយៈពេលយូរងាយស្រួលនៅពេលធ្វើសេចក្តីបញ្ជាក់ដំបូង។ នៅក្នុងច្បាប់មិនបានកំណត់អំពីការធ្វើសេចក្តីបញ្ជាក់ដំបូងទេ ប៉ុន្តែច្បាប់បានកំណត់ចំណុចមួយចំនួនដែលត្រូវយកមកធ្វើសេចក្តី

[29] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤៥ កថាខណ្ឌទី១។

បញ្ជាក់ដំបូង ដែលមានចែងនៅក្នុងមាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំនិងសេចក្តីបញ្ជាក់ដំបូង (សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ និងភាពចាំបាច់នៃការរក្សាការពារ)។[30]

- **ឯកសារបញ្ជាក់ដំបូងអំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តិដែលនឹងត្រូវបានការពារ**

អ្នកដាក់ពាក្យសុំដីកាសម្រេចចាត់ចែងរក្សាការពារ (ម្ចាស់បំណុល) ចាំបាច់ត្រូវធ្វើសេចក្តីបញ្ជាក់ដំបូងចំពោះសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តិដែលនឹងត្រូវបានរក្សាការពារ។ ដើម្បីធ្វើសេចក្តីបញ្ជាក់ចំពោះសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តិដែលនឹងត្រូវបានរក្សាការពារ អ្នកដាក់ពាក្យសុំត្រូវធ្វើការបញ្ជាក់ពីអង្គហេតុចាំបាច់ ដើម្បីបញ្ជាក់ការទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារ។ ភស្តុតាងដែលត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង គឺឯកសារ។

ឧទាហរណ៍៖ ឯកសារដែលបញ្ជាក់ពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តិនោះ គឺមានទៅតាមប្រភេទនៃរឿងក្តី ដូចជារឿងក្តីទាក់ទងនឹងកិច្ចសន្យាកិច្ចខ្ចីបរិភោគ គឺលិខិតកិច្ចសន្យាខ្ចីបរិភោគ រឿងក្តីទាក់ទងនឹងការទាមទារឱ្យប្រគល់ចលនវត្ថុ គឺប័ណ្ណកម្មសិទ្ធិ ហើយរឿងក្តីទាក់ទងនឹងការទាមទារឱ្យប្រគល់រថយន្តដោយសារការបញ្ចប់ភតិសន្យា ឬ ការបញ្ចប់កិច្ចសន្យាខ្ចីប្រើ គឺភតិសន្យា ឬ កិច្ចសន្យាខ្ចីប្រើតាមលំដាប់លំដោយ។

ផ្ទុយទៅវិញ បើម្ចាស់បំណុលខកខានមិនបានដាក់ឯកសារដែលបញ្ជាក់ពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តិដែលត្រូវបានការពារទេ គឺចៅក្រមមិនអាចដឹង ឬ អាចកំណត់សិទ្ធិរបស់ម្ចាស់បំណុលបានឡើយ។ ការខ្វះឯកសារនេះគឺខុសពីល័ក្ខខ័ណ្ឌចាំបាច់ក្នុងការដាក់ពាក្យសុំដែលជាហេតុនាំឱ្យចៅក្រមត្រូវលើកពាក្យសុំនេះចោលដោយដីកាសម្រេច។[31]

- **ឯកសារបញ្ជាក់ដំបូងអំពីភាពចាំបាច់នៃការរក្សាការពារ**

លើសពីនេះ ក្រៅពីឯកសារបញ្ជាក់ដំបូងអំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តិដែលនឹងត្រូវបានការពារមានល័ក្ខខ័ណ្ឌមួយទៀត ដែលចៅក្រមត្រូវពិចារណាដែរ ថាតើមានភាពចាំបាច់នៃការរក្សាការពារដែរឬទេ។ ក្នុងអត្ថន័យនេះ សំដៅទៅលើចៅក្រមមិនអាចចេញដីកាសម្រេចរក្សាការពារដោយសំអាងលើល័ក្ខខ័ណ្ឌសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តិតែមួយប៉ុណ្ណោះទេ គឺចាំបាច់ត្រូវមានល័ក្ខខ័ណ្ឌនៃភាពចាំបាច់នៃការរក្សាការពារទើបចៅក្រមអាចចេញដីកាសម្រេចបាន។ ភាពចាំបាច់នៃការរក្សាការពារនេះ មានសារសំខាន់ណាស់ដែលមិនអាចខ្វះបានព្រោះថាការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ គឺមានការប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់កូនបំណុល។

[30] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤១ កថាខណ្ឌទី៣។

[31] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤១។

ឧទាហរណ៍៖ ឯកសារបញ្ជាក់អំពីភាពចាំបាច់ដែលម្ចាស់បំណុលត្រូវសរសេរមានដូចជា ករណីដែលស្ថានភាពទ្រព្យសម្បត្តិរបស់កូនបំណុលទំនងនឹងធ្លាក់ថ្លៃជាបរិមាណ ឬ ជាគុណភាព ឬ នឹងមានតែទ្រព្យសម្បត្តិដែលពិបាកដូរជាប្រាក់នៅក្នុងការអនុវត្តដោយបង្ខំតែប៉ុណ្ណោះ ដែលនៅសល់ដោយសារតែការចាយវាយខ្ជះខ្ជាយ ការលក់ក្នុងតម្លៃថោក ការបំបាត់ ជាអាទិ៍។

ដូច្នេះ ម្ចាស់បំណុលដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ចាំបាច់ត្រូវធ្វើសេចក្តីបញ្ជាក់ដំបូងពីភាពចាំបាច់នេះ គឺត្រូវផ្តល់ឯកសារដែលបញ្ជាក់ពីភាពចាំបាច់នៃការរក្សាការពារដោយសរសេរពីមូលហេតុ និងស្ថានភាពផ្សេងៗដែលកូនបំណុលរបស់ខ្លួន។

១.៣.២ ឯកសារសម្រាប់បញ្ជាក់អំពីសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិ

អ្នកដាក់ពាក្យសុំដីកាសម្រេចរឹបអូសបណ្តោះអាសន្នមានសិទ្ធិជ្រើសតាំងអ្នកតំណាងដោយអាណត្តិ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ខ្លួនបានដោយធ្វើសកម្មភាពបណ្តឹងជំនួសខ្លួន។ ក្នុងករណីបើមានអ្នកតំណាងដោយអាណត្តិ អ្នកដាក់ពាក្យសុំដីកាសម្រេចត្រូវដាក់ឯកសារបញ្ជាក់អំពីសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិនេះភ្ជាប់មកជាមួយពាក្យសុំ។

បើគ្មានលិខិតបញ្ជាក់ពីសិទ្ធិអ្នកតំណាងដោយអាណត្តិទេ តុលាការមិនអាចលើកពាក្យសុំនេះបានទេ គឺគ្រាន់តែឱ្យភាគីកែតម្រូវដោយណែនាំឱ្យភាគីដាក់លិខិតនេះ។ ផ្ទុយទៅវិញ បើភាគីមិនបានដាក់ទៀត តុលាការមិនអាចទទួលស្គាល់អ្នកតំណាងដោយអាណត្តិនោះទេ គឺភាគីត្រូវមកធ្វើសកម្មភាពក្នុងនីតិវិធីរក្សាការពារនេះដោយខ្លួនឯង។

ឯកសារដែលបញ្ជាក់ពីសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិ (លិខិតប្រគល់សិទ្ធិឱ្យអ្នកតំណាងដោយអាណត្តិ) ដែលជាលំក្ខខ័ណ្ឌចាំបាច់ត្រូវតែមាន បើភាគីមានអ្នកតំណាងដោយអាណត្តិ។ ជាគោលការណ៍ អ្នកតំណាងដោយអាណត្តិជាមេធាវីលើកលែងតាមលំក្ខខ័ណ្ឌមួយចំនួនតាមមាត្រា៥៣ កថាខណ្ឌទី១។ ឯកសារដែលបញ្ជាក់ពីសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិមានសារសំខាន់សម្រាប់ចៅក្រម ដើម្បីកំណត់ពីទំហំសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិ ដើម្បីធានាស្ថេរភាពនៃនីតិវិធីរក្សាការពារ។ បើអ្នកតំណាងដោយអាណត្តិធ្វើសកម្មភាពក្នុងនីតិវិធីរក្សាការពារដោយគ្មានលិខិតប្រគល់សិទ្ធិទេ គឺតុលាការមិនអាចកំណត់ពីទំហំសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិបានទេ។ ការធ្វើរបៀបនេះនាំឱ្យមានការប្រើសិទ្ធិហួសពីឆន្ទៈរបស់ភាគីផ្ទាល់ដែលអាចបណ្តាលឱ្យមានអស្ថេរភាពក្នុងនីតិវិធីរក្សាការពារ និងសង្គមទាំងមូលទៀតផង។

ដូច្នេះ លិខិតប្រគល់សិទ្ធិរបស់អ្នកតំណាងដោយអាណត្តិ គឺមានផលប្រយោជន៍សម្រាប់តុលាការក្នុងការចាត់ការនីតិវិធីរក្សាការពារប្រកបដោយយុត្តិធម៌ ស្ថេរភាពសម្រាប់ការពារសិទ្ធិ និងផលប្រយោជន៍របស់ភាគីនៃនីតិវិធីរក្សាការពារផងដែរ។

១.៣.៣ ឯកសារសម្រាប់បញ្ជាក់កម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន

ខ្លឹមសារមាត្រា៥៤១ កថាខណ្ឌទី១ ចំណុច ខ ពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវសរសេរនូវចំណុចខ្លឹមសារនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នដែលអ្នកដាក់ពាក្យសុំទាមទារដែល រួមមានប្រភេទដីកាសម្រេចកម្មវត្ថុនៃការរឹបអូសរឹបអូសជាបណ្តោះអាសន្ន និងគោលបំណងនៃការរក្សាការពារ។ កម្មវត្ថុនៃការរឹបអូសរឹបអូសជាបណ្តោះអាសន្នក៏ត្រូវមានឯកសារ ដើម្បីបញ្ជាក់ភ្ជាប់មកជាមួយនឹងពាក្យសុំពីព្រោះថាដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវបញ្ជាក់ពីកម្មវត្ថុនៃការរឹបអូសលើកលែងតែ ករណីចលនវត្ថុតុលាការអាចចេញដីកាសម្រេចបានដោយមិនចាំបាច់កំណត់កម្មវត្ថុទេ។[32]

ឯកសារដើម្បីបញ្ជាក់កម្មវត្ថុនៃការរឹបអូសបណ្តោះអាសន្ន គឺអ្នកដាក់ពាក្យសុំត្រូវធ្វើការបញ្ជាក់យ៉ាងណាដើម្បីឱ្យតុលាការជឿថា កម្មវត្ថុដែលសុំឱ្យតុលាការធ្វើការរឹបអូសជាបណ្តោះអាសន្ននោះ ពិតជាទ្រព្យសម្បត្តិរបស់កូនបំណុល។

១.៣.៤ ឯកសារបញ្ជាក់ផ្សេងៗ

ក្រៅពីឯកសារសម្រាប់ធ្វើសេចក្តីបញ្ជាក់ដំបូង ឯកសារសម្រាប់បញ្ជាក់ពីសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិ ឯកសារដើម្បីបញ្ជាក់កម្មវត្ថុនៃការរឹបអូសបណ្តោះអាសន្ន និងមានឯកសារជាច្រើនទៀត ដែលតុលាការអាចទាមទារឱ្យអ្នកដាក់ពាក្យសុំដាក់ភ្ជាប់ជាមួយពាក្យសុំ ដូចជាឯកសារបញ្ជាក់ពីភាគី លិខិតបញ្ជាក់របស់នីតិបុគ្គលដើម្បីបញ្ជាក់ពីសមត្ថភាពធ្វើជាភាគី ក្នុងករណីដែលម្ចាស់បំណុលជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ ឬ ជននៅក្រោមហិបត្តម្ភត្រូវមានឯកសារបញ្ជាក់ពីអ្នកតំណាងដែលច្បាប់កំណត់ភ្ជាប់មកជាមួយពាក្យសុំ។

១.៤ សោហ៊ុយ

១.៤.១ ពន្ធដាក់ពាក្យសុំ

ការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ម្ចាស់បំណុលដែលដាក់ពាក្យសុំឱ្យចេញដីកាសម្រេចត្រូវបង់ពន្ធចំនួន ៥.០០០រៀល ទៅតុលាការ។[33] ក្នុងករណីពន្ធពាក្យសុំខាងលើម្ចាស់បំណុលមិនបានបង់នោះទេ តុលាការនឹងបង្គាប់ម្ចាស់បំណុលបង់ពន្ធនៅក្នុងអំឡុងពេលសមរម្យមួយ។[34]ជាក់ស្តែង ប្រសិនជាម្ចាស់បំណុល

[32] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤៦។

[33] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៣៧ កថាខណ្ឌទី១។

[34] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៧៨ កថាខណ្ឌទី១។

មិនបង់ពន្ធពាក្យសុំតាមការបង្គាប់របស់តុលាការនោះទេ និងនាំឱ្យពាក្យសុំចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវលើកចោលដោយដីកាសម្រេច។ [35]

១.៤.២ ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ

ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ គឺជាប្រាក់ប្រដាប់ក្តីតុលាការដែលភាគី ឬ បុគ្គលដែលទាក់ទងនឹងរឿងក្តីត្រូវបង់ជាមុនសម្រាប់ការចំណាយរបស់តុលាការ ដែលធ្វើសកម្មភាពតាមនីតិវិធីនៅក្នុងបណ្តឹងរដ្ឋប្បវេណី។ ចំពោះក្នុងរឿងរឹបអូសជាបណ្តោះអាសន្ន ម្ចាស់បំណុលត្រូវបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធបន្ថែមពីលើពន្ធដាក់ពាក្យសុំសម្រាប់តុលាការបញ្ជូនឯកសារ ឬ សកម្មភាពផ្សេងៗទៀត។ល។

ឧទាហរណ៍៖ សោហ៊ុយសម្រាប់ការបញ្ជូនដីកាសម្រេចទៅកូនបំណុល។ [36]

១.៤.៣ បន្ទុកនៃប្រាក់ប្រដាប់ក្តី

នៅពេលដែលការសម្រេចសេចក្តីលើកចោលនូវពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវបានធ្វើឡើង សេចក្តីសម្រេចនោះត្រូវកំណត់អំពីបន្ទុកនៃប្រាក់ប្រដាប់ក្តី (បណ្តឹងជំទាស់ ចំពោះសេចក្តីសម្រេចនេះអាចត្រូវបានប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់) ដូច្នេះសេចក្តីសម្រេចនេះឆ្លើយតបទៅនឹងសេចក្តីសម្រេចដែលបញ្ចប់រឿងក្តីនៅតុលាការ។ [37] ពេលដែលដីកាសម្រេចទទួលស្គាល់ ពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវបានធ្វើមានលទ្ធភាពពីរផ្លូវ៖

- ទី១ គឺថាដីកាសម្រេចនេះមិនត្រូវកំណត់បន្ទុកនៃប្រាក់ប្រដាប់ក្តី (បណ្តឹងតវ៉ាចំពោះដីកាសម្រេចនេះអាចត្រូវបានដាក់ទៅតុលាការដែលចេញដីកាសម្រេច និងដីកាសម្រេចនេះមិនឆ្លើយតបទៅនឹងការសម្រេចសេចក្តីដែលបញ្ចប់រឿងក្តីនៅក្នុងតុលាការ។ [38]
- ទី២ គឺថាដីកាសម្រេចដែលទទួលស្គាល់ពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវកំណត់នូវប្រាក់ប្រដាប់ក្តី។

១.៥ ការពិនិត្យទៅលើពាក្យសុំដីកាសម្រេច

ចៅក្រមដែលទទួលបន្ទុកចាត់ការទៅលើពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ចៅក្រមត្រូវធ្វើការពិនិត្យទៅលើចំណុចដូចខាងក្រោម ៖

[35] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៧៨ កថាខណ្ឌទី២។

[36] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤៣។

[37] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៦៥ កថាខណ្ឌទី១។

[38] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៥០។

ក-ឈ្មោះ ឬ នាមករណ៍ និងអាស័យដ្ឋានរបស់ភាគីហើយ និងឈ្មោះអាស័យដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

ខ-ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ។

គ-សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ។

ឃ-ភាពចាំបាច់នៃការរក្សាការពារ។

លើសពីនេះទៅទៀត តុលាការនឹងធ្វើការពិនិត្យបន្ថែមទៅលើសមត្ថកិច្ចតុលាការ គឺថានៅក្នុងពាក្យសុំនោះអ្នកដាក់ពាក្យសុំបានដាក់មកតុលាការដែលមានសមត្ថកិច្ចឬមិនមាន។ លើសពីនេះទៅទៀត តុលាការធ្វើការពិនិត្យថា តើអ្នកដាក់ពាក្យសុំបានបង់ពន្ធដាក់ពាក្យសុំហើយឬនៅ។

ករណីដែលអ្នកសុំមិនទាន់បង់ពន្ធ តុលាការនឹងចេញដីកាបង្គាប់ឱ្យបង់ពន្ធ ដាក់ពាក្យសុំដោយកំណត់អំឡុងពេលសមរម្យណាមួយ ប្រសិនបើអ្នកសុំមិនបានបង់ពន្ធដាក់ពាក្យសុំ នៅក្នុងអំឡុងពេលនោះតុលាការនឹងលើកពាក្យសុំចោលដោយដីកាសម្រេច។ ជាក់ស្តែងនៅក្នុងករណីដែលអ្នកដាក់ពាក្យសុំបានដាក់ពាក្យសុំខុសសមត្ថកិច្ចតុលាការ ដែលមិនមានសមត្ថកិច្ចត្រូវផ្ទេររឿងក្តីនោះទៅឱ្យតុលាការដែលមានសមត្ថកិច្ចតាមពាក្យសុំ ឬ ឆន្ទានុសិទ្ធិរបស់តុលាការ។ ក្នុងករណីដែលនៅក្នុងពាក្យសុំសរសេរខ្វះខាតនូវចំណុចណាមួយ ឬ សរសេរផ្ទុយពីបញ្ញត្តិមាត្រា៥៤១ កថាខណ្ឌទី១ តុលាការត្រូវបង្គាប់ឱ្យអ្នកដាក់ពាក្យសុំកែតម្រូវនូវចំណុចខ្វះខាតនោះក្នុងអំឡុងពេលសមរម្យមួយ។

១.៦ ប្រាតិភោគ និងប្រាក់រំដោះ

១.៦.១ ប្រាតិភោគ

ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន អាចធ្វើដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគបាន។ ការឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគ ត្រូវអាស្រ័យទៅតាមឆន្ទានុសិទ្ធិរបស់តុលាការ (នៅក្នុងការរឹបអូសជាបណ្តោះអាសន្នជាធម្មតាតែងតែមានការតម្រូវឱ្យដាក់ប្រាតិភោគ) ។

ប្រាតិភោគ គឺដើម្បីធានានូវសំណងនៃការខូចខាតដែលអាចនឹងកើតមានដល់កូនបំណុល ក្នុងករណីដែលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននេះមានភាពខុសពីការពិត។ ម៉្យាងទៀត ជំនួសឱ្យការបង្គាប់ឱ្យដាក់ប្រាតិភោគ ជាមុនតុលាការក៏អាចដាក់ប្រាតិភោគជាលក្ខខ័ណ្ឌសម្រាប់ការអនុវត្តការរឹបអូសជាបណ្តោះអាសន្នដែរ។

ឧទាហរណ៍៖ ករណីដែលកម្មវត្ថុមិនអាចលក់បានដោយសារការរឹបអូសជាបណ្តោះអាសន្នហើយនៅពេលដែលអាចលក់វិញ តម្លៃរបស់វាបានធ្លាក់ចុះ។

- **គោលបំណងនៃប្រាតិភោគ**

លក្ខណៈពិសេសនៃនីតិវិធីចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ គឺតុលាការអាចចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុបានដោយពុំចាំបាច់សួរកូនបំណុលដោយគ្រាន់តែឆ្លងកាត់ការធ្វើសេចក្តីបញ្ជាក់ដំបូងជាការស្រេច។ ប៉ុន្តែដីកាសម្រេចរក្សាការពារ ក្នុងករណីខ្លះត្រូវប្រឈមមុខនឹងការលុបចោលទៅវិញត្រង់ចំណុចនេះ បានជះឥទ្ធិពលដល់ផលប្រយោជន៍របស់កូនបំណុល គឺបណ្តាលឱ្យកូនបំណុលខូចខាតជាច្រើន។ ដូច្នេះ ដើម្បីឆ្លើយតបនឹងការខូចខាតរបស់កូនបំណុលដែលកើតឡើងដោយថាហេតុទើបតុលាការតម្រូវឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ។ លើសពីនេះ ការដាក់ប្រាតិភោគរបស់ម្ចាស់បំណុលក្នុងបំណងទប់ស្កាត់ការប្រើប្រាស់សិទ្ធិហួសប្រមាណ។

ជាក់ស្តែងគោលបំណងនៃប្រាតិភោគ គឺដើម្បីធានាសងការខូចខាត និងសំណងជម្ងឺចិត្ត។ ម្យ៉ាងវិញទៀតកូនបំណុលនឹងមានសិទ្ធិជាអាទិភាពទៅលើម្ចាស់បំណុលផ្សេងទៀត។ ប្រាតិភោគមានគោលបំណងទប់ស្កាត់ឬ បញ្ឈៀសការប្រើប្រាស់សិទ្ធិដោយបំពានរបស់ម្ចាស់បំណុល ពោលគឺម្ចាស់បំណុលមិនអាចធ្វើការរក្សាការពារទៅលើទ្រព្យសម្បត្តិរបស់កូនបំណុលតាមអំពើចិត្តនោះទេ ហេតុនេះប្រាតិភោគក៏ជាល័ក្ខខ័ណ្ឌមួយដែលត្រូវបំពេញដោយម្ចាស់បំណុលផងដែរ ប្រសិនបើតុលាការបង្គាប់ឱ្យដាក់ប្រាតិភោគ។

ការដាក់ប្រាតិភោគ អាចជាល័ក្ខខ័ណ្ឌនៃការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬ ជាល័ក្ខខ័ណ្ឌនៃការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ក្នុងករណីតុលាការយល់ថាសំណុំរឿងរក្សាការពារណាមួយមានភាពចាំបាច់ត្រូវដាក់ប្រាតិភោគ ការដាក់ប្រាតិភោគជាល័ក្ខខ័ណ្ឌនៃការចេញដីកាសម្រេចរក្សាការពារ គឺតុលាការនឹងចេញដីកាសម្រេចបង្គាប់ឱ្យដាក់ប្រាតិភោគ ដោយកំណត់អំពីអំឡុងពេលនៃការដាក់ចំនួនប្រាតិភោគ ទីកន្លែងដាក់ប្រាតិភោគ វិធីដាក់ប្រាតិភោគ និងទណ្ឌកម្ម ក្នុងករណីមិនគោរពតាមការកំណត់។ ក្នុងករណីម្ចាស់បំណុលបានអនុវត្តតាមការកំណត់របស់តុលាការ (បានដាក់ប្រាតិភោគ) តុលាការនឹងចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នតាមការស្នើសុំរបស់ម្ចាស់បំណុល។

- **ចំនួននៃប្រាតិភោគ**

ចំនួននៃប្រាតិភោគតុលាការអាចសម្រេចឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ ត្រូវពិចារណាជាមុនឱ្យបានល្អិតល្អន់លើផលប៉ះពាល់ដែលនាំឱ្យមានការខូចខាត នៅពេលតុលាការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នពាក្យសុំរបស់ម្ចាស់បំណុល ឬ លុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តាមពាក្យសុំតវ៉ារបស់កូនបំណុល។ ហេតុនេះតុលាការត្រូវវាយតម្លៃ និងពិចារណាអំពីការខូចខាតដែលនឹងកើតមានដល់កូនបំណុល ឬ ម្ចាស់បំណុលដោយផ្អែកលើមាត្រដ្ឋានមួយចំនួនដូចជា៖

(១) ការខូចខាតដែលអាចកើតមានឡើងចំពោះកូនបំណុល (បច្ចុប្បន្ន និងអនាគត)

(២) ទំហំនៃការខូចខាត

(៣) ល័ក្ខខ័ណ្ឌដែលម្ចាស់បំណុលនឹងទទួលបានរក្សាការពារ

(៤) សេចក្តីបញ្ជាក់ដំបូងរបស់ម្ចាស់បំណុល

(៥) ប្រភេទកម្មវត្ថុនៃការរក្សាការពារ (ចលនវត្ថុ អចលនវត្ថុ សិទ្ធិលើបំណុល សិទ្ធិលើទ្រព្យសម្បត្តិ ផ្សេងទៀត ឬ នាវា ជាអាទិ៍)។

មូលដ្ឋានខាងលើនេះ ជាមាត្រដ្ឋានក្នុងការពិចារណាសម្រាប់កំណត់ប្រាតិភោគ បើសេចក្តីបញ្ជាក់ដំបូងរបស់ម្ចាស់បំណុលពុំមានភាពច្បាស់លាស់ខ្លាំង ចំនួនប្រាតិភោគនឹងមានចំនួនច្រើន បើសេចក្តីបញ្ជាក់ដំបូងរបស់ម្ចាស់បំណុលមានភាពច្បាស់លាស់ខ្លាំង ចំនួនប្រាតិភោគនឹងមានចំនួនទាប និងអាស្រ័យទៅលើប្រភេទកម្មវត្ថុ បើជាអចលនវត្ថុហើយជាការរឹបអូសជាបណ្តោះអាសន្នផលប៉ះពាល់ចំពោះកូនបំណុលមានកម្រិតទាប ប៉ុន្តែបើជាចលនវត្ថុដែលធ្វើពាណិជ្ជកម្ម ដូចជារថយន្តដឹកជញ្ជូនអ្នកដំណើរ ឬរថយន្តអាជីវកម្ម នៅពេលធ្វើការរឹបអូសជាបណ្តោះអាសន្ននឹងអាចនាំឱ្យអាជីវកម្មរបស់កូនបំណុលជាប់គាំង។ ហេតុថាផលប៉ះពាល់ធ្ងន់បែបនេះជាទូទៅនឹងនាំឱ្យចំនួនប្រាតិភោគមានទំហំធំ ឬ ស្មើនឹងកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន។

នៅពេលដែលតុលាការសម្រេចឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ តុលាការក៏ត្រូវពិចារណាឱ្យបានល្អិតល្អន់លើផលប៉ះពាល់ និងឥទ្ធិពលដែលអាចនាំឱ្យមានការខូចខាតជាយថាហេតុ ដោយសារការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។ ដូច្នេះ តុលាការត្រូវសាកល្បងធ្វើការវាយតម្លៃលើការខូចខាតដោយមានការប្រយ័ត្នប្រយែងបំផុត ដែលនឹងអាចកើតមានឡើងចំពោះកូនបំណុល។ ម្យ៉ាងវិញទៀត តុលាការក៏ត្រូវគិតដល់ល័ក្ខខ័ណ្ឌសំខាន់ៗ ដែលម្ចាស់បំណុលត្រូវទទួលបានការការពារ។ បន្ទាប់ពីតុលាការពិចារណាលើការខូចខាតនាពេលអនាគត តុលាការក៏ត្រូវពិចារណាទៅដល់ការធ្វើសេចក្តីបញ្ជាក់ដំបូង។

ដូច្នេះ មុននឹងចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន គឺតុលាការគ្រាន់តែពិនិត្យលើទៅឯកសារនៃសេចក្តីបញ្ជាក់ដំបូង ឬ /និង សួរម្ចាស់បំណុល រួចបញ្ជូនដីកាសម្រេចរក្សាការពារនោះទៅឱ្យកូនបំណុល។ មានន័យថា "បើការបញ្ជាក់ដំបូងមានលក្ខណៈរឹងមាំនោះចំនួននៃប្រាតិភោគ គឺទាប ឬ តិចតួច"។ ផ្ទុយទៅវិញ "បើការបញ្ជាក់ដំបូងពុំមានលក្ខណៈរឹងមាំនោះតម្រូវការនៃការដាក់ប្រាតិភោគត្រូវមានកម្រិតខ្ពស់ ឬ ច្រើន" ។ លើសពីនេះទៅទៀតតុលាការត្រូវពិចារណាដល់ប្រភេទនៃកម្មវត្ថុនៃការចេញដីការក្សាការពារអាចជាចលនវត្ថុ អចលនវត្ថុ ឬ សិទ្ធិលើបំណុល។ ផ្អែកលើចំណុចសំខាន់ៗទាំងប៉ុន្មានខាងលើនេះទើបបង្កលក្ខណៈងាយស្រួលដល់តុលាការក្នុងការកំណត់ចំនួនប្រាតិភោគដែលតម្រូវឱ្យម្ចាស់បំណុលដាក់។

- **វិធីនៃការដាក់ប្រាតិភោគ**

ចំនួនប្រាតិភោគ ជាប្រាក់ដែលតុលាការកំណត់ជាក់លាក់ ហេតុនេះមានតែចំនួនទឹកប្រាក់ ឬ ឧបករណ៍ដែលអាចផ្គូផ្គងបាន ហើយតុលាការទទួលស្គាល់ថាសមរម្យ ឬ ទីតាំងដែលតុលាការបានកំណត់ (មាត្រា៧១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ប៉ុណ្ណោះដូចជា មូលប្បទានបត្រ ជាអាទិ៍ ទើបអាចចាត់ទុកជាការតម្កល់ប្រាតិភោគ មានន័យថា ម្ចាស់បំណុលមិនអាចយករថយន្តផ្សេងមកដាក់ធានាដោយចាត់ទុកថាជាប្រាតិភោគនោះទេ ទោះបីរថយន្តនោះ មានតម្លៃថ្លៃជាងរថយន្តដែលជាកម្មវត្ថុនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬ លើសសិទ្ធិលើបំណុលដែលត្រូវរក្សាការពាររបស់ម្ចាស់បំណុលក៏ដោយ។ វិធីដាក់ប្រាតិភោគត្រូវកំណត់ដោយប្រកាសរបស់ក្រសួងយុត្តិធម៌។

ករណីតុលាការបង្គាប់ឱ្យដាក់ប្រាតិភោគមុនពេលចេញដីកាសម្រេចរក្សាការពារ ឬ ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ការដាក់ប្រាតិភោគជាលក្ខខ័ណ្ឌមួយដើម្បីចេញដីកាសម្រេចរក្សាការពារ ឬដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននេះ។ ដូច្នេះម្ចាស់បំណុលត្រូវដាក់ប្រាតិភោគមុនចេញដីការក្សាការពារ។ ម្យ៉ាងវិញទៀត តុលាការមិនចេញដីកាសម្រេចទេរហូតដល់ប្រាតិភោគត្រូវបានដាក់។

ក្នុងករណីតុលាការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដែលភ្ជាប់ជាមួយនូវការបង្គាប់ឱ្យដាក់ប្រាតិភោគ ការដាក់ប្រាតិភោគ គឺជាលក្ខខ័ណ្ឌមួយ ដើម្បីអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដូច្នេះម្ចាស់បំណុលត្រូវដាក់ប្រាតិភោគមុនពេលអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។ ម្យ៉ាងវិញទៀត ម្ចាស់បំណុលមិនមានលទ្ធភាពក្នុងការអនុវត្តដីកាសម្រេចរក្សាការពារបានឡើយ រហូតដល់ពេលដែលខ្លួនបានដាក់ប្រាតិភោគ។

លើសពីនេះទៅទៀត ប្រាតិភោគអាចត្រូវបានដាក់ទៅតុលាការអនុវត្តការរក្សាការពារ ឬ តុលាការដែលបង្គាប់ឱ្យដាក់ប្រាតិភោគ។ ចំពោះការតម្កល់ ឬការផ្ញើ គឺជារបបមួយដែលមានករណីយកិច្ចដាក់ប្រាតិភោគ ដាក់ប្រាក់ ឬ ឧបករណ៍ដែលអាចផ្គូផ្គងបាន ដើម្បីឱ្យអ្នកមានសិទ្ធិលើប្រាតិភោគនោះ មានសិទ្ធិទាមទារយកវត្ថុដែលតម្កល់ទុកនោះបាន។

ករណីនេះ មាត្រា៧៣ កថាខណ្ឌទី១ បានចែងថា "អ្នកមានសិទ្ធិលើប្រាតិភោគក្នុងមាត្រានេះ សំដៅទៅលើបុគ្គលដែលទទួលការផ្តល់ប្រាតិភោគដើម្បីជាប្រយោជន៍របស់ខ្លួន"។ ចំពោះវិធីនៃការដាក់ប្រាតិភោគលម្អិតនឹងមានចែងនៅក្នុងសេចក្តីណែនាំរបស់ក្រសួងយុត្តិធម៌ដែលបច្ចុប្បន្នកំពុងស្ថិតនៅក្នុងសេចក្តីព្រាងនៅឡើយដែលនឹងត្រូវបញ្ចប់នាពេលដ៏ខ្លីខាងមុខនេះ។

១.៦.២ ការដាក់ប្រាក់រំដោះ

ប្រាក់រំដោះ សំដៅលើប្រាក់ដែលកូនបំណុលត្រូវផ្ញើនៅតុលាការសម្រាប់ជំនួសឱ្យទ្រព្យសម្បត្តិ ដែលជា

កម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន ដើម្បីទទួលបានការលុបចោលនូវការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន។[39]

- **គោលបំណងនៃការដាក់ប្រាក់រំដោះ**

កាលណាបើដីកាសម្រេចរក្សាការពារដែលទាក់ទងនឹងការរឹបអូសជាបណ្តោះអាសន្នបានន័យថា ការចាត់ចែងដែលកម្រិតនូវការចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បីការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ដែលមានគោលបំណងឱ្យសងជាប្រាក់ ប៉ុន្តែនៅពេលដែលបានផ្ញើប្រាក់នៃសិទ្ធិលើបំណុលដែលត្រូវបានរក្សាការពារ ឬ ចំនួនទឹកប្រាក់នៃកម្មវត្ថុដែលបានរឹបអូសជាបណ្តោះអាសន្ន ភាពចាំបាច់នៃការរឹបអូសជាបណ្តោះអាសន្នមិនមានអត្ថិភាពទៀតទេ។ ដូច្នេះ តុលាការត្រូវកំណត់នៅក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នអំពីចំនួនទឹកប្រាក់ ដែលត្រូវផ្ញើដោយកូនបំណុល ដើម្បីទទួលបាននូវការលុបចោលការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន។ គោលបំណង គឺការពារផលប្រយោជន៍របស់កូនបំណុល និងម្ចាស់បំណុល បើកូនបំណុលផ្ញើចំនួនទឹកប្រាក់ដែលបានកំណត់ដោយតុលាការ កូនបំណុលនោះ អាចរួចផុតពីការអនុវត្តរឹបអូសជាបណ្តោះអាសន្ននូវទ្រព្យដែលត្រូវរឹបអូស កូនបំណុលអាចប្រើប្រាស់ និងចាត់ចែងទ្រព្យនោះបានដោយសេរី ព្រោះការអនុវត្តរឹបអូសជាបណ្តោះអាសន្នត្រូវបានលុបចោល។ ប្រសិនបើមានការកើនឡើងតម្លៃគាត់អាចលក់បានថ្លៃ ចំពោះម្ចាស់បំណុលនឹងទទួលបាននូវការពេញចិត្តពីចំនួនទឹកប្រាក់របស់កូនបំណុលដែលនឹងត្រូវបំពេញមកដល់ខ្លួន។ ប្រាក់រំដោះសម្រាប់ជំនួសទ្រព្យដែលត្រូវបានរឹបអូសដូច្នេះប្រាក់រំដោះគឺស្ថិតនៅក្រោមការអនុវត្តរបស់ម្ចាស់បំណុល។

ដើម្បីទទួលបានប្រាក់រំដោះ ម្ចាស់បំណុលត្រូវដាក់ពាក្យបណ្តឹងអង្គសេចក្តីថ្មីមួយបន្ថែមទៀត ក្នុងករណីដែលម្ចាស់បំណុលឈ្នះបណ្តឹងអង្គសេចក្តី ដែលគាត់ទទួលបាននូវលិខិតអនុវត្ត ម្ចាស់បំណុលអាចរឹបអូសសិទ្ធិលើបំណុលខាងលើ ដើម្បីទទួលបានវិញនូវប្រាក់ដែលបានផ្ញើដោយផ្អែកលើលិខិតអនុវត្ត។ ដូច្នេះម្ចាស់បំណុលនឹងមានភាពងាយស្រួលក្នុងការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុបាន។

- **ចំនួននៃប្រាក់រំដោះ**

ចៅក្រម ជាអ្នកមានឆន្ទានុសិទ្ធិនៅក្នុងការសម្រេចពីទំហំ ឬ ចំនួននៃប្រាក់រំដោះ ដែលគ្មានមាត្រាណាមួយក្នុងក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់ច្បាស់លាស់អំពីចំនួននៃប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ននេះឡើយ។ ចំនួននៃប្រាក់រំដោះ គឺអាស្រ័យទៅលើទំហំ ឬ តម្លៃនៃទ្រព្យសម្បត្តិរបស់កូនបំណុល ដែលម្ចាស់បំណុលស្នើសុំរឹបអូសជាបណ្តោះអាសន្នលើទ្រព្យសម្បត្តិនោះ។ ម្យ៉ាងវិញទៀត តុលាការអាចយកតម្លៃនៃទ្រព្យ

[39] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤៧ កថាខណ្ឌទី១។

សម្បត្តិនោះ ធ្វើជាចំនួននៃប្រាក់រំដោះដោយសារតែប្រាក់រំដោះត្រូវចាត់ទុកជាប្រាក់ជំនួសទ្រព្យសម្បត្តិដែលត្រូវរឹបអូសជាបណ្តោះអាសន្ន។

១.៧ នីតិវិធីនៃការពិនិត្យរឿងក្តី និងការទាញហេតុផលដោយផ្ទាល់មាត់

១.៧.១ នីតិវិធីនៃការពិនិត្យរឿងក្តី

- **ការពិនិត្យភស្តុតាងជាឯកសារ**

ម្ចាស់បំណុលត្រូវបង្ហាញឯកសារសេចក្តីបញ្ជាក់ដំបូង ដើម្បីឱ្យតុលាការអាចសម្រេចថា តើសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដែលនឹងត្រូវបានរក្សាការពារមានអត្ថិភាពឬអត់ (មាត្រា៥៤១ កថាខណ្ឌទី១ ចំណុច គ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ឬ ថាតើមានភាពចាំបាច់ដើម្បីចេញដីកាសម្រេចរក្សាការពារដែរឬទេ (មាត្រា៥៤១ កថាខណ្ឌទី១ ចំណុច ឃ នៃក្រមនីតិវិធីរដ្ឋប្បវេណី)? សេចក្តីបញ្ជាក់ដំបូងត្រូវភ្ជាប់ជាមួយពាក្យសុំ ដើម្បីឱ្យតុលាការពិចារណា ដូច្នេះ ជាដំបូងតុលាការត្រូវ ពិនិត្យលើឯកសារអំពីសេចក្តីបញ្ជាក់ដំបូងដូចជា ឯកសារថតចម្លងនៃកិច្ចសន្យា ប័ណ្ណកម្មសិទ្ធិលើទ្រព្យសម្បត្តិ មូលប្បទានបត្រ មតកសាសន៍ កំណត់ហេតុ រូបថតរបាយការណ៍ដែលធ្វើឡើងដោយម្ចាស់បំណុល ឬ ឯកសារ បញ្ជាក់អំពីទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ ឬឯកសារផ្សេងទៀតដែលចាំបាច់សម្រាប់រក្សាការពារ។

- **ការសួរម្ចាស់បំណុល**

តុលាការអាចហៅម្ចាស់បំណុលមកសាកសួរយកព័ត៌មាន ដែលទាក់ទងនឹងពាក្យសុំភស្តុតាងជាឯកសាររួមមាន លិខិតបញ្ជាក់ពីសិទ្ធិលើបំណុលបានដោយឱ្យម្ចាស់បំណុលបញ្ជាក់ឱ្យបានច្បាស់លាស់ នូវគោលបំណងដែលចង់ឱ្យតុលាការចាត់ចែងរក្សាការពារ។[40] ការសាកសួរម្ចាស់បំណុលអាចឱ្យឆ្លើយជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់ ហើយតុលាការអាចអញ្ជើញម្ចាស់បំណុលមកតុលាការ និងសាកសួរម្ចាស់បំណុល ឬអាចឱ្យម្ចាស់បំណុលដាក់ឯកសារបន្ថែម។ នីតិវិធីនៃការសាកសួរម្ចាស់បំណុល គឺមិនធ្វើនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ទេ ដូច្នេះ នីតិវិធីសាកសួរម្ចាស់បំណុលមិនត្រូវធ្វើជាសាធារណៈឡើយ។ គេមិនចាំបាច់តម្រូវឱ្យមានវត្តមានភាគីទាំងពីរឡើយ ហើយតុលាការមិនត្រូវធ្វើកំណត់ហេតុទេ។ ម្យ៉ាងវិញទៀតការសួរម្ចាស់បំណុល គឺជាវិធីងាយៗសម្រាប់តុលាការក្នុងការធ្វើការបញ្ជាក់នូវខ្លឹមសារនៃពាក្យសុំ ឬ ភស្តុតាងជាឯកសារ។

- **ការសួរកូនបំណុល**

ការសម្រេចសេចក្តី ចំពោះនីតិវិធីនៃការរក្សាការពារតុលាការអាចសាកសួរកូនបំណុលបាន ផ្អែកលើមាត្រា ៥៣៥ កថាខណ្ឌទី១ មាត្រា ១១៤ កថាខណ្ឌទី២។ នីតិវិធីនៃការសាកសួរកូនបំណុល គឺដូចគ្នានឹងនីតិវិធី

[40] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៣៥ កថាខណ្ឌទី១ និងមាត្រា១១៤ កថាខណ្ឌទី២។

នៃការសាកសួរម្ចាស់បំណុលដែរ ដូច្នេះនីតិវិធីនៃការសាកសួរកូនបំណុលមិនត្រូវធ្វើជាសាធារណៈឡើយ។ គេមិនចាំបាច់តម្រូវឱ្យមានវត្តមានភាគីទាំងពីរឡើយ ហើយតុលាការមិនត្រូវធ្វើកំណត់ហេតុទេ។

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីត្រង់បទបញ្ញត្តិទូទៅ ការជំនុំជម្រះត្រូវធ្វើឡើងចំពោះមុខហើយគ្មានភាគីណាមួយត្រូវជំនុំជម្រះដោយមិនបានសាកសួរ ឬ កោះហៅឡើយ ក្នុងករណីណាក៏ដោយ តុលាការត្រូវគោរពនូវគោលការណ៍ចំពោះមុខ ក៏ប៉ុន្តែនៅក្នុងនីតិវិធីនៃការចាត់ចែងរក្សាការពារមានចរិតលក្ខណៈ ដូចជាលក្ខណៈបណ្តោះអាសន្ន បន្ទាន់បង្ខំ បន្ទាប់បន្សំ និងសម្ងាត់ ហេតុដូច្នេះហើយគេមិនសូវសាកសួរកូនបំណុលទេ ព្រោះបារម្ភខ្លាចកូនបំណុលបង្កការលំបាកដល់ការអនុវត្ត ឬ លួចបញ្ជៀសទ្រព្យសម្បត្តិដែលត្រូវចាត់ចែងរក្សាការពារ។ ប៉ុន្តែមានករណីលើកលែងមួយ នៅក្នុងករណីនៃការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ហានៈជាបណ្តោះអាសន្ន ជាគោលការណ៍ដីកាសម្រេចមិនអាចចេញបានឡើយ បើមិនឆ្លងកាត់តាមកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ តាមកាលបរិច្ឆេទនៃការសាកសួរ ដែលកូនបំណុលអាចចូលរួមបានដោយសារតែការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ហានៈជាបណ្តោះអាសន្នអាចជះឥទ្ធិពលដល់កូនបំណុល។[41] ការសាកសួរកូនបំណុល ជាវិធីមួយដែលអាចជួយការពារផលប្រយោជន៍ដល់កូនបំណុលដែរ ពេលតុលាការសាកសួរនូវព័ត៌មានមួយចំនួននោះ។ ក្នុងករណីដែលរឿងក្តីមានលក្ខណៈស្មុគស្មាញ ឬ ដីកាសម្រេចរក្សាការពារមើលទៅ ជះឥទ្ធិពលធំធេងចំពោះកូនបំណុល ឬ មានលទ្ធភាពជឿជាក់ថា ការតវ៉ានឹងអាចធ្វើឡើងដោយកូនបំណុល តុលាការអាចសាកសួរកូនបំណុលដើម្បីផ្តល់ឱកាសឱ្យកូនបំណុលធ្វើការអះអាង ឬ ដាក់ឯកសារសម្រាប់ធ្វើសេចក្តីបញ្ជាក់ដំបូង។

១.៧.២ នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់

ដើម្បីដំណើរការនីតិវិធីតុលាការអាចជ្រើសរើសនីតិវិធីពីរ គឺការសាកសួរភាគី ឬ ការទាញហេតុផលផ្ទាល់មាត់ (មាត្រា១១៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ក្នុងកិច្ចការរក្សាការពារភាគច្រើនតុលាការមិនសូវជ្រើសរើសយកការទាញហេតុផលដោយផ្ទាល់មាត់ទេ ពីព្រោះការទាញហេតុផលដោយផ្ទាល់មាត់មិនមែនជាល័ក្ខខ័ណ្ឌរបស់ច្បាប់ឡើយ។ ប៉ុន្តែ ក្នុងករណីដែលរឿងក្តីនោះមានលក្ខណៈស្មុគស្មាញដែលតុលាការគិតថាការសាកសួរភាគី និងការពិនិត្យឯកសារមិនទាន់មានលក្ខណៈគ្រប់គ្រាន់ ដើម្បីចេញដីកាសម្រេចតុលាការអាចធ្វើការទាញហេតុផលដោយផ្ទាល់មាត់បាន ពីព្រោះការសម្រេចសេចក្តីនៅក្នុងនីតិវិធីនៃការរក្សាការពារត្រូវធ្វើឡើងដោយដីកាសម្រេច ដូច្នេះ មាត្រា១១៤ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីត្រូវយកមកអនុវត្ត បើតុលាការសម្រេចជ្រើសរើសយកការទាញហេតុផលដោយផ្ទាល់មាត់នីតិវិធីនេះត្រូវធ្វើជាសាធារណៈ ដែលភាគីសងខាងអាចមានវត្តមានបានហើយត្រូវធ្វើកំណត់ហេតុ។

[41] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤៨ កថាខណ្ឌទី៤។

១.៨ ការចេញ និងការបញ្ជូនដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ

១.៨.១ ការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ

ការសម្រេចសេចក្តីលើពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវធ្វើឡើងដោយដីកាសម្រេចតាមបញ្ញត្តិមាត្រា៥៣៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ បើខ្វះលក្ខខ័ណ្ឌចាំបាច់សម្រាប់ការធ្វើបណ្តឹងដែលអនុវត្តដូចគ្នា ចំពោះនីតិវិធីនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដូចជាសមត្ថភាពភាគី និងលក្ខណៈសម្បត្តិជាភាគីនោះ ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននឹងត្រូវបានលើកចោល។ បើសិនខ្វះលក្ខខ័ណ្ឌទាមទារសម្រាប់ការរឹបអូសជាបណ្តោះអាសន្នក៏ពាក្យសុំនឹងត្រូវបានលើកចោលដែរ។ ចំពោះដីកាសម្រេចដែលលើកចោលពាក្យសុំនេះអាចប្តឹងជំទាស់បាន។ អំឡុងពេលធម្មតានៃការប្តឹងជំទាស់ គឺរយៈពេល ១ (មួយ) សប្តាហ៍ ប៉ុន្តែអំឡុងពេលនៃការប្តឹងជំទាស់នៅក្នុងករណីនេះ ត្រូវបានកំណត់ដល់ទៅ ២ (ពីរ) សប្តាហ៍ ដោយផ្អែកទៅតាមច្បាប់។

ចំណែក ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវចេញនៅពេលដែលលក្ខខ័ណ្ឌទាមទារសម្រាប់ការរឹបអូសជាបណ្តោះអាសន្ន ក៏ដូចជាលក្ខខ័ណ្ឌចាំបាច់ផ្សេងទៀតសម្រាប់ការធ្វើបណ្តឹងត្រូវបានបំពេញសព្វគ្រប់។

ចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ អាចចេញបានដោយមិនចាំបាច់កំណត់កម្មវត្ថុទេ។ តុលាការត្រូវបញ្ជូនដីកាសម្រេចរឹបអូសបណ្តោះអាសន្នទៅភាគី។[42]

១.៨.២ ការបញ្ជូនដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ

ការបញ្ជូន គឺជាការជូនដំណឹងដែលធ្វើឡើងតាមវិធីដែលច្បាប់បានកំណត់ ដើម្បីជូនដំណឹងអំពីខ្លឹមសារនៃឯកសារតាមផ្លូវបណ្តឹង ចំពោះភាគី និងអ្នកដទៃទៀតដែលមានការពាក់ព័ន្ធ និងផលប្រយោជន៍។[43] ការទទួលនូវការបញ្ជូន គឺជាការដាក់ខ្លួនក្រោមសិទ្ធិជម្រះក្តីរបស់តុលាការ ហេតុនេះហើយការធ្វើការបញ្ជូនចំពោះជនដែលមិនស្ថិតនៅក្រោមសិទ្ធិជម្រះក្តីរបស់តុលាការកម្ពុជាមិនអាចធ្វើបានទេលើកលែងក្នុងករណីដែលជននោះយល់ព្រមទទួលការបញ្ជូនដោយស្ម័គ្រចិត្ត។ ការបញ្ជូននេះត្រូវភ្ជាប់ជាមួយនូវអានុភាពគតិយុត្តផ្សេងទៀតមានដូចជាតាមរយៈការបញ្ជូននេះអំឡុងពេលដែលអាចប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បានចាប់ផ្តើមដំណើរការ។

- **ស្តាប់ឥតចាត់ចែង និងប្រតិបត្តិការបញ្ជូន**

[42] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤៣។

[43] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២, ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០, ទំព័រ១៩៤។

មន្ត្រីដែលទទួលបន្ទុកកិច្ចការបញ្ជូន គឺក្រឡាបញ្ជី។ ម្យ៉ាងទៀត មន្ត្រីដែលទទួលបន្ទុកកិច្ចការបញ្ជូនមានតួនាទី និងភារកិច្ច ដូចតទៅ៖

- ធ្វើ ឬ ផ្តល់ឯកសារបញ្ជូនទៅអ្នកប្រតិបត្តិក្នុងការបញ្ជូន
- ផ្តល់អំណាចទាក់ទងទៅនឹងការបញ្ជូន
- ទទួលរបាយការណ៍បញ្ជូនពីអ្នកប្រតិបត្តិក្នុងការបញ្ជូន
- យករបាយការណ៍បញ្ជូនទៅឱ្យចៅក្រមពិនិត្យមើលថាតើត្រឹមត្រូវដែរឬទេ
- យករបាយការណ៍បញ្ជូនដាក់ទុកក្នុងសំណុំរឿង។

ម្យ៉ាងវិញទៀត តួនាទី និងភារកិច្ចរបស់អ្នកប្រតិបត្តិក្នុងការបញ្ជូនគឺ ៖

- បញ្ជូនឯកសារទៅឱ្យបុគ្គលដែលត្រូវទទួលការបញ្ជូន
- ធ្វើរបាយការណ៍ទាក់ទងទៅនឹងការបញ្ជូន
- បញ្ជូនរបាយការណ៍ទៅតុលាការដើមវិញ។

មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនមាន មន្ត្រីប៉ុស្តិ៍ប្រៃសណីយ៍ អាជ្ញាសាលា ក្រឡាបញ្ជីជាដើម។[44] ឯកសារដែលត្រូវបញ្ជូន ជាឯកសារថតចម្លងលើកលែងតែករណីដែលបានកំណត់ពិសេសដោយច្បាប់។

- **ការបញ្ជូនទៅបុគ្គលដែលអសមត្ថភាពក្នុងបណ្តឹង**

បុគ្គលដែលអសមត្ថភាព មានអនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមហិបត្តម្ភ។ ការបញ្ជូនរបស់បុគ្គលទាំង ៣ (បី) នេះ គឺអ្នកប្រតិបត្តិការបញ្ជូនត្រូវបញ្ជូនទៅឱ្យអ្នកតំណាងស្របច្បាប់របស់បុគ្គលដែលអសមត្ថភាពនោះ ដែលក្នុងនោះមានដូចជា ចំពោះអនីតិជន អ្នកប្រតិបត្តិការបញ្ជូនត្រូវបញ្ជូនឯកសារទៅឱ្យអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលរបស់អនីតិជន។ បើជាជននៅក្រោមអាណាព្យាបាលទូទៅវិញ ការបញ្ជូនត្រូវបញ្ជូនទៅឱ្យអ្នកអាណាព្យាបាលទូទៅ។ ក្នុងករណីអ្នកទទួលការបញ្ជូន ជាជននៅក្រោមហិបត្តម្ភវិញ អ្នកប្រតិបត្តិការបញ្ជូនត្រូវបញ្ជូនទៅឱ្យហិតូបត្តម្ភក:។ លើកលែងតែក្នុងករណី អនីតិជនដែលទទួលបានអត្តាធីនភាព និងអនីតិជនដែលទទួលបានការយល់ព្រមពីអ្នកមានអំណាចមេបា ការបញ្ជូន គឺបញ្ជូនទៅកាន់បុគ្គលនោះផ្ទាល់។

- **វិធីនៃការបញ្ជូន**

វិធីនៃការបញ្ជូនមានដូចជា ការបញ្ជូនដោយការប្រគល់ ការបញ្ជូនដោយការជួបប្រទះ ការបញ្ជូនដោយបង្គ្រប់កិច្ច ការបញ្ជូនដោយទុកចោល ការបញ្ជូនទៅបរទេស និងការបញ្ជូនតាមការផ្សាយជាសាធារណៈ។

[44] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា២៤៦ កថាខណ្ឌទី៣។

- **ការបញ្ជូនដោយប្រគល់**

ជាគោលការណ៍ ត្រូវប្រគល់ឯកសារទៅឱ្យជនដែលត្រូវទទួលការបញ្ជូននោះ ការបញ្ជូនត្រូវបញ្ជូនទៅលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការរបស់ជនដែលនឹងត្រូវទទួលការបញ្ជូន។ លំនៅឋានគឺជាកន្លែងដែល ជាទីតាំងជីវភាពរស់នៅរបស់បុគ្គលម្នាក់ៗ ចំណែកឯទីសំណាក់ គឺក្នុងករណីដែលកន្លែងដែលជាទីតាំងនៃជីវភាពរស់នៅមិនច្បាស់លាស់នោះទេ ទីសំណាក់ត្រូវចាត់ទុកជាលំនៅឋាន។ ចំពោះការបញ្ជូនទៅអ្នកតំណាងដែលច្បាប់បានកំណត់ អាចធ្វើការបញ្ជូនទៅទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការរបស់អ្នកតំណាងបាន។

- **ការបញ្ជូនដោយជួបប្រទះ**

ប្រសិនបើជនដែលត្រូវទទួលការបញ្ជូនពុំច្បាស់លាស់ថាមានលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ការបញ្ជូនអាចធ្វើបាននៅកន្លែងដែលជួបប្រទះជននោះលើកលែង តែក្នុងករណីដែលមានការជូនដំណឹងអំពីទីកន្លែងដែលត្រូវធ្វើការបញ្ជូននោះ។ ទោះបីជាបានដឹងពីលំនៅឋាន ទីសំណាក់ ឬ កន្លែងដែលត្រូវធ្វើការបញ្ជូនក៏ដោយ ប្រសិនបើបុគ្គលដែលត្រូវធ្វើការបញ្ជូនពុំបានតវ៉ាដូច្នេះ អ្នកប្រតិបត្តិក្នុងការបញ្ជូនអាចធ្វើការបញ្ជូនទៅទីកន្លែងដែលជួបប្រទះ។ ការបញ្ជូនបែបនេះ គេហៅថាការបញ្ជូនដោយជួបប្រទះ។[45]

- **ការបញ្ជូនដោយបង្គ្រប់កិច្ច**

ក្នុងករណីដែលអ្នកប្រតិបត្តិក្នុងការបញ្ជូនធ្វើការបញ្ជូនទៅលំនៅឋាន ឬ ទីសំណាក់របស់បុគ្គលដែលត្រូវទទួលការបញ្ជូន ប៉ុន្តែបុគ្គលដែលត្រូវទទួលការបញ្ជូននោះអវត្តមាន ដូច្នេះ អ្នកប្រតិបត្តិការបញ្ជូនអាចធ្វើការប្រគល់ឯកសារនោះទៅកាន់បុគ្គលដែលមានវត្តមាននៅទីកន្លែងនោះ អាចជាអ្នកបម្រើ ឬ អ្នកផ្សេងទៀតដែលធ្វើការនៅទីនោះ ឬ អ្នកនៅជាមួយ ដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារនោះបាន។ ការបញ្ជូនបែបនេះ គឺហៅថាការបញ្ជូនដោយបង្គ្រប់កិច្ច។[46]

- **ការបញ្ជូនដោយទុកចោល**

ប្រសិនបើជនដែលត្រូវទទួលការបញ្ជូន ឬ អ្នកដែលត្រូវទទួលការបញ្ជូនដោយបង្គ្រប់កិច្ចនោះពុំព្រមទទួលយកឯកសារនោះ ដោយគ្មានមូលហេតុត្រឹមត្រូវ ដូច្នេះ អ្នកប្រតិបត្តិការបញ្ជូនអាចទុកឯកសារនោះចោលនៅចំពោះមុខបុគ្គលនោះបាន។ ការបញ្ជូនបែបនេះគេហៅថាការបញ្ជូនដោយទុកចោល។[47]

---

[45] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា២៥១។

[46] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា២៥២ កថាខណ្ឌទី១។

[47] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា២៥២ កថាខណ្ឌទី២។

- **ការបញ្ជូនទៅបរទេស**

យោងតាមមាត្រា ២៥៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ក្នុងករណីដែលបុគ្គលដែលត្រូវទទួលការបញ្ជូនពុំមានលំនៅឋាន ទីសំណាក់ ឬ លំនៅឋានចុងក្រោយនៅព្រះរាជាណាចក្រកម្ពុជាការបញ្ជូនត្រូវធ្វើតាមល័ក្ខខ័ណ្ឌដូចតទៅ៖

- ចំពោះជនបរទេសតុលាការត្រូវប្រគល់ភារកិច្ចទៅឱ្យក្រសួង ឬ ស្ថាប័ន ដែលមានសមត្ថកិច្ចនៅប្រទេសនោះ
- ករណីជនជាតិខ្មែរនៅបរទេស តុលាការត្រូវប្រគល់កិច្ចការបញ្ជូនទៅឱ្យអគ្គរាជទូត ឬ ភារធារីកុងស៊ុលរបស់ព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះឱ្យធ្វើការបញ្ជូនបាន
- ប្រសិនបើជនបរទេសដែលនៅព្រះរាជាណាចក្រកម្ពុជាត្រូវអនុវត្តវិធីនៃការបញ្ជូនដូចនឹងជនជាតិខ្មែរដែរ

- **ការបញ្ជូនតាមការផ្សាយជាសាធារណៈ**

ការបញ្ជូនតាមការផ្សាយជាសាធារណៈមានល័ក្ខខ័ណ្ឌដូចខាងក្រោម៖ [48]

- ក្នុងករណីដែលបានខិតខំប្រឹងប្រែងស្រាវជ្រាវរកយ៉ាងណានៅតែមិនដឹងពីទីកន្លែងដែលត្រូវបញ្ជូន
- ករណីដែលបានដឹងពីទីកន្លែងដែលត្រូវបញ្ជូនតែការបញ្ជូនមិនអាចធ្វើទៅបាន ទោះបីព្យាយាមបញ្ជូនតាមរបៀបនៃការបញ្ជូនបង្គ្រប់កិច្ចនិងការបញ្ជូនដោយធ្វើការទុកចោលក៏ដោយ
- ករណីដែលមិនអាចធ្វើការបញ្ជូនទៅបរទេសបាន
- ករណីដែលតុលាការមិនអាចទទួលលិខិតបញ្ជាក់ពីការបញ្ជូនពីក្រសួងឬ ស្ថាប័នដែលមានសមត្ថកិច្ចនៅបរទេសក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែគិតចាប់ពីពេលបញ្ជូន។

ដើម្បីធ្វើការផ្សាយជាសាធារណៈមានតែពាក្យសុំរបស់ភាគីដែលស្នើសុំឱ្យតុលាការធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ និងបន្ទាប់ពីបានទទួលការអនុញ្ញាតដោយតុលាការ ក៏ប៉ុន្តែតុលាការក៏អាចបង្គាប់ឱ្យក្រឡាបញ្ជីធ្វើការបញ្ជូនតាមរយៈការផ្សាយជាសាធារណៈបានដោយឆន្ទានុសិទ្ធិរបស់ខ្លួនផងដែរ បើទោះបីជាគ្មានពាក្យសុំពីភាគីក៏ដោយ ចំពោះករណីដែលតុលាការយល់ឃើញថាជាករណីចាំបាច់។ [49]

ប្រសិនបើការបញ្ជូនតាមការផ្សាយជាសាធារណៈនោះ ត្រូវបានធ្វើក្នុងករណីដែលល័ក្ខខ័ណ្ឌដែលការបញ្ជូនដោយបង្គ្រប់កិច្ច និងការបញ្ជូនដោយទុកចោលត្រូវបានបំពេញ ហើយតែនៅតែមិនអាចបញ្ជូនទៅដល់ជនដែលត្រូវទទួលការបញ្ជូននោះបានក្រឡាបញ្ជីគប្បីជូនដំណឹងដោយរបៀបសមរម្យតាមរយៈទូរស័ព្ទផ្ញើតាមប៉ុស្តិ៍ប្រៃសនីយ៍

[48] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា២៥៦។

[49] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា២៥៥។

ឬ បិទតាមលំនៅឋាន ទីសំណាក់របស់ជនដែលត្រូវទទួលការបញ្ជូន ជាដើម។

ជាងនេះទៅទៀត ការបញ្ជូនជាសាធារណៈមានអានុភាពនៅក្រោយអំឡុងពេល ២ (ពីរ) សប្តាហ៍ដោយគិតចាប់ពីថ្ងៃដែលបានបិទប្រកាស។[50] ការបញ្ជូនតាមការផ្សព្វផ្សាយជាសាធារណៈ ដែលត្រូវធ្វើនៅបរទេសវិញ នឹងមានអានុភាពជាការបញ្ជូននៅក្រោយអំឡុងពេល ៦ (ប្រាំមួយ) សប្តាហ៍បន្ទាប់ពីការបិទប្រកាស។ អានុភាពនៅទីនេះមានន័យថាការបញ្ជូនត្រូវបានប្រតិបត្តិការណ៍ និងត្រូវចាត់ទុកថាអ្នកដែលទទួលការបញ្ជូនបានទទួលការបញ្ជូននេះ។

ផ្នែកទី២ នីតិវិធីនៃការអនុវត្តការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ

ក្រោយពីតុលាការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នតាមពាក្យសុំរបស់ម្ចាស់បំណុល ហើយម្ចាស់បំណុលអាចដាក់ពាក្យសុំអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ទៅតុលាការដែលមានសមត្ថកិច្ចអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននោះដោយផ្អែកលើប្រភេទ និងកម្មវត្ថុនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននីមួយៗ និងយកឯកសារចម្លងយថាភូតទៅអនុវត្តដោយមិនចាំបាច់ភ្ជាប់រូបមន្តអនុវត្តទេ។

ការដាក់ពាក្យសុំ ម្ចាស់បំណុលត្រូវដាក់ចូលទៅតុលាការមានសមត្ថកិច្ចអនុវត្តរក្សាការពារជាតុលាការដែលត្រូវអនុវត្តការចាត់ចែងរក្សាការពារត្រូវហៅថា តុលាការអនុវត្តការរក្សាការពារ (មាត្រា៥៣២ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦) និងអាស្រ័យទៅតាមកម្មវត្ថុនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននោះ។

២.១ ស្ថាប័នមានសមត្ថកិច្ច

ស្ថាប័នមានសមត្ថកិច្ចក្នុងការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ គឺអាជ្ញាសាលា។ ការរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ ត្រូវធ្វើតាមរបៀបកាន់កាប់វត្ថុដែលជាកម្មវត្ថុ ដោយអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលជាកម្មវត្ថុស្ថិតនៅ។[51]

២.២ ការដាក់ពាក្យសុំអនុវត្ត

ពាក្យសុំឱ្យអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ត្រូវតែធ្វើជាលាយលក្ខណ៍អក្សរមិនអាចធ្វើដោយផ្ទាល់មាត់បានទេ។

២.២.១ ចំណុចដែលត្រូវសរសេរក្នុងពាក្យសុំអនុវត្តដីកាសម្រេច

ចំណុចដែលត្រូវសរសេរ ក្នុងពាក្យសុំអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុត្រូវមានបញ្ជាក់នូវចំណុចដូចខាងក្រោមនេះ ហើយត្រូវភ្ជាប់ជាមួយនឹងលិខិតចម្លងយថាភូតនៃលិខិតអនុវត្ត ដែលមានអានុភាពអនុវត្ត :

[50]ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា២៥៧។

[51] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៦៥ កថាខណ្ឌទី១។

ក-ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

ខ-សញ្ញាណនៃលិខិតអនុវត្ត។

គ-សេចក្តីសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់ ឬ ការអនុវត្តជំនួស ឬ វិធានបង្ខំដោយប្រយោល។

ឃ-សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និងវិធីអនុវត្តដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្តសុំ ក្នុងករណីដែលសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់។

ង-ខ្លឹមសារនៃសេចក្តីសម្រេចដែលម្ចាស់បំណុលសុំ ក្នុងករណីដែលសុំឱ្យអនុវត្តដោយបង្ខំតាមការអនុវត្តជំនួស ឬ វិធានបង្ខំដោយប្រយោល។[52]

នៅក្នុងពាក្យសុំឱ្យអនុវត្តចំពោះចលនវត្ថុត្រូវសរសេរអំពីទីកន្លែងដែលចលនវត្ថុដែលត្រូវរឹបអូសជាបណ្តោះអាសន្ននោះស្ថិតនៅ។[53]

២.២.២ ឯកសារដែលត្រូវភ្ជាប់ជាមួយពាក្យសុំដីកាសម្រេច

- **លិខិតចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន**

ករណីនេះម្ចាស់បំណុលពុំចាំបាច់ស្នើសុំរូបមន្តអនុវត្ត។ មូលហេតុដែលច្បាប់មិនតម្រូវឱ្យមានរូបមន្តអនុវត្ត ព្រោះការរឹបអូសជាបណ្តោះអាសន្នជាបញ្ហាបន្ទាន់បង្ខំ ដូច្នេះ នីតិវិធីគប្បីត្រូវបានអនុវត្តយ៉ាងលឿនបំផុតដែលអាចធ្វើទៅបាន។ មូលហេតុផ្សេងទៀត គឺដោយសារដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវបានអនុវត្តលុះត្រាតែមានពាក្យសុំពីភាគី ហើយដីកានេះត្រូវអនុវត្តក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ។[54] ប៉ុន្តែ បើសិនជាការអនុវត្តចំពោះ ឬ សម្រាប់ជនក្រៅពីភាគីដែលត្រូវកំណត់នៅក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវធ្វើឡើងដោយភ្ជាប់រូបមន្តអនុវត្ត។

- **លិខិតបញ្ជាក់អំពីអ្នកតំណាងដោយអាណត្តិ**

កាលណាម្ចាស់បំណុលសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន បានផ្តល់សិទ្ធិអំណាចឱ្យអ្នកតំណាងដោយអាណត្តិ សិទ្ធិអំណាចនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ[55] ប៉ុន្តែបើមានបណ្តឹងអង្គសេចក្តី

[52] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៦៤។

[53] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៣៨៤ កថាខណ្ឌទី២។

[54] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៦២ កថាខណ្ឌទី២។

[55] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៣ កថាខណ្ឌទី២។

ហើយមានលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរួចហើយ សិទ្ធិតំណាងនេះក៏អាចធ្វើសកម្មភាពចំពោះការចាត់ចែងរក្សាការពារបានដែរ[56] គ្រាន់តែធ្វើការចម្លងឯកសារផ្លូវការរួចភ្ជាប់មកជាមួយពាក្យសុំអនុវត្តតែម្តង។

២.៣ ការពិនិត្យពាក្យសុំ និងលក្ខខ័ណ្ឌចាំបាច់

២.៣.១ ការពិនិត្យពាក្យសុំ

ពាក្យសុំឱ្យអនុវត្តដីកា គឺត្រូវធ្វើជាលាយលក្ខណ៍អក្សរ។ ដូច្នេះ នៅពេលដែលតុលាការអនុវត្តបានទទួលពាក្យសុំឱ្យអនុវត្តដីកាសម្រេចរឹបអូសបណ្តោះអាសន្ន តុលាការត្រូវពិនិត្យថា តើពាក្យសុំឱ្យអនុវត្តដីការឹបអូសបណ្តោះអាសន្ននេះ ស្របនឹងលក្ខខ័ណ្ឌនៃរបៀបដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំឬទេ តាមមាត្រា៥៦៤ និងមាត្រា ៣៤៩ កថាខណ្ឌទី ២ ដូចជាឈ្មោះ និងអាសយដ្ឋានរបស់កូនបំណុលនៃការអនុវត្ត សញ្ញាណនៃលិខិតអនុវត្ត សេចក្តីស្នើសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់ និងសញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និងវិធីអនុវត្តដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្តសុំ។ ក្រៅពីនេះ តុលាការអនុវត្តត្រូវពិនិត្យផងដែរនូវឯកសារភ្ជាប់ដូចជា លិខិតចម្លងយថាភូតនៃដីកាសម្រេចរក្សាការពារ លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ បញ្ជីឈ្មោះភាគី។

២.៣.២ ការពិនិត្យលើលក្ខខ័ណ្ឌចាំបាច់

បន្ទាប់ពីបានពិនិត្យលើរបៀបនៃការដាក់ពាក្យសុំឱ្យអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ហើយតុលាការអនុវត្តត្រូវពិនិត្យលើលក្ខខ័ណ្ឌចាំបាច់នៃការអនុវត្តដីការឹបអូសជាបណ្តោះអាសន្ន ព្រោះថាបើមិនបានបំពេញនូវលក្ខខ័ណ្ឌទាំងនោះទេ គឺការអនុវត្តដីការក្សាការពារមិនអាចធ្វើបានឡើយ។

- **លិខិតយថាភូតនៃដីកាសម្រេច**

លិខិតយថាភូតនៃដីកាសម្រេចតុលាការត្រូវពិនិត្យថា តើឈ្មោះភាគីដែលមាននៅក្នុងពាក្យសុំឱ្យអនុវត្តនោះ ដូចគ្នានឹងឈ្មោះភាគី ដែលមាននៅក្នុងដីកាសម្រេចរក្សាការពារដែរឬទេ។ បើឈ្មោះដូចគ្នា គឺការអនុវត្តដីកាសម្រេចរក្សាការពារត្រូវធ្វើឡើងដោយផ្អែកតែលើឯកសារចម្លងលិខិតយថាភូតនៃដីកាសម្រេចរក្សាការពារប៉ុណ្ណោះ។ ប៉ុន្តែ បើឈ្មោះភាគីមិនដូចគ្នាទេ គឺការអនុវត្តដីកាសម្រេចរក្សាការពារត្រូវធ្វើឡើងដោយផ្អែកលើឯកសារចម្លងលិខិតយថាភូតនៃដីកាសម្រេចរក្សាការពារដែលភ្ជាប់នឹងរូបមន្តអនុវត្ត។[57]

[56] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤ កថាខណ្ឌទី២។

[57] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៦២ កថាខណ្ឌទី១។

- **អំឡុងពេល**

បើអំឡុងពេល០២សប្តាហ៍មិនទាន់កន្លងហួស ចាប់ពីថ្ងៃដែលដីកាសម្រេចរក្សាការពារត្រូវបានបញ្ជូនទៅម្ចាស់បំណុល។ ដូច្នេះ បើម្ចាស់បំណុលបានទទួលដីកាសម្រេចរក្សាការពាររួចហើយ មិនបានដាក់ពាក្យសុំឱ្យអនុវត្តរក្សាការពារនោះ ក្នុងអំឡុងពេល០២សប្តាហ៍ទេ គឺដីកាសម្រេចនោះនឹងគ្មានអានុភាពដើម្បីអនុវត្តនោះទេ។[58]

ក្នុងករណីដែលតុលាការចេញដីកាសម្រេចរក្សាការពារដោយឱ្យដាក់ប្រាតិភោគ។ ប្រាតិភោគនេះ ជាលក្ខខ័ណ្ឌមួយសម្រាប់ការអនុវត្តដីកាសម្រេចរក្សាការពារ។ ដូច្នេះ តុលាការត្រូវពិនិត្យមើលថា តើប្រាតិភោគត្រូវបានដាក់រួចហើយ ឬ មិនទាន់ដាក់។[59]

២.៤ វិធីនៃការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន

ក្នុងករណីដែលតុលាការអនុវត្តរកឃើញនូវលក្ខខ័ណ្ឌចាំបាច់ផ្សេងៗ ត្រូវបានបំពេញតុលាការអនុវត្តនោះត្រូវធ្វើនីតិវិធីអនុវត្តដីកាសម្រេចរក្សាការពារនោះ។

ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ជាមូលដ្ឋានត្រូវធ្វើទៅតាមការអនុវត្តការរឹបអូសនៅក្នុងករណីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យសងជាប្រាក់ដែរ។ ប៉ុន្តែជាគោលការណ៍ ការអនុវត្តនេះមិនឈានចូលទៅដល់ដំណាក់កាលនៃការប្តូរជាប្រាក់ទេ។ នៅគ្រប់ករណីទាំងអស់ ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ចាប់ផ្តើមដោយការដាក់ពាក្យសុំរបស់ម្ចាស់បំណុលទៅស្ថាប័នអនុវត្ត។[60]

ការអនុវត្តរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ ត្រូវធ្វើឡើងតាមរបៀបកាន់កាប់វត្ថុដែលជាកម្មវត្ថុដោយអាជ្ញាសាលានៃសាលាដំបូង ដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលជាកម្មវត្ថុនោះស្ថិតនៅ។

នីតិវិធីនេះជាមូលដ្ឋានត្រូវធ្វើតាមវិធីដូចគ្នាទៅនឹងការរឹបអូសនៅក្នុងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុដែរ (មាត្រា ៥៦៥ កថាខណ្ឌទី ៤ មាត្រា ៣៨៤ កថាខណ្ឌទី ២ និង បញ្ញត្តិចាប់ពីមាត្រា ៣៨៥ ដល់មាត្រា ៣៩២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦)។ ក្នុងករណីដែលកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន គឺជាប្រាក់ អាជ្ញាសាលាមិនដកហូតទុក ឬ ឱ្យកូនបំណុលរក្សាទុកប្រាក់នោះទេ[61] តែអាជ្ញាសាលាត្រូវធ្វើប្រាក់នោះ នៅតុលាការដែលខ្លួនស្ថិតនៅ។[62] វត្ថុផ្សេងទៀតក្រៅពីប្រាក់ត្រូវដកហូត និងរក្សាទុកដោយអាជ្ញាសាលា។ ក៏ប៉ុន្តែប្រសិនបើមានការបារម្ភថា ចលនវត្ថុដែលត្រូវបានរឹបអូសជាបណ្តោះអាសន្ននោះនឹងចុះតម្លៃយ៉ាងខ្លាំង ឬ បើ

[58] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៦២ កថាខណ្ឌទី២។

[59] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤២។

[60] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៦៥ កថាខណ្ឌទី១។

[61] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៣៨៥ កថាខណ្ឌទី១ និង កថាខណ្ឌទី៤។

[62] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៦៥ កថាខណ្ឌទី២។

ត្រូវការសោហ៊ុយច្រើនហួសហេតុដើម្បីរក្សាទុកចលនវត្ថុនោះ អាជ្ញាសាលាអាចលក់ចលនវត្ថុនោះ តាមនីតិវិធីនៃការលក់នៅក្នុងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុបាន តាមពាក្យសុំរបស់ម្ចាស់បំណុល ឬ កូនបំណុល (មាត្រា ៥៦៥ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦)។[63] នៅក្នុងករណីនេះ ប្រាក់ដែលទទួលបានពីការលក់ត្រូវយកទៅផ្ញើនៅតុលាការដែលអាជ្ញាសាលានោះស្ថិតនៅ។ មាត្រា ៣៨៧ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះរថយន្ត ឬ ទោចក្រយានយន្តដែលត្រូវបានចុះបញ្ជី។មានន័យថា អាជ្ញាសាលាដែលធ្វើការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ត្រូវផ្តុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចសរសេរនូវហេតុការណ៍នៃការរឹបអូសជាបណ្តោះអាសន្នចូលទៅក្នុងសៀវភៅបញ្ជី ហើយការរឹបអូសជាបណ្តោះអាសន្ននោះនឹងត្រូវមានអានុភាពនៅពេលដែលបានសរសេរចូលក្នុងសៀវភៅបញ្ជីនោះ។

- **ការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុដែលកូនបំណុលអនុវត្តកាន់កាប់**

ក្នុងករណីនេះអាជ្ញាសាលាអាចរឹបអូសបណ្តោះអាសន្នចំពោះចលនវត្ថុនោះ ដោយផ្អែកទៅលើរូបភាពខាងក្រៅនៃកាន់កាប់របស់កូនបំណុលតែប៉ុណ្ណោះ ដោយមិនចាំបាច់ស្រាវជ្រាវព័ត៌មានអំពីកម្មសិទ្ធិចលនវត្ថុនោះឡើយ។ ប៉ុន្តែ ប្រសិនជាចលនវត្ថុនោះមិនមែនជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត អាជ្ញាសាលាមិនអាចធ្វើបានការរឹបអូសចលនវត្ថុដែលជាកម្មសិទ្ធិរបស់អ្នកដទៃបានទេ។ **ឧទាហរណ៍៖** សៀវភៅដែលមានបិទស្លាករបស់បណ្ណាល័យសៀវភៅ។

នៅពេលធ្វើការរឹបអូសចលនវត្ថុរបស់កូនបំណុលនៃការអនុវត្តដែលកាន់កាប់នោះ អាជ្ញាសាលាអាចរឹបអូសចលនវត្ថុដោយធ្វើការកាន់កាប់ចលនវត្ថុនោះបាន។ ម៉្យាងវិញទៀត អាជ្ញាសាលាអាចចូលទៅក្នុងកន្លែងរស់នៅរបស់កូនបំណុលនៃការអនុវត្ត ឬ កន្លែងផ្សេងទៀត និងអាចធ្វើការឆែកឆេរស្វែងរកចលនវត្ថុដែលអាចរឹបអូសបាន ប្រសិនជាមានការចាំបាច់ អាជ្ញាសាលាអាចចាត់ចែង បើកទ្វារដែលបិទ ទូដែក ឬ ប្រអប់ផ្សេងទៀតបាន។

អំឡុងពេលជ្រើសរើសចលនវត្ថុដែលត្រូវនឹងរឹបអូសអាជ្ញាសាលាក៏ត្រូវគិតពិចារណាដល់ផលប្រយោជន៍របស់កូនបំណុលនៃការអនុវត្ត។ ប៉ុន្តែ ក៏ត្រូវគិតពីផលប្រយោជន៍របស់ម្ចាស់បំណុលនៃការអនុវត្តដូចគ្នាដែរ។[64]

ជាគោលការណ៍ អាជ្ញាសាលាជាអ្នកកាន់កាប់ចលនវត្ថុដែលបានរឹបអូសដោយផ្ទាល់ ប៉ុន្តែមានករណីលើកលែង គឺអាជ្ញាសាលាអាចអនុញ្ញាតទុកចលនវត្ថុដែលបានរឹបអូសនៅកូនបំណុលនៃការអនុវត្ត ជាអ្នកថែរក្សាគ្រប់គ្រងនិងអាចប្រើប្រាស់បាន ប្រសិនជាចលនវត្ថុដែលបានរឹបអូសនោះពិបាកថែរក្សា ឬ មានបញ្ហាច្រើន ឬ ត្រូវចំណាយពេលច្រើនក្នុងការដឹកជញ្ជូន ប៉ុន្តែចលនវត្ថុរឹបអូសនោះត្រូវបានបិទស្លាក ឬ ដាក់សញ្ញារឹបអូស

[63] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៦៥ កថាខណ្ឌទី៣។

[64] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៣៨៥ កថាខណ្ឌទី៣។

ដោយវិធីផ្សេងទៀត។ ម៉្យាងវិញទៀត ប្រសិនជាមានការចាំបាច់ត្រូវគ្រប់គ្រងថែរក្សាចលនវត្ថុវិញដោយអាជ្ញាសាលាខ្លួនឯងវិញ គឺអាជ្ញាសាលាអាចលុបចោលនូវការអនុញ្ញាតនោះបាន។[65]

- **ការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុដែលម្ចាស់បំណុលកាន់កាប់**

ក្នុងករណីម្ចាស់បំណុលខ្លួនឯងជាអ្នកកាន់កាប់ចលនវត្ថុរបស់កូនបំណុល ម្ចាស់បំណុលនៃការអនុវត្តដែលមានទ្រព្យសម្បត្តិរបស់កូនបំណុលជាកម្មវត្ថុសិទ្ធិឃាត់ទុក និងកម្មវត្ថុនៃការបញ្ឆើចលនវត្ថុ ម្ចាស់បំណុលអាចប្រគល់វត្ថុទាំងនោះដោយស្ម័គ្រចិត្តឱ្យទៅអាជ្ញាសាលាដើម្បីធ្វើការរឹបអូស។

- **ការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុដែលតតិយជនកាន់កាប់ ឬ បុគ្គលផ្សេងក្រៅពីកូនបំណុលនៃការអនុវត្ត**

ករណីដែលតតិយជនកាន់កាប់ ឬ បុគ្គលផ្សេងក្រៅពីកូនបំណុលនៃការអនុវត្តកាន់កាប់ចលនវត្ថុ អាជ្ញាសាលា អាចរឹបអូសបណ្តោះចលនវត្ថុបានតែក្នុងករណីតតិយជនអនុញ្ញាតឱ្យរឹបអូស ប្រសិនជាតតិយជនមិនអនុញ្ញាតនោះទេ អាជ្ញាសាលាក៏មិនអាចអនុវត្តសមត្ថកិច្ចរបស់ខ្លួនដោយរឹបអូសដោយបង្ខំនូវចលនវត្ថុដែលកាន់កាប់ដោយអ្នកផ្សេងបានទេ ពីព្រោះនៅក្នុងលិខិតអនុវត្តមានតែឈ្មោះរបស់ម្ចាស់បំណុល និងកូនបំណុលនៃការអនុវត្តតែប៉ុណ្ណោះ។ ផ្ទុយមកវិញ ម្ចាស់បំណុលអាចស្នើសុំទាមទារឱ្យប្រគល់ចលនវត្ថុ ដែលតតិយជនមានលើកូនបំណុលនៃការអនុវត្ត ហើយប្រសិនជាតតិយជនមិនព្រមប្រគល់ចលនវត្ថុដែលនឹងត្រូវរឹបអូសនោះ គឺគ្មានជម្រើសអ្វីក្រៅពីធ្វើការរឹបអូសសិទ្ធិទាមទារឱ្យសង ឬ សិទ្ធិទាមទារឱ្យប្រគល់វត្ថុដែលកូនបំណុលមានចំពោះតតិយជន តាមរយៈការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ហើយម្ចាស់បំណុលត្រូវប្រមូលយកវត្ថុ ឬ ប្រគល់វត្ថុទាំងនោះទៅឱ្យអាជ្ញាសាលាជាអ្នកកាន់កាប់។ ម៉្យាងវិញទៀតក្រៅពីការរឹបអូសចលនវត្ថុដែលជារថយន្ត ឬ ទោចក្រយានដែលត្រូវរឹបអូសមានចុះបញ្ជីក្នុងសៀវភៅចុះបញ្ជីអាជ្ញាសាលា ត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចសរសេរហេតុការណ៍នៃការរឹបអូសចូលទៅក្នុងសៀវភៅចុះបញ្ជី។[66]

២.៥ ការផ្អាក និងការលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន

ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន អាចត្រូវបានផ្អាកក្នុងលក្ខណៈជាការផ្អាកការអនុវត្ត ដោយសារមានពាក្យសុំតវ៉ា ឬ ពាក្យសុំទាមទារឱ្យលុបចោលនូវដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន និងពាក្យបណ្តឹងជំទាស់ចំពោះដីកាសម្រេចអំពីពាក្យសុំតវ៉ា ឬ ពាក្យសុំលុបចោលនោះ ការផ្អាកការអនុវត្តដោយសារមានការតវ៉ាចំពោះការអនុវត្ត និងដោយសារមានការដាក់ពាក្យបណ្តឹងជំទាស់, ការផ្អាកការអនុវត្តដោយសារមានបណ្តឹងតវ៉ារបស់

[65] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៣៨៥ កថាខណ្ឌទី៦។

[66] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៣៨៧។

តតិយជនជាអាទិ៍។ ប៉ុន្តែយ៉ាងណាក៏ដោយខុសប្លែកអំពីការអនុវត្តដោយបង្ខំ ការផ្អាកនៅក្រោយការអនុវត្តមិនសូវមានអត្ថន័យទេ ព្រោះថាការអនុវត្តរឹបអូសជាបណ្តោះអាសន្នត្រូវបានបញ្ចប់នៅត្រឹមដំណាក់កាលនៃការរឹបអូសតែប៉ុណ្ណោះ។

ស្រដៀងគ្នាទៅនឹងករណីនៃការអនុវត្តដោយបង្ខំដែរ ការលុបចោលនូវការចាត់ចែងការអនុវត្តរឹបអូសជាបណ្តោះអាសន្នអាចធ្វើទៅបាន (មាត្រា ៣៦៧ កថាខណ្ឌទី ២, មាត្រា ៣៧០ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦) ។ បន្ថែមពីនេះ ប្រព័ន្ធនៃការលុបចោលការចាត់ចែងការអនុវត្តរឹបអូសជាបណ្តោះអាសន្នដោយការធ្វើប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន។[67] ទោះបីជាបណ្តឹងជំទាស់ អាចធ្វើបានចំពោះដីកាសម្រេចលុបចោលក៏ដោយ ក៏ត្រូវគិតពិចារណាទៅលើភាពច្បាស់លាស់នៃលក្ខខ័ណ្ឌនៃការសម្រេចសេចក្តីនេះ ការលុបចោលការអនុវត្តត្រូវមានអានុភាពភ្លាមៗ ដោយមិនបាច់ចាំរហូតដល់ពេលចូលជាស្ថាពរ។[68]

២.៦ ការបំលែងពីការរឹបអូសជាបណ្តោះអាសន្នទៅជាការអនុវត្តដោយបង្ខំ

នៅក្រោយពេលដែលការរឹបអូសជាបណ្តោះអាសន្នត្រូវបានអនុវត្ត ប្រសិនបើគ្រប់លក្ខខ័ណ្ឌចាំបាច់សម្រាប់ការអនុវត្តដោយបង្ខំត្រូវបានបំពេញ ហើយម្ចាស់បំណុលបានដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ដោយផ្អែកលើលិខិតអនុវត្ត នោះការរឹបអូសជាបណ្តោះអាសន្ន ត្រូវបំលែងទៅជាការអនុវត្តដោយបង្ខំវិញត្រឹមទំហំនៃការអនុវត្តនោះ។ ហេតុនេះហើយនីតិវិធីនេះ អាចឈានបន្តទៅដំណាក់កាលនៃការប្តូរជាប្រាក់បានដោយមិនបាច់ធ្វើនីតិវិធីដដែលសម្រាប់ការអនុវត្តដោយបង្ខំទេ។ ប៉ុន្តែយ៉ាងណាក៏ដោយ បើជាការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុដែលតម្រូវឱ្យមានការចុះបញ្ជី អំពីការរឹបអូសដាច់ដោយឡែកពីការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ននោះត្រូវមានដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំរបស់តុលាការដែលមានសមត្ថកិច្ច។ ករណីដែលម្ចាស់បំណុលមានការធ្វេសប្រហែសមិនបានដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ បើទោះបីជាមានគ្រប់លក្ខខ័ណ្ឌចាំបាច់សម្រាប់ការអនុវត្តដោយបង្ខំត្រូវបានបំពេញហើយក៏ដោយនោះកូនបំណុលអាចដាក់ពាក្យសុំឱ្យលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដោយសារការផ្លាស់ប្តូរស្ថានភាពបានដោយសំអាងទៅលើការរលត់នៃភាពចាំបាច់នៃការរឹបអូសជាបណ្តោះ។[69]

២.៧ ការលុបចោលប្រាតិភោគ

ប្រសិនបើអ្នកដែលបានដាក់ប្រាតិភោគបានបញ្ជាក់នូវការរលត់នៃហេតុ ដែលត្រូវបានដាក់ប្រាតិភោគ តុលាការ

[67] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៦៩ កថាខណ្ឌទី១។

[68] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៦៩ កថាខណ្ឌទី២។

[69] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៥៨។

ត្រូវចេញដីកាសម្រេចលុបចោលនូវប្រាតិភោគនោះតាមពាក្យសុំ។[70]

ដូច្នេះ ក្នុងករណីម្ចាស់បំណុលនៃរឿងក្តីរក្សាការពារឈ្នះបណ្តឹងអង្គសេចក្តីហើយសាលក្រមបានចូលជាស្ថាពរ ម្ចាស់បំណុលនោះអាចទទួលនូវប្រាតិភោគ ដែលគាត់បានដាក់តាមខ្លឹមសារនៃសេចក្តី របស់តុលាការនោះត្រឡប់មកវិញបាន។[71]

ម្ចាស់បំណុលត្រូវដាក់ពាក្យសុំលុបប្រាតិភោគ ដើម្បីទទួលនូវប្រាតិភោគនោះត្រឡប់មកវិញ។ យោងលើពាក្យសុំម្ចាស់បំណុលត្រូវដាក់ឯកសារដូចខាងក្រោមនេះ ម្ចាស់បំណុលត្រូវបានតម្រូវឱ្យធ្វើការបញ្ជាក់នូវការរលត់នៃហេតុដែលត្រូវដាក់ប្រាតិភោគ។

ក្នុងករណីដែលតុលាការទទួលស្គាល់ថា មូលហេតុនៃការដាក់ប្រាតិភោគបានរលត់ តុលាការត្រូវចេញដីកាសម្រេចលុបប្រាតិភោគនោះ។ ម្ចាស់បំណុលអាចទទួលប្រាតិភោគត្រឡប់មកវិញបាន ដោយផ្អែកលើដីកាសម្រេចលុបប្រាតិភោគចោល។ នីតិវិធីនៃការទទួលនូវប្រាតិភោគត្រឡប់មកវិញដោយផ្អែកលើដីកាសម្រេច ដែលបានលើកឡើងខាងលើ និងមានចែងនៅក្នុងសេចក្តីណែនាំរបស់ក្រសួងស្តីពីនីតិវិធីនៃការដាក់ប្រាតិភោគដែលក្រសួងយុត្តិធម៌កំពុងធ្វើសេចក្តីព្រាង។

ផ្នែកទី៣ បណ្តឹងឧបាស្រ័យចំពោះការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ

បណ្តឹងឧបាស្រ័យ គឺជាបណ្តឹងតវ៉ារបស់ភាគីដែលពុំយល់ស្របជាមួយសេចក្តីសម្រេចណាមួយ (សាលក្រម សាលដីកា ឬ ដីកាសម្រេច) របស់ចៅក្រម ឬ តុលាការដើម្បីទាមទារឱ្យលុបចោល ឬ ផ្លាស់ប្តូរសេចក្តីសម្រេចដើម។

៣.១ ការតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

ចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នមិនអាចប្តឹងជំទាស់ភ្លាមបានទេ ប៉ុន្តែអាចដាក់ពាក្យសុំតវ៉ា ទៅតុលាការដែលបានចេញដីកាសម្រេចនោះបាន។[72] ការដាក់ពាក្យសុំតវ៉ា គឺជាឱកាសដែលផ្តល់ឱ្យកូនបំណុលដែលពុំមានឱកាសចូលរួមនៅក្នុងនីតិវិធីជាមុន ក្នុងការសុំឱ្យមានការវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នមិនមែនដោយតុលាការជាន់ខ្ពស់ទេ តែដោយតុលាការថ្នាក់ដដែលដែលចំណុចនេះស្រដៀងគ្នាទៅនឹងការតវ៉ាចំពោះដីកាសម្រេចដាស់តឿននៅក្នុងនីតិវិធីនៃការដាស់តឿន

[70] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៧៣ កថាខណ្ឌទី២។

[71] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤២។

[72] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៥០។

ដែរ។[73] ក្នុងករណីដែលតុលាការនៃបណ្តឹងជំទាស់ លុបចោលដីកាសម្រេចលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ហើយចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ពាក្យសុំតវ៉ាចំពោះដីកាសម្រេចនេះ ត្រូវដាក់ទៅតុលាការនៃបណ្តឹងជំទាស់នោះដែរ។

៣.១.១ ការដាក់ពាក្យតវ៉ា និង លក្ខខ័ណ្ឌនៃពាក្យសុំតវ៉ា

ពាក្យសុំតវ៉ាត្រូវធ្វើជាលាយលក្ខណ៍អក្សរ។[74] ដោយពុំមានការកំណត់អំឡុងពេលពាក្យសុំតវ៉ា អាចដាក់នៅពេលណាក៏បានឱ្យតែដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននៅមានសុពលភាព។ ការដាក់ពាក្យសុំតវ៉ាមិនធ្វើឱ្យអានុភាពអនុវត្តនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នផ្អាកដោយស្វ័យប្រវត្តិទេ គឺត្រូវមានសេចក្តីសម្រេចបណ្តោះអាសន្ន ដោយឡែកដែលបង្គាប់ឱ្យផ្អាកការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ឬ លុបចោលការចាត់ចែងការអនុវត្ត។[75] សេចក្តីសម្រេចបណ្តោះអាសន្ននេះ អាចធ្វើបានតែក្នុងករណីដែលមានសេចក្តីបញ្ជាក់ដំបូងអំពីស្ថានភាពដែលច្បាស់ថានឹងក្លាយជាមូលហេតុនៃការលុបចោលដីកាសម្រេចរក្សាការពារ និងអំពីការដែលមានការបារម្ភថាការខូចខាតដែលមិនអាចសងបាននឹងកើតឡើងដោយសារការអនុវត្តការរឹបអូសជាបណ្តោះអាសន្ននោះប៉ុណ្ណោះ ហើយម៉្យាងទៀត ការដាក់ប្រាតិភោគមានភាពចាំបាច់ជានិច្ច។[76] "ស្ថានភាពដែលច្បាស់ថានឹងក្លាយជាមូលហេតុនៃការលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន" សំដៅទៅលើស្ថានភាពដែលផ្ទុយយ៉ាងច្បាស់លាស់នឹងអត្ថិភាពនៃសិទ្ធិដែលត្រូវបានរក្សាការពារ និងភាពចាំបាច់នៃការចាត់ចែងរក្សាការពារដែលជាលក្ខខ័ណ្ឌចាំបាច់សម្រាប់ការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន (ឧទាហរណ៍ មានភាពមិនត្រឹមត្រូវយ៉ាងច្បាស់ក្រឡែត នៅក្នុងការទទួលស្គាល់ ឬ នៅក្នុងការបកស្រាយច្បាប់) ។ ដោយឡែក "ការបារម្ភថាការខូចខាតដែលមិនអាចសងបាននឹងកើតឡើងដោយសារការអនុវត្តការរក្សាការពារ" សំដៅទៅលើករណីដែលសំណងជាប្រាក់តាមក្រោយទំនងជានឹងមិនអាចសងគ្រប់ចំពោះការខូចខាតរបស់កូនបំណុលបានឡើយ (ឧទាហរណ៍ ករណីដែលកូនបំណុលនឹងក្ស័យធន ឬ មិនអាចរស់បាន ដោយសារការអនុវត្តការរឹបអូសជាបណ្តោះអាសន្ននូវប្រាក់បញ្ញើនៅធនាគាររបស់កូនបំណុល ជាអាទិ៍)។

[73] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៣២៧ និង មាត្រា៣២៩។

[74] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៣៤ ចំណុច គ។

[75] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៥១។

[76] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៥១ កថាខណ្ឌទី១។

៣.១.២ ការវិនិច្ឆ័យអំពីពាក្យសុំតវ៉ា

នៅក្នុងការវិនិច្ឆ័យអំពីការតវ៉ា តុលាការត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬ ធ្វើការសួរ នៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចចូលរួមបាន។[77] គោលបំណងនៃការកំណត់បែបនេះ គឺដើម្បីផ្តល់ទៅឱ្យភាគី (ជាពិសេសកូនបំណុល) នូវការធានានៅក្នុងការចូលរួមក្នុងនីតិវិធី។ ប៉ុន្តែ យ៉ាងណាក៏ដោយ វាមិនចាំបាច់ទាល់តែថា នៅក្នុងកាលបរិច្ឆេទទាំងអស់ ត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬ ការសួរដែលភាគីទាំងសងខាងអាចចូលរួមបាននោះទេ គឺគ្រាន់តែធានាឱ្យបាននូវកាលបរិច្ឆេទដែលភាគីទាំងសងខាង អាចចូលរួមបាន តែម្តងក៏ជាការគ្រប់គ្រាន់ដែរ។ ដើម្បីបញ្ចប់ការវិនិច្ឆ័យអំពីការតវ៉ា ជាគោលការណ៍ តុលាការត្រូវសម្រេចថ្ងៃបញ្ចប់ការវិនិច្ឆ័យ ដោយកំណត់អំឡុងពេលអនុគ្រោះដ៏សមរម្យ។[78] ទោះបីជាទូទៅ នៅក្នុងនីតិវិធីនៃការចេញដីកាសម្រេចតុលាការអាចបញ្ចប់ការ វិនិច្ឆ័យរបស់ខ្លួននៅពេលណាក៏បាន ក៏នៅក្នុងនីតិវិធីនៃការវិនិច្ឆ័យអំពីការតវ៉ានេះ តុលាការត្រូវជូនដំណឹងទៅភាគីអំពីកាលបរិច្ឆេទនៃការបញ្ចប់ការវិនិច្ឆ័យ ដើម្បីផ្តល់ឱកាសឱ្យភាគីក្នុងការដាក់ឯកសារសម្រាប់ការវិនិច្ឆ័យទៅតុលាការឱ្យបានគ្រប់គ្រាន់។ ក៏ប៉ុន្តែ ប្រសិនបើការវិនិច្ឆ័យត្រូវបញ្ចប់នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន តុលាការអាចប្រកាសដោយភ្លាមៗថាបញ្ចប់ការវិនិច្ឆ័យបាន ព្រោះថាការធានានៅក្នុងនីតិវិធីត្រូវបានផ្តល់ឱ្យគ្រប់គ្រាន់ហើយ គឺដូចគ្នាទៅនឹងនីតិវិធីបណ្តឹងដែរ។

៣.១.៣ ដីកាសម្រេចអំពីពាក្យតវ៉ាចំពោះដីកាសម្រេច

នៅក្នុងដីកាសម្រេចអំពីពាក្យសុំតវ៉ា តុលាការត្រូវទទួលស្គាល់ផ្លាស់ប្តូរ ឬ លុបចោលនូវដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។[79] ប្រសិនបើដីកាសម្រេចរឹបអូសជាណ្តោះអាសន្ន មានភាពត្រឹមត្រូវតុលាការត្រូវចេញដីកាសម្រេចទទួលស្គាល់ដីកាសម្រេចនោះ។ រីឯ តុលាការត្រូវចេញដីកាសម្រេចផ្លាស់ប្តូរ ប្រសិនបើដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នមានផ្នែកនូវចំណុចដែលត្រូវធ្វើការផ្លាស់ប្តូរ។ ករណីនេះមានរួមបញ្ចូលករណីពីរដូចជា លំក្ខខ័ណ្ឌដែលម្ចាស់បំណុលត្រូវដាក់ប្រាតិភោគ ឬ ការបន្ថែមនូវប្រាតិភោគ នៅក្នុងអំឡុងពេលកំណត់ណាមួយតំណាងមួយ ជាអាទិ៍។ តុលាការត្រូវចេញដីកាសម្រេចលុបចោលការរឹបអូសជាបណ្តោះអាសន្ន ប្រសិនបើដីកាសម្រេចនោះ មានភាពមិនត្រឹមត្រូវ ហើយនៅក្នុងករណីនេះ តុលាការអាចដាក់លំក្ខខ័ណ្ឌឱ្យកូនបំណុលដាក់ប្រាតិភោគបាន។[80] ដីកាសម្រេចនេះមិនមានអានុភាព បើមិនទាន់ចូលជាស្ថាពរទេ ក៏ប៉ុន្តែ

[77] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៥២។

[78] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៥៣។

[79] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៥៤ កថាខណ្ឌទី១។

[80] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៥៤ កថាខណ្ឌទី២។

បើយល់ឃើញថាចាំបាច់ពិសេសតុលាការអាចប្រកាសថា ដីកាសម្រេចនេះមានអានុភាពភ្លាមៗបាន។[81] ដីកាសម្រេចទាំងនេះត្រូវបញ្ជូនទៅភាគី ហើយបណ្តឹងជំទាស់អាចធ្វើបានចំពោះដីកាសម្រេចទាំងនេះ។

ដោយឡែក នៅក្នុងរឿងរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុអាចមានរូបភាពបីយ៉ាងនៃបណ្តឹងឧបាស្រ័យ (សុំធ្វើការបែងចែកជាបីដើម្បីងាយស្រួលបកស្រាយ)៖ បណ្តឹងតវ៉ា, បណ្តឹងតវ៉ារបស់តតិយជន និងបណ្តឹងជំទាស់ ប៉ុន្តែគប្បីដឹងថាពេលណាគេធ្វើបណ្តឹងតវ៉ាហើយពេលណាគេធ្វើបណ្តឹងជំទាស់ ព្រោះនីតិវិធីនីមួយៗមានលំដាប់លំដោយតាមច្បាប់។

- **បណ្តឹងតវ៉ារបស់កូនបំណុល**

ជាគោលការណ៍ ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នអាចចេញ ដោយពុំចាំបាច់សាកសួរ កូនបំណុលនោះទេតែក្រោយពេលតុលាការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តុលាការត្រូវបញ្ជូនដីកានោះទៅឱ្យភាគី។ ប្រសិនបើកូនបំណុលមិនពេញចិត្តចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នកូនបំណុលអាចប្តឹងតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នទៅតុលាការដើម គឺតុលាការដែលបានចេញដីកាសម្រេចនោះ។ កូនបំណុលអាចដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នទៅតុលាការ ដែលបានចេញដីកាសម្រេចនោះ។[82] ពាក្យសុំដែលបានកំណត់ខាងក្រោមនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ ចំពោះពាក្យសុំតវ៉ាការរឹបអូសជាបណ្តោះអាសន្ន។

នៅពេលមានពាក្យសុំតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តុលាការត្រូវកោះហៅភាគីចូលរួមនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការសាកសួរដែលភាគីអាចចូលរួមបាន។ តុលាការមិនអាចចេញដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នបានឡើយ បើមិនបានឆ្លងកាត់តាមកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ តាមកាលបរិច្ឆេទនៃការសាកសួរដែល ភាគីទាំងសងខាងអាចចូលរួមបាន។[83]

- **បណ្តឹងតវ៉ារបស់តតិយជន**

តតិយជនដែលមានកម្មសិទ្ធិ ឬ សិទ្ធិផ្សេងទៀតដែលរាំងស្ទះការធ្វើអនុប្បទាន ឬ ប្រគល់ចំពោះវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំអាចដាក់ពាក្យបណ្តឹងតវ៉ា ដើម្បីទាមទារកុំឱ្យអនុញ្ញាតការអនុវត្តដោយបង្ខំចំពោះម្ចាស់បំណុលនៃការអនុវត្តនោះបាន។[84]

---

[81] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៥៦។

[82] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៥០។

[83] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៥២។

[84] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៣៦៥ កថាខណ្ឌទី១។

ដោយហេតុថាមាត្រាខាងលើយកមកអនុវត្តចំពោះរឿងរក្សាការពារផងដែរ ដូច្នេះតតិយជនដែលប៉ះពាល់ផលប្រយោជន៍កើតចេញពីដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន គឺតតិយជននោះអាចប្តឹងតវ៉ាបានដែលគេហៅថា បណ្តឹងរបស់តតិយជន និងអនុវត្តនីតិវិធីដូចនីតិវិធីបណ្តឹងផងដែរ (មាននីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់)។ នីតិវិធីនៅពេលមានបណ្តឹងតវ៉ារបស់តតិយជន មានភាពខុសប្លែកពីបណ្តឹងតវ៉ាធម្មតារបស់កូនបំណុល ហើយនីតិវិធីនោះឃើញមានចែងនៅក្នុងករណីដែលមានពាក្យបណ្តឹងតវ៉ាចំពោះការទាមទារពាក្យបណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត ឬ ពាក្យបណ្តឹងតវ៉ារបស់តតិយជន បើមានសេចក្តីបញ្ជាក់ដំបូងអំពីមូលហេតុតវ៉ាដែលត្រូវបានអះអាងនោះ តុលាការដែលបានទទួលពាក្យបណ្តឹងអាចបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំមួយរយៈ តាមពាក្យសុំដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យប្រាតិភោគបានរហូតដល់ធ្វើការសម្រេចសេចក្តីដែលបានកំណត់នៅក្នុងមាត្រា៣៦៨ (ការសម្រេចសេចក្តីផ្អាកការអនុវត្តនៅក្នុងសាលក្រម ឬ សាលដីកាចុងក្រោយ ជាអាទិ៍) នៅក្នុងសាលក្រមចុងក្រោយ។[85]

តាមខ្លឹមសារមាត្រានេះបានអនុញ្ញាតឱ្យតុលាការដែលបានទទួលពាក្យបណ្តឹងតវ៉ារបស់តតិយជននោះអាចបង្គាប់ឱ្យផ្អាកការអនុវត្តសិន ដើម្បីរង់ចាំតុលាការសម្រេចសេចក្តីចុងក្រោយ ដោយចេញសាលក្រមចុងក្រោយដែលអាចលុបចោល ឬ ផ្លាស់ប្តូរ ឬ ទទួលស្គាល់នូវការអនុវត្តនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននោះ។

៣.២ ការលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

ក្រៅពីការលុបចោលដោយសារការតវ៉ាដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន អាចត្រូវបានលុបចោលនៅក្នុងករណីពីរទៀត ដែលមាននីតិវិធីដោយឡែកពីគ្នា តាមពាក្យសុំរបស់កូនបំណុល: ការលុបចោលដោយសារការមិនដាក់ពាក្យបណ្តឹងអង្គសេចក្តី និងការលុបចោលដោយសារការផ្លាស់ប្តូរស្ថានភាព ។

៣.២.១ ការលុបចោលដោយការមិនដាក់ពាក្យបណ្តឹងអង្គសេចក្តី

ការលុបចោលដោយសារការមិនដាក់ពាក្យបណ្តឹងអង្គសេចក្តី: តុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវបង្គាប់ឱ្យម្ចាស់បំណុលដាក់ពាក្យបណ្តឹងអង្គសេចក្តី ហើយឱ្យដាក់ឯកសារដែលបញ្ជាក់អំពីការដាក់ពាក្យបណ្តឹងនោះ ក្នុងអំឡុងពេលដែលទទួលស្គាល់ថាសមរម្យ តាមពាក្យសុំរបស់កូនបំណុល។[86] ការបង្គាប់នេះ ហៅថា ការបង្គាប់ឱ្យដាក់ពាក្យបណ្តឹង។ គោលបំណងនៃការបង្គាប់នេះ គឺដើម្បីបង្ខំឱ្យម្ចាស់បំណុលទៅទទួលលិខិតអនុវត្ត សម្រាប់ការអនុវត្តដោយបង្ខំចំពោះសិទ្ធិដែលត្រូវបានរក្សាការពារ។ ការកំណត់បែបនេះ នឹងទប់ស្កាត់នូវការខូចខាតធ្ងន់ធ្ងរដែលអាចនឹងកើតមានដល់កូនបំណុល ដោយសារទុកស្ថានភាព

[85] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៣៦៧ កថាខណ្ឌទី១។

[86] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៥៧ កថាខណ្ឌទី១។

ដែលមានដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នឱ្យយូរអង្វែង។ ហេតុនេះហើយ ការបង្គាប់ឱ្យដាក់ពាក្យបណ្តឹងអាចចេញបានដោយពុំមានល័ក្ខខ័ណ្ឌទាមទារអ្វីទេ ប្រសិនបើមានពាក្យសុំរបស់កូនបំណុល។ អំឡុងពេលនៃការដាក់ពាក្យបណ្តឹងអង្គសេចក្តីមិនត្រូវតិចជាង ២ សប្តាហ៍ទេ។[87]

ប្រសិនម្ចាស់បំណុលមិនដាក់ឯកសារបញ្ជាក់ជាលាយលក្ខណ៍អក្សរអំពីការដាក់ពាក្យបណ្តឹងអង្គសេចក្តីនៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងការបង្គាប់ឱ្យដាក់ពាក្យបណ្តឹងទេ តុលាការត្រូវលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នតាមពាក្យសុំរបស់កូនបំណុល។[88] ម៉្យាងទៀត ប្រសិនបើនៅក្រោយពេលដាក់ឯកសារបញ្ជាក់នេះហើយ ពាក្យបណ្តឹងអង្គសេចក្តីត្រូវបានដកវិញ ឬ ត្រូវបានលើកចោលនោះ ត្រូវចាត់ទុកថា ឯកសារនោះមិនបានដាក់ឡើយហើយការណ៍នេះក៏នឹងនាំទៅដល់ការចេញដីកាសម្រេចលុបចោលដែរ។[89] ការចាប់ផ្តើមនីតិវិធីមជ្ឈត្តកម្ម ប្រសិនបើមានកិច្ចសន្យាមជ្ឈត្តកម្មអំពីអង្គសេចក្តី [90] និងការចាប់ផ្តើមនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ប្រសិនបើអង្គសេចក្តី គឺជារឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ក៏ត្រូវចាត់ទុកថាជាការដាក់ពាក្យបណ្តឹងអង្គសេចក្តីដែរ។ ដីកាសម្រេចលុបចោលត្រូវបញ្ជូនទៅភាគីហើយបណ្តឹងជំទាស់អាចធ្វើបានចំពោះដីកាសម្រេចនេះ។[91]

៣.២.២ ការលុបចោលដោយការផ្លាស់ប្តូរស្ថានភាព

ការលុបចោលដោយសារការផ្លាស់ប្តូរស្ថានភាព: បើមានការរលត់សិទ្ធិដែលត្រូវបានរក្សាការពារ ឬ ភាពចាំបាច់ក្នុងការរក្សាការពារ ឬ ការផ្លាស់ប្តូរផ្សេងទៀតនៃស្ថានភាពតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬ តុលាការនៃបណ្តឹងអង្គសេចក្តីអាចលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តាមពាក្យសុំរបស់កូនបំណុលបាន។ ការផ្លាស់ប្តូរស្ថានភាពនេះ ត្រូវបានបែងចែកជាពីរប្រភេទ។[92]

- ប្រភេទទីមួយ គឺករណីដែលនៅក្រោយពេលចេញដីកាសម្រេចរឹបអូសជាបណ្តោអាសន្ន កើតមានឡើងនូវអង្គហេតុថ្មី ដែលធ្វើឱ្យដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននោះ មានភាពមិនត្រឹមត្រូវ (ឧទាហរណ៍ ករណីដែលសិទ្ធិទាមទារទាំងអស់ដែលត្រូវបានរក្សាការពារត្រូវបានសងគ្រប់ចំនួន ករណីដែលមានសាលក្រមនៃការជំនុំជម្រះលើកទី១ សម្រេចឱ្យម្ចាស់បំណុលចាញ់ក្តី នៅក្នុង

[87] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៥៧ កថាខណ្ឌទី២។

[88] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៥៧ កថាខណ្ឌទី៣។

[89] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៥៧ កថាខណ្ឌទី៤។

[90] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៥៧ កថាខណ្ឌទី៥។

[91] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៦១ កថាខណ្ឌទី១ ចំណុច ក ។

[92] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៥៨ កថាខណ្ឌទី១។

បណ្តឹងអង្គសេចក្តី ករណីដែលកូនបំណុលក្លាយជាអ្នកមានទ្រព្យសម្បត្តិគ្រប់គ្រាន់ដើម្បីសង ករណីដែលម្ចាស់បំណុលមិនធ្វើការអនុវត្តដោយបង្ខំ បើទោះជាបានបំពេញគ្រប់លក្ខខ័ណ្ឌទាមទារដែលអាចអនុវត្តដោយបង្ខំបានហើយក៏ដោយ ជាអាទិ៍)។

- ប្រភេទទីពីរ គឺករណីដែលកូនបំណុលបានដឹងអំពីអង្គហេតុដែលនាំឱ្យដីកាសម្រេចរឹបអូសបណ្តោះអាសន្ននោះ មានភាពមិនត្រឹមត្រូវ ឬ អាចធ្វើសេចក្តីបញ្ជាក់ដំបូងអំពីហេតុនោះ នៅក្រោយពេលចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នទោះបីជាអង្គហេតុនោះបានកើតឡើងនៅពេលចេញដីកាសម្រេចរក្សាការពារក៏ដោយ។ នៅក្នុងករណីនេះ កូនបំណុលត្រូវធ្វើសេចក្តីបញ្ជាក់ដំបូងអំពីការផ្លាស់ប្តូរស្ថានភាពនោះ។[93]

បញ្ញត្តិទាក់ទងនឹងការសម្រេចសេចក្តីអំពីការតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំណែកឯ ការសម្រេចសេចក្តីអំពីពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន[94] មានន័យថា បញ្ញត្តិស្តីពីការសម្រេចសេចក្តីអំពីការផ្អាកការអនុវត្តរឹបអូសជាបណ្តោះអាសន្នជាអាទិ៍។[95] ការទាញហេតុផលដោយផ្ទាល់មាត់ និងការសួរនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចចូលរួមបាន ការបញ្ចប់ការវិនិច្ឆ័យ និងអានុភាពនៃដីកាសម្រេចលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នដោយសារការផ្លាស់ប្តូរស្ថានភាព។ ដីកាសម្រេចលុបចោលអាចដាក់លក្ខខ័ណ្ឌឱ្យកូនបំណុលដាក់ប្រាតិភោគបាន ហើយដីកាសម្រេចនេះត្រូវបញ្ជូនទៅភាគីនឹងអាចប្តឹងជំទាស់បាន។

៣.២.៣ ការលុបចោលដោយការអស់សុពលភាពនៃដីកាសម្រេច

ដីកាសម្រេចរក្សាការពារធ្វើឡើងក្នុងគោលបំណងការពារសិទ្ធិរបស់ម្ចាស់បំណុលជាបណ្តោះអាសន្ន ដោយតុលាការមិនទាន់សម្រេចអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិនោះតាមវិធីនៃបណ្តឹងឡើយ។ ប៉ុន្តែវាក៏អាចធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់កូនបំណុលផងដែរ។ ប្រសិនបើមានការអូសបន្លាយពេលវេលាមិនសមរម្យ ហេតុនេះហើយទើបមាត្រា ៥៥៧ នេះកំណត់ថា តុលាការត្រូវបង្គាប់ម្ចាស់បំណុលឱ្យដាក់ពាក្យបណ្តឹងអង្គសេចក្តី និងឯកសារដែលបញ្ជាក់អំពីការដាក់ពាក្យបណ្តឹងដោយកំណត់អំឡុងពេលមិនតិចជាង២ (ពីរ) សប្តាហ៍ តាមពាក្យសុំរបស់កូនបំណុល។

៣.៣ បណ្តឹងជំទាស់

[93] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៥៨ កថាខណ្ឌទី២។

[94] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៦០ កថាខណ្ឌទី១។

[95] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៥១។

៣.៣.១ អត្ថន័យនៃបណ្តឹងជំទាស់

បណ្តឹងជំទាស់ គឺជាបណ្តឹងឧបាស្រ័យមួយប្រភេទទៅតុលាការជាន់ខ្ពស់ (ដែលជាតុលាការនៃបណ្តឹងជំទាស់) ដើម្បីទាមទារឱ្យលុបចោល ឬ ផ្លាស់ប្តូរដីកាសម្រេចដើម។ បណ្តឹងជំទាស់អាចធ្វើទៅបាន លុះត្រាតែមានចែងក្នុងច្បាប់។ ដីកាសម្រេចដែលអាចបណ្តឹងជំទាស់បានមានដូចជា ៖

- ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ (មាត្រា ៥៥៤ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦)
- ដីកាសម្រេចឱ្យធ្វើបដិទាន (មាត្រា ៥៥៥ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦)
- ដីកាសម្រេចដែលលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ (មាត្រា ៥៤៤ កថាខណ្ឌទី ១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦)
- ដីកាសម្រេចអំពីពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរក្សាការពារ (មាត្រា ៥៦១ កថាខណ្ឌទី ១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦)។

៣.៣.២ នីតិវិធី និង អំឡុងពេលនៃបណ្តឹងជំទាស់

ដើម្បីប្តឹងជំទាស់បាន ភាគីត្រូវដាក់ពាក្យបណ្តឹងជំទាស់នេះទៅតុលាការដើម ហើយតុលាការដើមត្រូវផ្ញើពាក្យបណ្តឹងជំទាស់នេះ និងសំណុំរឿងទៅតុលាការនៃបណ្តឹងជំទាស់។ ចំពោះនីតិវិធីនៃការប្តឹងជំទាស់ អ្នកដែលមានសិទ្ធិធ្វើបណ្តឹងជំទាស់អាចធ្វើបានតែអំឡុងពេល ២ (ពីរ) សប្តាហ៍ ចាប់ពីថ្ងៃដែលទទួលបានការបញ្ជូន។[96] បើក្នុងករណីដែលពុំបានសរសេរច្បាស់លាស់អំពីមូលហេតុនៃការទាមទារឱ្យលុបចោល ឬ ផ្លាស់ប្តូរដីកាសម្រេចដើមក្នុងបណ្តឹងជំទាស់ទេ ម្ចាស់បណ្តឹងជំទាស់គប្បីដាក់លិខិតជាលាយលក្ខណ៍អក្សរ ដែលបានសរសេរអំពីមូលហេតុនៃការទាមទារឱ្យលុបចោលនោះ ទៅតុលាការនៃបណ្តឹងជំទាស់ក្នុងអំឡុងពេល ០២ (ពីរ) សប្តាហ៍ គិតចាប់ពីថ្ងៃដែលបានដាក់ពាក្យបណ្តឹងជំទាស់នោះ។ នីតិវិធីនៃបណ្តឹងជំទាស់ ជានីតិវិធីមួយដែលមានរយៈពេលយូរ ឬ យឺតជាងការតវ៉ា ហើយការតវ៉ាគ្រាន់តែជានីតិវិធីបន្ថែមលើបណ្តឹងជំទាស់តែប៉ុណ្ណោះ។ បណ្តឹងជំទាស់ ត្រូវបានយកមកអនុវត្តដូចគ្នាចំពោះបញ្ញត្តិមួយចំនួនផងដែរទៅនឹងនីតិវិធីនៃការតវ៉ាដូចជា ការទាញហេតុផលផ្ទាល់មាត់នៅក្នុងបណ្តឹងជំទាស់ចំពោះនីតិវិធីនៃបណ្តឹងជំទាស់ ជានីតិវិធីមួយដែលមានការរយៈពេលយូរ ឬ យឺតជាងការតវ៉ា។ បណ្តឹងជំទាស់នេះចំណុចខ្លះក៏ត្រូវអនុវត្តដូចនីតិវិធីនៃការតវ៉ាដែរ។

នៅក្នុងបណ្តឹងជំទាស់ ចំពោះនីតិវិធីរឹបអូសជាបណ្តោះអាសន្ន តុលាការចាំបាច់ត្រូវធ្វើការទាញហេតុផលផ្ទាល់មាត់ដោយត្រូវធ្វើការកំណត់រយៈពេលដ៏សមរម្យ និងភាគីដែលពាក់ព័ន្ធនឹងផលប្រយោជន៍អាចចូលរួមបាន។ ចំពោះ ករណីដែលតុលាការនៃបណ្តឹងជំទាស់ចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នជាលើកទីមួយ

[96] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៦១ កថាខណ្ឌទី១។

បណ្តឹង ជំទាស់មិនអាចធ្វើបានទេចំពោះដីកាសម្រេចនេះ ព្រោះមានការបកស្រាយថាដីកាសម្រេចនេះបានបំពេញល័ក្ខខ័ណ្ឌនៃប្រព័ន្ធនៃការជម្រះក្តីពីរថ្នាក់រួចហើយ។ ផ្ទុយទៅវិញក្នុងករណីដែលសាលាឧទ្ធរណ៍បានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន និងលើកចោលពាក្យសុំតវ៉ា ឬ ពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននោះ នៅក្នុងបណ្តឹងអង្គសេចក្តីដែលកំពុងត្រូវបានចាត់ការនៅសាលាឧទ្ធរណ៍ បណ្តឹងជំទាស់អាចធ្វើទៅតុលាការកំពូលបានដើម្បីធានាឱ្យបាននូវប្រព័ន្ធនៃការជម្រះក្តីពីរថ្នាក់។

៣.៣.៣ ការធ្វើបណ្តឹងជំទាស់

ផលប្រយោជន៍ក្នុងការប្តឹងជំទាស់ ត្រូវបានទទួលស្គាល់ចំពោះភាគី ឬ តតិយជន ដែលបាត់បង់នូវផលប្រយោជន៍ដោយសារដីកាសម្រេចដើម។ បណ្តឹងជំទាស់ត្រូវធ្វើក្នុង អំឡុងពេល ០១ (មួយ)សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានទទួលដំណឹងអំពីដីកាសម្រេច។[97] អំឡុងពេលនេះមិនអាចពន្យារបានទេ (មាត្រា ២៥៩ កថាខណ្ឌទី ១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦)។ ដើម្បីធ្វើបណ្តឹងជំទាស់ត្រូវដាក់ពាក្យបណ្តឹងជំទាស់ទៅតុលាការដើម។ នៅក្នុងពាក្យបណ្តឹងជំទាស់គួរតែចុះអំពីមូលហេតុច្បាស់លាស់នៃការសុំលុបចោល ឬ ផ្លាស់ប្តូរនូវដីកាសម្រេចដើម ក៏ប៉ុន្តែប្រសិនបើមិនសរសេរអំពីមូលហេតុទាំងនោះ ក៏បណ្តឹងជំទាស់នោះមិនបែរជាគ្មានសុពលភាពដែរ។ ក្នុងករណីដែលពាក្យបណ្តឹងជំទាស់មិនមានសរសេរអំពីមូលហេតុនោះទេ ដើមបណ្តឹងជំទាស់គប្បីដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងជំទាស់នោះទៅតុលាការនៃបណ្តឹងជំទាស់ ក្នុងអំឡុងពេល ០២ (ពីរ) សប្តាហ៍គិតចាប់ពីថ្ងៃដែលបានដាក់ពាក្យបណ្តឹងជំទាស់នោះ។[98]

៣.៣.៤ នីតិវិធីជំនុំជម្រះនៃបណ្តឹងជំទាស់

ដោយហេតុថានីតិវិធីនៃការជំនុំជម្រះបណ្តឹងជំទាស់ត្រូវបញ្ចប់ដោយដីកាសម្រេច តុលាការអាចសម្រេចដោយឆន្ទានុសិទ្ធិបានថាតើត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬ អត់ (មាត្រា ៣០៦ កថាខណ្ឌទី ១ និងមាត្រា១១៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦) ។ ក្នុងករណីដែលមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់ទេ តុលាការនៃបណ្តឹងជំទាស់អាចសួរម្ចាស់បណ្តឹងជំទាស់ ឬ បុគ្គលផ្សេងទៀតដែល មានទំនាក់ទំនងផលប្រយោជន៍នៃបណ្តឹងជំទាស់នោះបាន។ ក្នុងការជំនុំជម្រះបណ្តឹងជំទាស់ភាគីអាចដាក់អង្គហេតុថ្មីនឹងភស្តុតាងថ្មីដូចការជំនុំជម្រះបណ្តឹងឧទ្ធរណ៍។ សេចក្តីសម្រេចចុងក្រោយនៃការជំនុំជម្រះបណ្តឹងជំទាស់ គឺជាដីកាសម្រេចហើយខ្លឹមសារនៃដីកាសម្រេចនោះ ត្រូវអនុលោមទៅតាមសាលដីកាចុងក្រោយនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍។ ប៉ុន្តែ បណ្តឹងជំទាស់ចំពោះដីកាសម្រេចដែលសាលាឧទ្ធរណ៍បានធ្វើ

[97] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៣០៣ កថាខណ្ឌទី១។

[98] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៣០១ កថាខណ្ឌទី១។

ក្នុងនាម ជាតុលាការនៃការជំនុំជម្រះលើកទី១ ការវិនិច្ឆ័យ និងខ្លឹមសារនៃសេចក្តីសម្រេចចុងក្រោយ ត្រូវអនុលោមទៅតាមករណីនៃការជំនុំជម្រះបណ្តឹងសាទុក្ខដែលជាការវិនិច្ឆ័យលើអង្គច្បាប់។[99]

៣.៣.៥ ការបញ្ឈប់ការវិនិច្ឆ័យចំពោះបណ្តឹងជំទាស់

ការបញ្ចប់ការវិនិច្ឆ័យចំពោះបណ្តឹងជំទាស់មានលក្ខណៈដូចគ្នាជាមួយការវិនិច្ឆ័យអំពីការតវ៉ាដែរតុលាការត្រូវសម្រេចថ្ងៃបញ្ចប់ការវិនិច្ឆ័យដោយកំណត់អំឡុងពេលអនុគ្រោះដោយសមរម្យ។ ប៉ុន្តែ បើតុលាការបានកំណត់កាលបរិច្ឆេទនៃការវិនិច្ឆ័យតុលាការអាចប្រកាសភ្លាមៗថា បញ្ចប់ការវិនិច្ឆ័យដូចដែលបានកំណត់ទៅតាមកាលបរិច្ឆេទ។[100]

៣.៣.៦ ការសម្រេចសេចក្តី

នៅពេលដែលតុលាការបានទទួលពាក្យប្តឹងជំទាស់របស់ភាគី ហើយតុលាការបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ រួចមកតុលាការបានធ្វើការសម្រេចសេចក្តី។ បណ្តឹងជំទាស់នោះ គឺប្តឹងជំទាស់លើដីកាសម្រេចលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចការរឹបអូសជាបណ្តោះអាសន្ន ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន និងដីកាសម្រេចអំពីពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។ ការសម្រេចលើពាក្យសុំតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដែលទទួលស្គាល់ដីកាសម្រេចដើមរបស់តុលាការនៃបណ្តឹងជំទាស់ គឺភាគីមិនអាចប្តឹងជំទាស់ទៀតឡើយ។[101] ទោះបីជាតុលាការនៃបណ្តឹងជំទាស់រក្សាទុក ឬ លុបចោលនូវដីកាសម្រេចដើមក៏ដោយ។ ផ្ទុយទៅវិញ ការសម្រេចសេចក្តីលើពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារដែលលុបចោលដីកាសម្រេចនោះ គឺតុលាការនៃបណ្តឹងជំទាស់ចេញនូវៈ ដីកាសម្រេចរក្សាតម្កល់ទុក្ខដីកាសម្រេចដើម និងដីកាសម្រេចលុបចោលដីកាសម្រេចដើម។ ករណីតុលាការចេញដីកាសម្រេចរក្សាតម្កល់ទុក្ខដីកាសម្រេចដើម គឺភាគីមិនអាចប្តឹងជំទាស់បាននោះ។ លើកលែងតែករណីតុលាការចេញដីកាសម្រេចលុបចោលដីកាសម្រេចដើម ហើយចេញដីកាសម្រេចថ្មីគឺភាគីដែលមិនសុខចិត្តអាចដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចនោះបាន។[102]

---

[99] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៣០៤ កថាខណ្ឌទី២។

[100] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៥៣។

[101] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា២៥៩ កថាខណ្ឌទី៣។

[102] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៥០។

ម្យ៉ាងវិញទៀត ការសម្រេចសេចក្តីលើពាក្យសុំតវ៉ាចំពោះដីកាសម្រេចក្រោយនេះ គឺភាគីមិនអាចប្តឹងជំទាស់បានទៀតនោះទេ។[103] ទោះបីជាតុលាការចេញដីកាសម្រេចទទួលស្គាល់ ឬ លុបចោលដីកាសម្រេចនោះវិញក៏ដោយ។

មួយវិញទៀត បណ្តឹងជំទាស់ចំពោះដីកាសម្រេចអំពីពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន គឺការសម្រេចសេចក្តីរបស់តុលាការនៃបណ្តឹងជំទាស់អាចស្តែងឡើងក្នុងទិដ្ឋភាពដីកាសម្រេចពីរប្រភេទ គឺដីកាសម្រេចរក្សាទុកដីកាសម្រេចដើម និងដីកាសម្រេចលុបចោលដីកាសម្រេចដើម។ ម្យ៉ាងទៀត ដីកាសម្រេចទាំងពីរនេះ គឺភាគីមិនអាចជំទាស់ទៀតបានឡើយ។[104] ប៉ុន្តែក្នុងករណីតុលាការនៃបណ្តឹងជំទាស់ចេញដីកាសម្រេចលុបចោលដីកាសម្រេចដើម ហើយបើម្ចាស់បំណុលបានទទួលការប្រគល់វត្ថុ ឬ ការបង់ប្រាក់ ឬ ប្រើប្រាស់ ឬ ថែរក្សាគ្រប់គ្រងវត្ថុ ដោយផ្អែកលើដីកាសម្រេចដើមនោះ តុលាការអាចបង្គាប់ឱ្យម្ចាស់បំណុលបង្វិលសងវត្ថុដែលកូនបំណុលបានប្រគល់ ឬ សងប្រាក់ដែលកូនបំណុលបានបង់ ឬ បង្វិលសងវត្ថុដែលម្ចាស់បំណុលកំពុងប្រើប្រាស់ ឬ ថែរក្សាគ្រប់គ្រងបានតាមពាក្យសុំរបស់កូនបំណុល ។[105]

[103] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៦១។

[104] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា២៥៩ កថាខណ្ឌទី៣។

[105] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៥៥។

ជំពូកទី៣
បញ្ហាប្រឈម និងដំណោះស្រាយ

ជំពូកទី៣
បញ្ហាប្រឈម និងដំណោះស្រាយ

ផ្នែកទី១ បញ្ហាប្រឈម

នីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ ជានីតិវិធីមួយដែលមានភាពស្មុគស្មាញខ្លាំង បើគិតចាប់តាំងពីពេលដាក់ពាក្យសុំចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន រហូតមកដល់ការអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។ លើសពីនេះទៅទៀត ដើម្បីឱ្យនីតិវិធីនេះមានដំណើរការទៅបានរលូន ក៏ត្រូវតម្រូវឱ្យមានការចូលរួមពីសំណាក់មន្ត្រីដែលពាក់ពន្ធនៅក្នុងអំឡុងពេលអនុវត្តរឹបអូសនេះ។ មួយវិញទៀតក៏ត្រូវទាមទារឱ្យម្ចាស់បំណុលចូលរួមយ៉ាងសកម្ម និងមានចំណេះដឹងផ្នែកច្បាប់ទាក់ទងនឹងនីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្ននេះផងដែរ។ ប៉ុន្តែ ទោះបីជាមានអ្នកពាក់ព័ន្ធទៅនឹងផលប្រយោជន៍បានបំពេញទៅតាមលក្ខខ័ណ្ឌដែលច្បាប់កំណត់ក៏ដោយ ក៏តែងតែជួបប្រទះនឹងបញ្ហាខានពុំបាន។

១.១ ភាពខ្វះចន្លោះនៃច្បាប់

នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងបានតាក់តែងច្បាប់ជាច្រើនដែលក្នុងនោះមានដូចជា ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី និងលិខិតបទលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត។ ជាពិសេស ក្រមនីតិវិធីរដ្ឋប្បវេណីដែលពាក់ព័ន្ធទៅនិងប្រធានបទខាងលើនេះមាន ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី។ ក្នុងឆ្នាំ២០០៦ ក្រមនីតិវិធីរដ្ឋប្បវេណី ចំនួន ៩គន្លឹ ៥៨៨មាត្រា ត្រូវបានប្រកាសឱ្យប្រើដើម្បីសម្រួលក្នុងការអនុវត្ត និងដំណើរការនៃនីតិវិធីផ្នែករដ្ឋប្បវេណី ជាពិសេសត្រង់គន្លឹទី៧ ស្តីពីការចាត់ចែងរក្សាការពារ ក៏មាននីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ ជាផ្នែកមួយក្នុងនីតិវិធីនៃការចាត់ចែងរក្សាការពារផងដែរ។ ក៏ប៉ុន្តែ ច្បាប់ទាំងអស់នោះមិនទាន់គ្រប់គ្រាន់នៅឡើយទេ នៅតែមានភាពចន្លោះប្រហោងធ្វើឱ្យមានភាពស្មុគស្មាញ និងមានការយឺតយ៉ាវទៅដល់ដំណើរការក្នុងនីតិវិធី នាំឱ្យមានការខាតបង់ប្រយោជន៍ទៅលើម្ចាស់បំណុល។ ជាពិសេស បញ្ញត្តិនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីពុំមានចែងអំពីរយៈពេលពិតប្រាកដនៃការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុឱ្យម្ចាស់បំណុលនោះទេ។ មួយវិញទៀត ដោយសារតែច្បាប់ស្តីពីលក្ខន្តិកៈអាជ្ញាសាលាពុំទាន់មាននៅឡើយ ថែមទាំងក្រមនីតិវិធីរដ្ឋប្បវេណីក៏មិនបានចែងឱ្យគ្រប់គ្រាន់អំពីតួនាទីរបស់អាជ្ញាសាលាផងនោះ ទើបតម្រូវឱ្យព្រះរាជអាជ្ញា-ព្រះរាជអាជ្ញារងចុះទៅអនុវត្តរឹបអូសជាបណ្តោះអាសន្នជាមួយផងដែរ។ លើសពីនេះ នៅពេលតុលាការអនុវត្តបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នដែលបានបញ្ជូនទៅដល់ដៃរបស់កូនបំណុលហើយ តែកូនបំណុលពុំមានសកម្មភាពក្នុងការធ្វើបណ្តឹងតវ៉ាទៅលើដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននោះទេ ដោយទុកដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននោះចោល ហើយក៏មិនមានបញ្ញត្តិច្បាប់ណាមួយបានចែងពាក់ព័ន្ធអំពីអាជ្ញាយុកាលនៃការធ្វើបណ្តឹងតវ៉ានោះឡើយ។ ជាពិសេស

ការបញ្ជូនដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នក៏មិនមានរយៈពេលនៃការបញ្ជូនដូចគ្នា។ ចំពោះករណីខ្លះទៀត ដោយសារតែយើងពុំទាន់មានច្បាប់ស្តីពីលក្ខន្តិកៈអាជ្ញាសាលានៅឡើយ ទើបចលនវត្ថុខ្លះដែលត្រូវបានរឹបអូស គឺព្រះរាជអាជ្ញា-ព្រះរាជអាជ្ញារង ដែលជាអ្នកទទួលបន្ទុកនៃការរឹបអូសជាបណ្តោះអាសន្ននោះចុះទៅរឹបអូសផ្ទាល់តែម្តង។

១.២ កង្វះការយល់ដឹងផ្នែកច្បាប់របស់ប្រជាពលរដ្ឋ

ជាក់ស្តែងណាស់ ក្រមនីតិវិធីរដ្ឋប្បវេណីត្រូវប្រកាសឱ្យប្រើនាឆ្នាំ២០០៦ កន្លងមក អស់រយៈពេលជាង ១០ឆ្នាំមកហើយក្តី ក៏ប៉ុន្តែ ការយល់ដឹងផ្នែកច្បាប់របស់ប្រជាពលរដ្ឋនៅមានកម្រិតនៅឡើយ ហេតុថាពួកគាត់មានភាពមមាញឹកប្រកបកិច្ចការងារសម្រាប់បម្រើជីវភាពប្រចាំថ្ងៃ និងមានភាគរយតិចតួចណាស់ ដែលមានប្រជាពលរដ្ឋចំណាយពេលមកសិក្សាស្វែងយល់ ឬ ស្រាវជ្រាវអំពីច្បាប់។ ចំពោះករណីខ្លះទៀត ទីកន្លែងដែលប្រជាពលរដ្ឋគាត់រស់នៅជាតំបន់ដាច់ស្រយាលដែលមិនងាយ និងមានការផ្សព្វផ្សាយច្បាប់ទៅដល់នោះទេ ជាមូលហេតុនាំឱ្យការយល់ដឹងអំពីច្បាប់របស់ប្រជាពលរដ្ឋមានកង្វះខាតច្រើន។ ជាពិសេស ពាក់ព័ន្ធទៅនឹងនីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុតែម្តង ពួកគាត់ស្ទើរតែមិនធ្លាប់បានដឹងមិនធ្លាប់បានឮ ថាតើនីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុមានគោលបំណងបែបណា ដំណើរការអនុវត្តដូចម្តេច ដែលជាហេតុនាំឱ្យនីតិវិធីមួយនេះកាន់តែស្មុកស្មាញពិបាកនៅក្នុងពេលអនុវត្តតែម្តង ដោយធ្វើឱ្យប្រជាពលរដ្ឋមានការភាន់ច្រលំថាជាការរំលោភបំពាន ឬ ប្រើអំណាចខុសច្បាប់ពីសំណាក់ស្ថាប័នរដ្ឋ។ លើសពីនេះទៅទៀត ប្រជាពលរដ្ឋមិនយល់ដឹងអំពីរបៀបសរសេរពាក្យសុំដីកាសម្រេចការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ លំហូរនីតិវិធីនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ និងការលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុថាមានដំណើរការបែបណាទេ ព្រោះនីតិវិធីនេះមានលក្ខណៈស្មុគស្មាញជាខ្លាំង។

ឧទាហរណ៍៖ នៅពេលដែលតុលាការចេញដីកាសម្រេចការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុបញ្ជូនទៅកូនបំណុល ហើយកូនបំណុលដែលទទួលបានដីកានោះ គឺមានការភ័យតក់ស្លុតជាខ្លាំងព្រោះថាគាត់មិនបានយល់អំពីខ្លឹមសារនៃការរឹបអូសជាបណ្តោះអាសន្ននោះឡើយ។

១.៣ ការយល់ដឹងរបស់មន្ត្រីអនុវត្តរឹបអូសជាបណ្តោះអាសន្ននៅមានកម្រិត

ជាគោលការណ៍ មន្ត្រីអនុវត្តក្នុងការរឹបអូសជាបណ្តោះអាសន្នរួមមាន តុលាការអនុវត្ត ក្រឡាបញ្ជីដែលមានតួនាទីជាជំនួយការ អាជ្ញាសាលា ព្រះរាជអាជ្ញា-ព្រះរាជអាជ្ញារង មន្ត្រីនៃស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត និងមេធាវីដែលមិនមែនជាមន្ត្រីរាជការក៏ចូលរួមអនុវត្តផងដែរ។ ចំណែកឯមន្ត្រីដែលមានតួនាទីអនុវត្តទៅលើការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ គឺអាជ្ញាសាលាដោយអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណី និងបទដ្ឋានគតិយុត្តផ្សេងទៀត។ ក៏ប៉ុន្តែតាមបណ្តាសាលាដំបូងរាជធានី-ខេត្តមួយចំនួនដែលពុំទាន់មានអាជ្ញាសាលា គឺត្រូវប្រគល់

ភារកិច្ចអាជ្ញាសាលាដែលមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណីទៅឱ្យ ព្រះរាជអាជ្ញា-ព្រះរាជអាជ្ញារង ដែលស្ថិតនៅតាមសាលាដំបូងរាជធានី-ខេត្ត ជាបណ្តោះអាសន្នរហូតដល់មានច្បាប់ស្តីពីអាជ្ញាសាលា ដោយយោងតាមប្រកាសលេខ៣០ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលារបស់ក្រសួងយុត្តិធម៌។

ឧទាហរណ៍៖ ក្នុងករណីនៅតាមសាលាដំបូងខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តស្ទឹងត្រែង ខេត្តក្រចេះ និងខេត្តកំពង់ស្ពឺ នៅតែមិនទាន់មានអាជ្ញាសាលានៅឡើយទេ ដូច្នេះហើយព្រះរាជអាជ្ញា-ព្រះរាជអាជ្ញារងតាមបណ្តាខេត្តទាំងនោះ ជាអ្នកដែលទទួលបន្ទុកក្នុងការរឹបអូសរឹបអូសជាបណ្តោះអាសន្នជំនួសអាជ្ញាសាលា។

រីឯ អាជ្ញាសាលាមានតួនាទី និងភារកិច្ចជាច្រើន ដែលក្នុងនោះពេលខ្លះអាជ្ញាសាលាអនុវត្តតួនាទីក្នុងនាមជាស្ថាប័នឯករាជ្យ និងពេលខ្លះអាជ្ញាសាលាអនុវត្តកិច្ចការក្នុងនាមជាស្ថាប័នជំនួយរបស់តុលាការផងដែរ។

ជាការពិតណាស់ អាជ្ញាសាលាដើរតួនាទីយ៉ាងសំខាន់នៅក្នុងនីតិវិធីរក្សាការពារដែលទទួលបន្ទុកក្នុងការអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នរបស់តុលាការ ដែលអាជ្ញាសាលាបានស្ថិតនៅនោះ មានន័យថាអាជ្ញាសាលាអនុវត្ត ឬ បំពេញទៅបាន លុះត្រាតែតុលាការមានសមត្ថកិច្ចក្នុងការចេញដីកាសម្រេចចាត់ចែងរក្សាការពារទើបអាចអនុវត្តបាន។ បច្ចុប្បន្ននេះ មន្ត្រីដែលពាក់ព័ន្ធនឹងការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុមួយចំនួន មានចំណេះដឹងពាក់ព័ន្ធទៅនឹងនីតិវិធីនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុនៅមានកម្រិតនៅឡើយ។ តួយ៉ាងអាជ្ញាសាលាដែលទទួលបន្ទុកលើការអនុវត្តរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ ខ្វះខាតនូវការយល់ដឹងអំពីនីតិវិធីនៅក្នុងការអនុវត្តនោះ ក៏ជាកត្តាមួយក្នុងចំណោមកត្តាផ្សេងៗទៀត ដែលនាំឱ្យមានការរាំងស្ទះដល់ការអនុវត្ត ឬ ការអនុវត្តនីតិវិធីខុសពីបញ្ញត្តិច្បាប់។ ជាពិសេស អាជ្ញាសាលាដែលទើបតែចូលបម្រើការងារ ពុំមានបទពិសោធន៍ច្រើនអាចនឹងមិនដឹងអំពីគន្លឹះ ដើម្បីដោះស្រាយនូវបញ្ហាកក់ស្ទះនៅចំណុចណាមួយ ឬ ហៅថាមិនចេះបត់បែនដើម្បីសម្រួលឱ្យការអនុវត្តរឹបអូសជាបណ្តោះអាសន្នបានជោគជ័យ។

លើសពីនេះទៅទៀត យោងតាមសេចក្តីណែនាំរបស់ក្រសួងយុត្តិធម៌ ដែលបានផ្តល់សិទ្ធិឱ្យព្រះរាជអាជ្ញានិងព្រះរាជអាជ្ញារង ទទួលបន្ទុកកិច្ចការជំនួសអាជ្ញាសាលា ក៏ប៉ុន្តែព្រះរាជអាជ្ញា-ព្រះរាជអាជ្ញារងខ្លះ គាត់មានតួនាទីក្នុងការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ ហើយគាត់មកអនុវត្តនីតិវិធីរឹបអូសជាបណ្តោះអាសន្នដែលជានីតិវិធីមួយដាច់ដោយឡែកពីគ្នា ដូច្នេះទើបធ្វើឱ្យការអនុវត្តខ្លះមានភាពរអាក់រអួល ឬ មិនទទួលបានជោគជ័យ។

១.៤ ភាពលំបាកក្នុងការស្វែងរកចលនវត្ថុរបស់កូនបំណុល

នៅមុនពេលដែលម្ចាស់បំណុលបានដាក់ពាក្យបណ្តឹងសុំចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុរបស់កូនបំណុល ម្ចាស់បំណុល គឺជាអ្នកមានតួនាទីស្វែងរកទ្រព្យរបស់កូនបំណុលដោយខ្លួនឯង ហេតុនេះហើយទើបធ្វើឱ្យម្ចាស់បំណុលមានភាពលំបាកជាខ្លាំង ថែមទាំងម្ចាស់បំណុលខ្លះ គាត់មិនបានធ្លាប់យល់ដឹងពីច្បាប់ទៀតផងនោះ គាត់ក៏មិនដឹងត្រូវស្វែងរកទ្រព្យរបស់កូនបំណុលតាមមធ្យោបាយបែបណានោះទេ។

មួយវិញទៀត ទោះបីជាម្ចាស់បំណុលដែលបានដឹងពាក់ព័ន្ធនឹងផ្នែកច្បាប់ក៏ដោយ ក៏នៅតែមានផលលំបាកផងដែរ ព្រោះត្រូវពឹងពាក់ឱ្យស្ថាប័នដែលពាក់ព័ន្ធជួយស្វែងរកទ្រព្យរបស់កូនបំណុល ហើយក៏មិនអាចធានាថាបានលទ្ធផលដូចជាការរំពឹងទុកនោះដែរ។ ចំពោះករណីខ្លះ ម្ចាស់បំណុលចង់ស្វែងរកទ្រព្យដែលជាចលនវត្ថុរបស់កូនបំណុលដូចរថយន្តជាដើម ហើយគាត់បានចុះទៅស្ថាប័នដែលពាក់ព័ន្ធដើម្បីឱ្យមន្ត្រីសាធារណៈជួយស្វែងរកអត្តសញ្ញាណរបស់រថយន្តនោះ ប៉ុន្តែមន្ត្រីសាធារណៈក៏មិនព្រមសហការជាមួយនឹងម្ចាស់បំណុលនោះទេ ព្រោះជាការរក្សាការសម្ងាត់របស់ឯកជនភាព។ ចំណែកឯ កូនបំណុលខ្លះ មានគោលបំណងគេចវេសមិនទទួលខុសត្រូវដោយមានចេតនាទុច្ចរិត ខិលខូច បានលួចលក់ ផ្ទេរ ឬ ចាត់ចែងតាមបែបផ្សេងទៀតចំពោះ ចលនវត្ថុដែលនឹងត្រូវអាជ្ញាសាលារឹបអូស មានដូចជាលក់មុននឹងការរឹបអូស ឬ ផ្ទេរទៅឱ្យតតិយជនជាដើម។ ការលួចចាត់ចែងបែបនេះ ធ្វើឱ្យអាជ្ញាសាលាបាត់បង់នូវកម្មវត្ថុដែលត្រូវរឹបអូស ហើយត្រូវស្វែងរកសញ្ញាណចលនវត្ថុផ្សេងទៀតដើម្បីធ្វើការរឹបអូសម្តងទៀត។ ម៉្យាងវិញទៀត ចលនវត្ថុរបស់កូនបំណុលខ្លះមិនសមាមាត្រ និងតម្លៃដោយចលនវត្ថុនោះមានភាពសឹករិចរិល បែកបាក់ និងមិនអាចយកមកប្រើប្រាស់បាន។ រីឯករណីខ្លះទៀត កូនបំណុលនៃការរឹបអូសមានការយល់ដឹងខ្ពស់បានលួចចាត់ចែង ឬ លក់នូវចលនវត្ថុដែលខ្លួនមានអស់តែម្តង ដែលធ្វើឱ្យម្ចាស់បំណុលពុំអាចរកអ្វីមករឹបអូសបានឡើយ។

ឧទាហរណ៍៖ លោក ក បានដឹងជាមុនថានឹងមានការរឹបអូសនូវទ្រព្យរបស់ខ្លួនដោយអាជ្ញាសាលា ហើយ **លោក ក** មានមានគំនិតទុច្ចរិត និងខិលខូច ក៏បានផ្ទេរនូវទ្រព្យទាំងអស់របស់ខ្លួនទៅបងប្អូន ឬ សាច់ញាតិណាម្នាក់ ដែលជាហេតុធ្វើឱ្យអាជ្ញាសាលា ពុំអាចស្វែងរកចលនវត្ថុរបស់ខ្លួនមករឹបអូសជាបណ្តោះអាសន្នបាននាំឱ្យការសម្រេចសិទ្ធិទាមទាររបស់ម្ចាស់បំណុលមានការយឺតយ៉ាវ ឬ មិនអាចដំណើរការនីតិវិធីរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុនោះបានតែម្តង ព្រោះថាអាជ្ញាសាលាមិនអាចធ្វើការរឹបអូសនូវចលនវត្ថុដែលកាន់កាប់ដោយបុគ្គលផ្សេងក្រៅពីកូនបំណុលបានឡើយ។

១.៥ ទម្ងន់អន្តរាគមន៍ពីសំណាក់អ្នកមានអំណាច

វប្បធម៌អន្តរាគមន៍ពីសំណាក់អ្នកមានអំណាច តែងតែកើតឡើងជារឿយៗក្នុងសង្គមសព្វថ្ងៃ។ ក្នុងដំណើរនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ ករណីខ្លះកូនបំណុលនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្នដែលមានជាប់ខ្សែស្រឡាយជាមួយអ្នកមានឋានៈបុណ្យសក្តិធំក្នុងជួរមន្ត្រីរាជការ ឬ អ្នកមានមុខមាត់ក្នុងសង្គមបានសុំឱ្យមានការអន្តរាគមន៍ពីសំណាក់អ្នកមានអំណាចទាំងនោះ នាំឱ្យដំណើរការនៃនីតិវិធីរឹបអូសជាបណ្តោះអាសន្នមានការយឺតយ៉ាវ និងមានភាពរាំងស្ទះ។ គេសង្កេតឃើញជារឿយៗ កូនបំណុលនៃការអនុវត្តតែងតែមានការកាងពីអ្នកមានអំណាចមួយចំនួនតូច ដូចជាការយកកងកម្លាំងមកការារាំង ដល់ការអនុវត្តរបស់ស្ថាប័នអនុវត្ត។

ដូច្នេះ ការអនុវត្តរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុដែលអាជ្ញាសាលាបានរឹបអូសត្រូវបានផ្អាក ជាហេតុនាំឱ្យការអនុវត្តរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុនោះមិនបានជោគជ័យ។

១.៦ ការចំណាយច្រើនលើបន្ទុកសោហ៊ុយរបស់ម្ចាស់បំណុល

ជាការពិតណាស់ ដើម្បីអនុវត្តការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ ម្ចាស់បំណុលត្រូវទទួលខុសត្រូវច្រើននៅលើបន្ទុកសោហ៊ុយ ដូចជាពន្ធដាក់ពាក្យសុំ ប្រាក់ប្រដាប់ក្តីក្រៅពីពន្ធ សោហ៊ុយធ្វើដំណើរ និងសោហ៊ុយរដ្ឋបាលផ្សេងៗទៀតជាច្រើន។ ដូចនេះការស្វែងរកអត្តសញ្ញាណចលនវត្ថុរបស់កូនបំណុល គឺជាបន្ទុកសោហ៊ុយរបស់ម្ចាស់បំណុល ដោយហេតុថាច្បាប់បានផ្តល់បន្ទុកហានិភ័យនេះ ចំពោះម្ចាស់បំណុលក្នុងស្វែងរកដើម្បីទទួលបានការការពារនូវសិទ្ធិ និងផលប្រយោជន៍តាមផ្លូវច្បាប់របស់ខ្លួន។ លើសពីនេះម្ចាស់បំណុលពុំមានចំណេះដឹងផ្នែកច្បាប់ ឬ ការយល់ដឹងផ្នែកច្បាប់នៅមានកម្រិត ដើម្បីដំណើរការនីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុឱ្យមានដំណើរការទៅបានរលូន និងប្រកបដោយប្រសិទ្ធភាពខ្ពស់ ម្ចាស់បំណុលគប្បីស្វែងរកសេវាផ្នែកច្បាប់ពីមេធាវីសម្រាប់ពិគ្រោះយោបល់ និងតំណាងឱ្យខ្លួននៅក្នុងនីតិវិធីរក្សាការពារជៀសវាងការធ្វើសកម្មភាពណាមួយ ដែលខូចខាតនូវផលប្រយោជន៍តាមផ្លូវច្បាប់របស់ខ្លួន។ ម្ចាស់បំណុលត្រូវស្វែងរកបុគ្គលដែលមានវិជ្ជាជីវៈផ្នែកច្បាប់ ហើយជាបុគ្គលដែលច្បាប់អនុញ្ញាតឱ្យផ្តល់សេវាផ្នែកច្បាប់នោះជាមេធាវី។ ប៉ុន្តែ ហេតុថាមេធាវី ជាបុគ្គលឯកជនមិនមែនជាមន្ត្រីរាជការ ដូច្នេះម្ចាស់បំណុលចាំបាច់ត្រូវចំណាយប្រាក់ផ្ទាល់ខ្លួន ដើម្បីពឹងពាក់សេវាមេធាវីសម្រាប់ការពារផលប្រយោជន៍តាមផ្លូវច្បាប់របស់ខ្លួន។

ផ្នែកទី២៖ ដំណោះស្រាយ

នីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ ជាវិធានការមួយដើម្បីការពារជាបណ្តោះអាសន្ននូវសិទ្ធិរបស់ម្ចាស់បំណុល ដែលម្ចាស់បំណុលបានដាក់ពាក្យសុំរឹបអូសជាបណ្តោះអាសន្នទៅតុលាការ ដែលមានសមត្ថកិច្ច ក្នុងគោលបំណងការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ខ្លួនមុនទទួលបានបណ្តឹងអង្គសេចក្តីនេះជាមធ្យោបាយសង្គ្រោះដ៏ល្អមួយសម្រាប់ម្ចាស់បំណុល។ ទោះបីជាម្ចាស់បំណុល ឬ អ្នកដាក់ពាក្យសុំបានសម្រេចគោលបំណងក្នុងការរឹបអូសជាបណ្តោះអាសន្ន និងបំពេញទៅតាមលក្ខខ័ណ្ឌដែលច្បាប់បានកំណត់ក៏ដោយ ក៏បញ្ហាប្រឈមតែងតែជួបប្រទះជានិច្ច ដើម្បីបញ្ចៀសនូវបញ្ហាទាំងអស់នេះ ថែមទាំងជួយសម្រួលដល់ការអនុវត្តរាជរដ្ឋាភិបាល និងស្ថាប័នមានសមត្ថកិច្ច ដែលបានយកចិត្តទុកដាក់ជាខ្លាំងប្រឹងប្រែងបង្កើតនូវលិខិតបទដ្ឋានគតិយុត្តនានាដែលជាប់ពាក់ព័ន្ធ និងជំរុញក្នុងការផ្សព្វផ្សាយច្បាប់ដែលពាក់ព័ន្ធជាសាធារណៈ និងបើកវគ្គសិក្ខាសាលាខ្លីៗជូនទៅដល់មន្ត្រីដែលពាក់ព័ន្ធ។

២.១ ការបង្កើតលិខិតបទដ្ឋានគតិយុត្តបន្ថែម

ច្បាប់បានដើរតួនាទីយ៉ាងសំខាន់ដល់ការជួយសម្របសម្រួល និងដោះស្រាយនូវបញ្ហាដែលបានកើតមាន

ឡើងដោយសារទំនាស់ផលប្រយោជន៍។ បន្ថែមពីនេះ ដោយមានការយកចិត្តទុកដាក់ពីសំណាក់រាជរដ្ឋាភិបាល ជាពិសេសស្ថាប័នមានសមត្ថកិច្ច ក្រសួងយុត្តិធម៌ និងស្ថាប័នផ្សេងៗ ដែលជាប់ពាក់ព័ន្ធដោយបានខិតខំប្រឹងប្រែងបង្កើតនូវលិខិតបទដ្ឋានគតិយុត្តជាច្រើន ដើម្បីបំពេញបន្ថែមក្នុងការអនុវត្តប្រកបដោយប្រសិទ្ធិភាពក្នុងនោះ រួមមាន ប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី និងប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី,ប្រកាសស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ហើយនៅក្នុងឆ្នាំ២០០៨ដោយសារកង្វះខាតនូវមន្ត្រីអាជ្ញាសាលា សាលាភូមិន្ទអាជ្ញាសាលាក៏ត្រូវបានបង្កើតឡើង ចំពោះលិខិតបទដ្ឋានគតិយុត្តដូចដែលបានរៀបរាប់ខាងលើនេះ គឺបង្កើតក្នុងគោលបំណងដើម្បីសម្រួលដល់ការចាត់ចែងរក្សាការពារ និងអនុវត្តចាត់ចែងរក្សាការពារប្រកបដោយ ប្រសិទ្ធិភាព ភាពយុត្តិធម៌ ថែមទាំងជាការអភិវឌ្ឍន៍លើកកម្ពស់វិស័យច្បាប់ស៊ីវិលឱ្យកាន់តែមានភាពល្អប្រសើរជាលំដាប់ផងដែរ ប៉ុន្តែច្បាប់មិនទាន់គ្រប់គ្រាន់នៅឡើយ។ ដូចនេះ ក្រសួង ឬ ស្ថាប័នដែលពាក់ព័ន្ធត្រូវយកចិត្តទុកដាក់បង្កើតបន្ថែមនូវច្បាប់ស្តីពីលក្ខន្តិក:អាជ្ញាសាលា និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗដែលពាក់ព័ន្ធទៅនឹងក្រមសីលធម៌របស់អាជ្ញាសាលា ឬ ក្រមសីលធម៌របស់មន្ត្រីអនុវត្តផ្សេងទៀត ដើម្បីបង្កើនប្រសិទ្ធិភាពទ្វេដងក្នុងការអនុវត្តច្បាប់ ជាពិសេសបញ្ហាត្តិដែលពាក់ព័ន្ធទៅនឹងនីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ ជាដើម។

២.២ ការផ្សព្វផ្សាយច្បាប់ជាសាធារណៈ

ការផ្សព្វផ្សាយច្បាប់ គឺជាយន្តការមួយដែលរដ្ឋកំពុងតែបំផុសបំផុល ឬ ផ្សព្វផ្សាយ ដើម្បីឱ្យប្រជាពលរដ្ឋបានយល់ដឹងអំពីច្បាប់។ ក៏ប៉ុន្តែ ការផ្សព្វផ្សាយច្បាប់ភាគច្រើន គឺមាននៅតាមបណ្តាសាកលវិទ្យាល័យច្បាប់តែប៉ុណ្ណោះ ហេតុនេះមានតែនិស្សិតច្បាប់ទេ ទើបអាចទទួលបានចំណេះដឹងផ្នែកច្បាប់បានច្រើន។ ដូច្នេះ ដើម្បីពង្រីកនូវការផ្សព្វផ្សាយនោះឱ្យកាន់តែមានភាពទូលំទូលាយ ក៏ដូចជាលើកកម្ពស់វិស័យច្បាប់ឱ្យកាន់តែមានភាពរីកចម្រើន ក្រសួងយុត្តិធម៌ គណៈមេធាវីនៃព្រះរាជណាចក្រកម្ពុជា និងស្ថាប័នមានសមត្ថកិច្ចត្រូវផ្សព្វផ្សាយច្បាប់ឱ្យបានច្រើន ជាពិសេសនោះ គឺដំណើរការនីតិវិធីក្នុងរឿងក្តីរដ្ឋប្បវេណី តាមរយៈសិក្ខាសាលាអនឡាញ ទូរទស្សន៍ និងបណ្តាញទំនាក់ទំនងសង្គម ជាអាទិ៍។ ដោយហេតុថាការផ្សព្វផ្សាយច្បាប់ភាគច្រើនមានតែច្បាប់រដ្ឋធម្មនុញ្ញ រឿងក្តីព្រហ្មទណ្ឌ និងការលែងលះ តែមិនសូវបានផ្សព្វផ្សាយពាក់ពន្ធទៅនឹងនីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ ដែលជានីតិវិធីមួយមានលក្ខណៈស្មុគស្មាញ។ ដូចនេះ ដើម្បីអាចបញ្ជ្រាបការផ្សព្វផ្សាយចូលក្នុងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋបានច្រើន គឺត្រូវផ្សព្វផ្សាយតាមរយៈបណ្តាញសង្គម ព្រោះប្រជាពលរដ្ឋភាគច្រើន និយមចូលចិត្តនូវការប្រើប្រាស់បណ្តាញសង្គមសម្រាប់ប្រកបអាជីវកម្មអនឡាញ ឬ ដើម្បីការកម្សាន្តអារម្មណ៍។ ការផ្សព្វផ្សាយច្បាប់តាមរយៈប្រព័ន្ធបណ្តាញសង្គម គឺជាវិធីដ៏ល្អមួយដែលអាចផ្សព្វផ្សាយច្បាប់បានទូលំទូលាយ ហើយទទួលបានសមិទ្ធផលច្រើន។ កាលណាបើប្រជាពលរដ្ឋមានចំណេះដឹងផ្នែកច្បាប់សមរម្យ

ហើយ នោះការបំពានច្បាប់ ក៏មានការកាត់បន្ថយផងដែរ ហើយការអនុវត្តច្បាប់របស់ស្ថាប័នអនុវត្តក៏មានភាពងាយស្រួល និងឆាប់រហ័សដូចគ្នា។ រីឯ ក្រសួង ឬ ស្ថាប័នដែលពាក់ព័ន្ធទៅនឹងការផ្សព្វផ្សាយ ឬ ការអនុវត្តច្បាប់គួរណាស់តែជម្រុញលើកទឹកចិត្តទៅដល់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានមិនថា កសិករ អាជីវករ ពាណិជ្ជករ និងអ្នកសិក្សាផ្នែកច្បាប់ឱ្យពួកគាត់មានការសិក្សាស្វែងយល់អំពីនីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុឱ្យបានច្រើន។

២.៣ ការបណ្តុះបណ្តាលមន្ត្រីអនុវត្តរឹបអូសជាបណ្តោះអាសន្ន

ជាការពិតណាស់ការអនុវត្តរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុមានភាពស្មុគស្មាញពីព្រោះចលនវត្ថុមានភាពលំបាកខ្លាំងក្នុងការរឹបអូស។ ដូច្នេះ កត្តាចំណេះដឹងរបស់មន្ត្រីអនុវត្តត្រូវតែមានភាពច្បាស់លាស់ និងម៉ឺងម៉ាត់នៅក្នុងការអនុវត្ត ដូចជា ការពង្រឹងបន្ថែមទៅលើចំណេះដឹងរបស់មន្ត្រីអនុវត្ត ក្រសួងយុត្តិធម៌ គួរតែមានការពិនិត្យទៅលើរបាយការណ៍ការងាររបស់មន្ត្រីអនុវត្តឱ្យបានទៀងទាត់ និងបង្កើតវគ្គបណ្តុះបណ្តាលខ្លីៗអំពីការអនុវត្តរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ ដើម្បីពង្រឹងបន្ថែមពាក់ព័ន្ធនឹងនីតិវិធីនេះទៅដល់មន្ត្រីដែលទទួលបន្ទុកអនុវត្ត។ ជាពិសេសការចែករំលែកនូវចំណេះដឹង និងបទពិសោធន៍ពីសំណាក់មន្ត្រីអនុវត្តដែលមានបទពិសោធន៍ច្រើនពាក់ព័ន្ធជាមួយនឹងនីតិវិធីរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុនេះជាការពង្រឹងក៏ ដូចជាផ្តល់ចំណេះដឹងពាក់ព័ន្ធនឹងនីតិវិធីនេះដ៏មានប្រសិទ្ធិភាពបំផុត។

ឧទាហរណ៍៖ អាជ្ញាសាលា ដែលបានឆ្លងកាត់ការអនុវត្តរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុច្រើនគួរតែចែករំលែកនូវចំណេះដឹង និងបទពិសោធន៍របស់ខ្លួនទៅកាន់អាជ្ញាសាលាដែលទើបចុះអនុវត្តថ្មីៗពីការបណ្តុះបណ្តាលនៅសាលា ហើយមកកាន់តួនាទីនៅសាលាដំបូង។

២.៤ ការបង្កើតយន្តការក្នុងការស្វែងរកចលនវត្ថុរបស់កូនបំណុល

ជាទូទៅ កូនបំណុលខ្លះដែលមានចេតនាទុច្ចរិត និងខិលខូចបានយកទ្រព្យដែលជាចលនវត្ថុរបស់ខ្លួនទៅលាក់ទុក ឬ ធ្វើការលួចផ្ទេរទ្រព្យទៅឱ្យតតិយជនដែលជាសាច់ញាតិខ្លួន ដែលធ្វើឱ្យម្ចាស់បំណុលមានភាពលំបាកស្វែងរកទ្រព្យនោះ ហេតុនេះហើយក្រសួង ឬ ស្ថាប័នដែលពាក់ពន្ធត្រូវបង្កើតយន្តការសម្រាប់ការអនុវត្តរឹបអូសលើចលនវត្ថុ ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការអនុវត្ត។ នៅពេលដែលចុះទៅអនុវត្តរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ អាជ្ញាសាលា និងម្ចាស់បំណុលតែងតែជំរុញឱ្យកូនបំណុលអនុវត្តដោយស្ម័គ្រចិត្តលើទ្រព្យរបស់ខ្លួន ប៉ុន្តែកូនបំណុលតែងតែគេចវេសមិនព្រមអនុវត្តគោលការណ៍ស្ម័គ្រចិត្តតាមការស្នើសុំរបស់អាជ្ញាសាលា និងម្ចាស់បំណុលនោះឡើយ។ ដូច្នេះ ហើយទើបធ្វើឱ្យម្ចាស់បំណុលពិបាកក្នុងការស្វែងរកទ្រព្យជាចលនវត្ថុរបស់កូនបំណុល ដែលត្រូវធ្វើការស្នើសុំឱ្យមន្ត្រី ឬ ស្ថាប័នដែលពាក់ព័ន្ធចូលរួមក្នុងការផ្តល់ជាឯកសារ និងបញ្ចេញព័ត៌មានពីអត្តសញ្ញាណទ្រព្យនោះ។ ទោះបីជាមានការចូលរួមយ៉ាងសកម្មពីសំណាក់មន្ត្រីអនុវត្តក៏

ដោយ ក៏ការអនុវត្តរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ ពេលខ្លះមិនអាចប្រព្រឹត្តទៅបាន ឬ អនុវត្តបាននោះទេ ប្រសិនបើមិនមានការចូលរួមសហការពីស្ថាប័នពាក់ព័ន្ធមួយចំនួន ក្នុងន័យនេះ យើងសំដៅដល់ទាំងអាជ្ញាធរភូមិ-ឃុំ ស្នងការខេត្ត/ក្រុង កងរាជអាវុធហត្ថ ជាដើម ដែលជាជំនួយដល់ការអនុវត្តនីតិវិធីនេះឱ្យបានរលូន។ ពាក់ព័ន្ធនឹងការចុះស្រាវជ្រាវ ក៏ដូចជាការរឹបអូសចលនវត្ថុ ករណីមួយចំនួនដែលពិបាកក្នុងការធ្វើការអ្នកអនុវត្តតែងតែមានការស្នើកងកម្លាំងសាធារណៈ ដើម្បីការពារ ឬ ទប់ស្កាត់ហេតុការណ៍អាក្រក់កើតឡើងជាយថាហេតុ (ការរារាំងពីសំណាក់អ្នកមានអំណាច ឬ បញ្ហាផ្សេងទៀត)។ ដូច្នេះ ការបង្កើតយន្តការនេះឡើងគឺដើម្បីឱ្យកងកម្លាំងសាធារណៈមានកិច្ចសហប្រតិបត្តិការប្រកបដោយស្មារតីសហការខ្ពស់ជាមួយអ្នកអនុវត្ត។ ដើម្បីពង្រឹងកិច្ចសហការរវាងមន្ត្រីអនុវត្ត ជាមួយនឹងអាជ្ញាធរ មូលដ្ឋាន ក្រសួង ឬ ស្ថាប័ន គួរតែមានវិធានការតឹងរឹង ចំពោះមន្ត្រីដែលមិនចូលរួមសហការជាមួយមន្ត្រីអនុវត្តដូចជាការដាក់ពិន័យ ឬ ការដាក់ទណ្ឌកម្មរដ្ឋបាលជាដើម។

២.៥ លុបបំបាត់ឥទ្ធិពលអន្តរាគមន៍ពីសំណាក់អ្នកមានអំណាច

ទោះបីជាវប្បធម៌អន្តរាគមន៍ពីសំណាក់អ្នកមានអំណាចតែងតែកើតឡើងជារឿយៗ ដែលជាបញ្ហាមួយធ្វើឱ្យមានការរារាំងស្ទះដល់នីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុក៏ដោយ ប៉ុន្តែ បច្ចុប្បន្នវប្បធម៌អន្តរាគមន៍នេះគួរតែបញ្ចប់ ការអន្តរាគមន៍ពីអ្នកមានអំណាច បុណ្យស័ក្តិ រារាំងដល់ការអនុវត្តរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ គឺជាអំពើដែលធ្វើឱ្យរាំងស្ទះដល់ការអនុវត្តច្បាប់ និងជាការចូលដៃដល់ជនបានប្រព្រឹត្តអំពើខុសច្បាប់។ កាលណាសង្គមមួយសម្បូរទៅដោយការអន្តរាគមន៍មិនត្រឹមត្រូវ គឺជាការជួយជ្រោមជ្រែងអំពើខុសច្បាប់មានន័យថាជួយឱ្យច្បាប់មិនត្រូវបានអនុវត្តដោយប្រសិទ្ធភាព។

ដើម្បីទប់ស្កាត់ និងបញ្ឈប់វប្បធម៌អន្តរាគមន៍ ស្ថាប័ន ឬ អង្គភាពត្រូវតែមានវិធានការតឹងរឹង និងអនុវត្តឱ្យបានម៉ឺងម៉ាត់ចំពោះមន្ត្រីរបស់ខ្លួនដែលបានប្រើប្រាស់អំណាចក្នុងមុខងារទៅកាងចំពោះអំពើប្រព្រឹត្តខុសច្បាប់។

ជាពិសេសទៅទៀត ស្ថាប័នអនុវត្តក៏ពុំត្រូវស្តាប់ ឬ ធ្វើតាមការបញ្ជារពីសំណាក់អ្នកមានអំណាចដែលបានធ្វើការអន្តរាគមន៍ទៅលើការអនុវត្តការងាររបស់ខ្លួន។

២.៦ ការបង្កើតយន្តការក្នុងការកាត់បន្ថយបន្ទុកសោហ៊ុយចំណាយរបស់ម្ចាស់បំណុល

ជាគោលការណ៍ ម្ចាស់បំណុលត្រូវចំណាយបន្ទុកសោហ៊ុយច្រើននៅក្នុងការអនុវត្តរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ ដើម្បីជាយន្តការកាត់បន្ថយចំណាយម្ចាស់បំណុលអាចស្វែងរកសេវាប្រឹក្សាផ្នែកច្បាប់ដោយឥតគិតថ្លៃពីសំណាក់អ្នកច្បាប់ ឬ ក៏មេធាវីស្ម័គ្រចិត្តដែលជួយក្នុងរឿងរដ្ឋប្បវេណីដូចជា មេធាវីរបស់ក្រសួងយុត្តិធម៌ មេធាវីរបស់ក្រសួងមហាផ្ទៃ និងមេធាវីតាមបណ្តាសាលាខណ្ឌជាដើម។ ដើម្បីទទួលសេវាប្រឹក្សាយោបល់ផ្នែកច្បាប់ និង

ធ្វើជាអ្នកតំណាងដោយអាណត្តិ ប្រសិនបើម្ចាស់បំណុលពុំមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការស្វែងរកសេវាច្បាប់ពីសំណាក់មេធាវីឯកជន។

ទន្ទឹមនឹងនេះ ម្ចាស់បំណុលអាចស្វែងរកសេវាផ្នែកច្បាប់ផ្សេងៗទៀតពីសំណាក់អ្នកច្បាប់ ឬ មេធាវីដែលស្ម័គ្រចិត្ត ផ្តល់សេវាការពារក្តីដោយឥតគិតកម្រៃប្រចាំសាលាដំបូងរាជធានីខេត្ត និងតុលាការជាន់ខ្ពស់ ដើម្បីអាចជួយសម្រាលបន្ទុកសោហ៊ុយសម្រាប់ម្ចាស់បំណុល។ លើសពីនេះទៅទៀត ដើម្បីកាត់បន្ថយការចំណាយសោហ៊ុយក្នុងការចុះបញ្ជីរឹបអូសជាបណ្តោះអាសន្ន រដ្ឋត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តដែលចែងពីកម្រៃសេវាសាធារណៈក្នុងការចុះបញ្ជីរឹបអូសជាបណ្តោះអាសន្នឱ្យបានជាក់លាក់នឹងការបញ្ជូនដីកាឱ្យមានភាពច្បាស់លាស់។

ដូច្នេះ ដើម្បីកាត់បន្ថយបន្ទុកសោហ៊ុយធ្វើដំណើររបស់ភាគីតុលាការមិនត្រូវធ្វើការកោះហៅសាកសួរភាគីជាច្រើនលើកជាច្រើនសារ និងមិនត្រូវពន្យាពេលក្នុងការសម្រេចសេចក្តីលើពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុនោះឡើយ។

សេចក្តីសន្និដ្ឋាន

សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការស្រាវជ្រាវលើប្រធានបទ **"នីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ"** រួចមក យើងអាចសន្និដ្ឋានបានថា នីតិវិធីនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ គឺជានីតិវិធីមួយដែលមានលក្ខណៈបណ្តោះអាសន្ន ដើម្បីការពារផលប្រយោជន៍របស់ម្ចាស់បំណុលនៅពេលដែលមានការបារម្ភថាការអនុវត្តដោយបង្ខំមិនអាចធ្វើទៅបាន ឬ ការសម្រេចនូវសិទ្ធិទាមទាររបស់ម្ចាស់បំណុលមិនអាចប្រព្រឹត្តទៅបានដោយសារតែការផ្លាស់ប្តូរស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុល ឬ អាចនិយាយម្យ៉ាងទៀតបានថាដើម្បីរក្សាឱ្យបានស្ថិតស្ថេរមិនឱ្យកូនបំណុលធ្វើការផ្ទេរកម្មសិទ្ធិបាន ដើម្បីធានាដល់សិទ្ធិលើការទាមទាររបស់ម្ចាស់បំណុលនៅក្នុងករណីដែលមានការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ ដោយសារតែមានវិវាទទាក់ទងទៅនឹងសិទ្ធិទើបមានការរឹបអូសជាបណ្តោះអាសន្នលើវត្ថុដែលមានវិវាទ ដើម្បីទទួលបានសំណងក្នុងករណីដែលកូនបំណុលគេចវេសមិនទទួលខុសត្រូវ។ ការរឹបអូសជាបណ្តោះអាសន្ន បើយើងសង្កេតមើលទៅលើវាហាក់ដូចជាការពារសិទ្ធិរបស់ម្ចាស់បំណុលខ្លាំងណាស់ ក៏ប៉ុន្តែគឺដើម្បីការពារពីចេតនាទុច្ចរិតរបស់កូនបំណុលក្នុងការចាត់ចែងទ្រព្យសម្បត្តិដើម្បីឱ្យរួចផុតពីការអនុវត្តដោយបង្ខំ ហើយយើងក៏អាចនិយាយបានដែរថា វាដូចជាសមហេតុផល និងត្រឹមត្រូវដែរ។ ការរឹបអូសជាបណ្តោះអាសន្ន គឺគ្រាន់តែកម្រិតនៅសិទ្ធិចាត់ចែងរបស់កូនបំណុលតែប៉ុណ្ណោះ ហើយគេមិនបានបិទសិទ្ធិរបស់កូនបំណុលក្នុងការតវ៉ាសេចក្តីសម្រេចរបស់តុលាការនោះទេ ពោល គឺកូនបំណុលអាចប្តឹងតវ៉ាចំពោះដីការក្សាការពារដែលធ្វើចំពោះការរឹបអូសជាបណ្តោះអាសន្នបាន ប្រសិនបើខ្លួនយល់ឃើញថាការសម្រេចសេចក្តីនោះធ្វើឡើងដោយមានភាពអយុត្តិធម៌។ ការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ កម្រិតនូវសិទ្ធិសេរីភាពរបស់កូនបំណុលនៅក្នុងការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួន ប្រសិនបើតុលាការបានធ្វើការវិនិច្ឆ័យ និងសម្រេចសេចក្តីចំពោះពាក្យសុំរបស់ម្ចាស់បំណុលដោយផ្អែកទៅលើសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត និងភាពចាំបាច់នានាដែលជាលក្ខខ័ណ្ឌចាំបាច់សម្រាប់ការចេញដីកាសម្រេចនោះ បើពិនិត្យមើលលក្ខខ័ណ្ឌមានគ្រប់ តុលាការចេញដីកាសម្រេចនោះ មានន័យថាការសម្រេចសេចក្តីនោះត្រឹមត្រូវ ព្រោះដើម្បីការពារការលួចចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុលដោយចេតនាទុច្ចរិត ក្នុងការគេចវេសពីការទទួលខុសត្រូវនៅក្នុងការអនុវត្តកាតព្វកិច្ចចំពោះម្ចាស់បំណុល។

សរុបសេចក្តីមក នីតិវិធីនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ បានផ្តល់គុណសម្បត្តិជាច្រើន ព្រោះថាវាជានីតិវិធីដែលមានលក្ខណៈជាបណ្តោះអាសន្ន និងមានភាពឆាប់រហ័សដោយមិនចាំបាច់រង់ចាំរហូតដល់សាលក្រម ឬ សាលដីកាចូលជាស្ថាពរ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ភាគីដែលអាចនឹងទទួលនូវការខូចខាត ឬ ខាតបង់ដែលអាចនឹងកើតឡើងជាក់ជាពុំខាន បើមិនប្រញាប់ធ្វើការរឹបអូសជាបណ្តោះអាសន្នឱ្យបានទាន់ពេលវេលានោះទេ។

អនុសាសន៍

អនុសាសន៍

ឆ្លងកាត់តាមការសិក្សា និងស្រាវជ្រាវយ៉ាងស៊ីជម្រៅអំពីប្រធានបទស្តីពី **ការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ** ឃើញថាការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ មានការកើតឡើងច្រើននៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន។ ទោះបីជាក្នុងជំពូកទី៣ យើងខ្ញុំបានរៀបរាប់អំពីបញ្ហាប្រឈម និងដំណោះស្រាយដែលយើងខ្ញុំបានសរសេរមកហើយក្តី ប៉ុន្តែក្នុងនីតិវិធីរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុនៅតែមានភាពចន្លោះខ្វះខាតដែលត្រូវដោះស្រាយបន្ថែម ដើម្បីឱ្យដំណើរការនីតិវិធីនេះរលូនទៅមុខ និងការពារដល់ផលប្រយោជន៍របស់អ្នកដែលបាត់បង់ផលប្រយោជន៍ ជាពិសេសម្ចាស់បំណុលក្នុងនីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុដែលជានីតិវិធីមានការលំបាក និងស្មុគស្មាញខ្លាំង ដែលតម្រូវឱ្យអ្នកសិក្សាផ្នែកច្បាប់ សិស្ស និស្សិត អ្នកអនុវត្តច្បាប់ និងសាធារណៈជនគ្រប់មជ្ឈដ្ឋាន គួរគប្បីស្វែងយល់ និងចេះឱ្យបានច្បាស់លាស់អំពីនីតិវិធីនេះ ដើម្បីពង្រឹងសមត្ថភាព និងជាប្រយោជន៍សម្រាប់ខ្លួនឯងនាពេលអនាគត។ ទន្ទឹមនឹងនេះយើងខ្ញុំក៏បានសង្កេតឃើញថា ក្នុងនាមយើងជាអ្នកច្បាប់ត្រូវពង្រីកសមត្ថភាព និងចូលរួមផ្សព្វផ្សាយច្បាប់នោះឱ្យកាន់តែទូលំទូលាយ ក៏ដូចជាលើកកម្ពស់វិស័យច្បាប់ឱ្យកាន់តែរីកចម្រើន ព្រមទាំងក្រសួងយុត្តិធម៌ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងស្ថាប័នមានសមត្ថកិច្ចត្រូវផ្សព្វផ្សាយច្បាប់ឱ្យបានច្រើន ជាពិសេសនោះ គឺដំណើរការនីតិវិធីក្នុងរឿងក្តីរដ្ឋប្បវេណីតាមរយៈសិក្ខាសាលាផ្ទាល់ និងតាមអនឡាយ ទូរទស្សន៍ បណ្តាញទំនាក់ទំនងសង្គម និង មាតិកាពិភាក្សាផ្លាស់ប្តូរយោបល់ ជាដើម។

ទោះបីជាក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ បានប្រកាសឱ្យប្រើអស់រយៈពេលជាង១០ឆ្នាំមកហើយ ប៉ុន្តែយើងសង្កេតឃើញថានីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្ននៅមានភាពខ្វះចន្លោះ និងមានបញ្ហាជាច្រើននៅតែបន្តកើតមាននៅក្នុងសង្គមបច្ចុប្បន្ន ដូច្នេះយើងខ្ញុំសូមចូលរួមផ្តល់នូវមតិ និងយោបល់មួយចំនួន ក្នុងគោលបំណងដើម្បីជួយដល់សង្គមជាតិទាំងមូលព្រមទាំងសិស្ស និស្សិត អ្នកសិក្សាផ្នែកច្បាប់ និងប្រជាពលរដ្ឋនូវចំណុចមួយចំនួនដូចជា បច្ចុប្បន្ននេះតួនាទីរបស់ដោយព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ត្រូវបានជំនួសនៅតាមសាលាដំបូងរាជធានី-ខេត្តដែលមិនទាន់មានអាជ្ញាសាលា ដើម្បីសម្រាលការងាររបស់ព្រះរាជអាជ្ញាដែលមានច្រើន ព្រមទាំងដើម្បីផ្តល់សិទ្ធិអំណាចដល់អាជ្ញាសាលាដែលត្រូវបានជ្រើសរើស គប្បីពន្លឿនការអនុម័តច្បាប់ស្តីពីលក្ខន្តិកៈអាជ្ញាសាលានេះ ហើយចាត់តាំងអាជ្ញាសាលាទៅបំពេញមុខងាររបស់ខ្លួនឱ្យមានប្រសិទ្ធិភាពស្របតាមក្រមនីតិវិធីរដ្ឋប្បវេណី និងលិខិតបទដ្ឋានគតិយុត្តិជាធរមានផ្សេងៗទៀត។ ជាងនេះទៅទៀត ក្រសួងយុត្តិធម៌គួរតែបង្កើតសិក្ខាសាលា ឬ បទបង្ហាញឱ្យបានច្រើនពាក់ព័ន្ធទៅនឹងផ្នែកច្បាប់ ដើម្បីឱ្យអ្នកសិក្សាស្រាវជ្រាវច្បាប់គ្រប់មជ្ឈដ្ឋានបានសិក្សាស្វែងយល់ឱ្យកាន់តែស៊ីជម្រៅ និងធ្វើការផ្សព្វផ្សាយចូលទៅក្នុងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋបានច្រើន ព្រោះថាប្រជាពលរដ្ឋភាគច្រើននិយមប្រើប្រាស់បណ្តាញសង្គម ដូច្នេះនេះគឺជាវិធីដ៏ល្អ

មួយដែលអាចផ្សព្វផ្សាយច្បាប់បានទូលំទូលាយហើយទទួលបានសមិទ្ធផលច្រើន។ កាលណាដែលប្រជាពលរដ្ឋមានចំណេះដឹងផ្នែកច្បាប់សមរម្យ ហើយការបំពានច្បាប់ក៏មានការកាត់បន្ថយ ការអនុវត្តច្បាប់របស់ស្ថាប័នអនុវត្តក៏មានភាពងាយស្រួលនិងឆាប់រហ័សផងដែរ។ ចំណែកឯ មន្ត្រីដែលពាក់ព័ន្ធទៅនិងការរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុគួរតែពង្រឹងនូវចំណេះដឹងរបស់ខ្លួនឱ្យកាន់តែល្អប្រសើរ។ រីឯ អាជ្ញាសាលាដែលទទួលបន្ទុកលើការអនុវត្តរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ គួរតែមានការពង្រឹងបន្ថែមទៀតទៅលើចំណេះដឹងរបស់មន្ត្រីអនុវត្ត ក្រសួងយុត្តិធម៌គួរតែមានការពិនិត្យទៅលើរបាយការណ៍ការងាររបស់មន្ត្រីអនុវត្តឱ្យបានទៀងទាត់ និងបង្កើតវគ្គបណ្តុះបណ្តាលខ្លី។ អំពីការអនុវត្តរឹបអូសជាបណ្តោះអាសន្នលើចលនវត្ថុ ដើម្បីពង្រឹងបន្ថែមពាក់ព័ន្ធនឹងនីតិវិធីនេះដល់មន្ត្រីដែលទទួលបន្ទុកអនុវត្ត។ ជាពិសេសបង្កើនការយល់ដឹងអ្នកអនុវត្តច្បាប់ដូចជា ចៅក្រម ក្រឡាបញ្ជី និងមេធាវីឱ្យបានយល់ច្បាស់ និងអនុវត្តឱ្យបានត្រឹមត្រូវ តាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី។ លើសពីនេះ ម្ចាស់បំណុលគប្បីប្រញាប់ប្រញាល់ក្នុងការដាក់ពាក្យសុំរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុដោយជៀសវាង និងបង្ការទុកពីហានិភ័យដែលកើតឡើងជាយថាហេតុដោយចេតនាទុច្ចរិតរបស់កូនបំណុលក្នុងការគេចវេសពីការទទួលខុសត្រូវចំពោះម្ចាស់បំណុល ព្រមទាំងក្នុងករណីដែលខ្លួនបានដឹងពីចេតនាទុច្ចរិតរបស់កូនបំណុល ហើយមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើទៅបាន ឬ មានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់ម្ចាស់បំណុល។ជាចុងក្រោយដើម្បីកាត់បន្ថយការចំណាយសោហ៊ុយក្នុងការចុះបញ្ជីរឹបអូសជាបណ្តោះអាសន្ន រដ្ឋត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តដែលចែងពីកម្រៃសេវាសាធារណៈ ក្នុងការចុះបញ្ជីរឹបអូសជាបណ្តោះអាសន្នឱ្យបានជាក់លាក់ និងការបញ្ជូនដីកាឱ្យមានភាពច្បាស់លាស់។

ដូច្នេះ ក្រោយពីបានសិក្សាស្រាវជ្រាវ និងរិះរកនូវបញ្ហាដែលត្រូវដោះស្រាយចំពោះប្រធានបទ **នីតិវិធីនៃការរឹបអូសបណ្តោះអាសន្នលើចលនវត្ថុ** កន្លងមក យើងខ្ញុំយល់ឃើញថាប្រធានបទនេះ ពិតជាមានសារៈសំខាន់យ៉ាងខ្លាំង និងបានចូលរួមការពារជនដែលត្រូវបានគេមករំលោភបំពានផលប្រយោជន៍ពិតប្រាកដមែន ហើយច្បាប់ក៏បានការពារជននោះបានយ៉ាងល្អប្រសើរថែមទៀតផង។

ភន្តិទ្វេស

គន្ថនិទ្ទេស

១.ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១, ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០០៤។
- ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/ ០៧០៦/០២១, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦។
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/ ១២០៧/០៣០. ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧។
- សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីភាគ២៖ ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ រៀបចំដោយក្រុមការងារជប៉ុន ដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការងារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៩។
- ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ រៀបចំដោយក្រុមការងារជប៉ុន ដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៨។
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី រៀបចំដោយក្រុមការងារជប៉ុន ដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៧។
- សេចក្តីព្រាងច្បាប់លើកទី ៣ ស្តីពីអាជ្ញាសាលា (កែសម្រួលដោយក្រុមប្រឹក្សាអ្នកច្បាប់ និងរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ) ឆ្នាំ២០១២។
- ប្រកាសស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាលេខ ៣០.កយប្រក/០៧, ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧ របស់ក្រសួងយុត្តិធម៌។
- ប្រកាសស្តីពីបែបបទសម្រាប់អនុវត្តការងាររបស់មន្ត្រីអាជ្ញាសាលា នៃក្រសួងយុត្តិធម៌លេខ ០៦២.កយប្រក/១៩, ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩។

ឧបសម្ព័ន្ធ

បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១	ពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន
ឧបសម្ព័ន្ធទី២	លិខិតតំណាងដោយអាណត្តិ
ឧបសម្ព័ន្ធទី៣	លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ
ឧបសម្ព័ន្ធទី៤	ពាក្យស្នើសុំឱ្យពិនិត្យភស្តុតាង
ឧបសម្ព័ន្ធទី៥	សេចក្តីបញ្ជាក់ដំបូង
ឧបសម្ព័ន្ធទី៦	ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ចំនួន ០៣ (បី) ច្បាប់
ឧបសម្ព័ន្ធទី៧	កំណត់ហេតុស្តីពីការអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ចំនួន ០២ (ពីរ) ច្បាប់
ឧបសម្ព័ន្ធទី៨	ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយ ព្រះរាជក្រម លេខ នស/ រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ធ្នូ ២០០៧
ឧបសម្ព័ន្ធទី៩	ប្រកាសស្តីពីបែបបទសម្រាប់អនុវត្តការងាររបស់មន្ត្រីអាជ្ញាសាលានៃក្រសួងយុត្តិធម៌លេខ ០៦២កយប្រក/១៩, ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ ២០១៩
ឧបសម្ព័ន្ធទី១០	ប្រកាសស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាលេខ ៣០.កយប្រក/ ០៧, ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០០៧ របស់ក្រសួងយុត្តិធម៌

ឧបសម្ព័ន្ធទី១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ.....

សំណើសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

I **អត្តសញ្ញាណរបស់គូភាគី**

សហម្ចាស់បំណុល ៖ យើងខ្ញុំឈ្មោះ: ភេទប្រុស អាយុ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ: និងឈ្មោះ: ភេទស្រី អាយុ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ: មានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅភូមិ សង្កាត់ ក្រុង ខេត្ត ។ ទូរស័ព្ទទំនាក់ទំនងលេខ:( )

អ្នកបំណុល ៖ ឈ្មោះ: ភេទប្រុស អាយុ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ: មានទីលំនៅស្ថិតនៅភូមិ ឃុំ ស្រុក ខេត្ត ។
ទូរស័ព្ទទំនាក់ទំនងលេខ:(/)

សូមគោរពជូន

ឯកឧត្តមប្រធានសាលាដំបូងខេត្តកំពង់ចាម

II **ខ្លឹមសារនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នដែលម្ចាស់បំណុលសូមអោយប្រកាសបញ្ជូន**

១. រឹបអូសជាបណ្តោះអាសន្ននូវរថយន្តម៉ាក HYUNDAI ពណ៌ ពាក់ផ្លាកលេខ: សើរី ឆ្នាំ ជាកម្មសិទ្ធិរបស់ឈ្មោះ: ។

២. ប្រាក់ប្រដាប់ក្តី គឺជាបន្ទុករបស់កូនបំណុល។

៣.ដីកាសម្រេចនេះមានអានុភាពអនុវត្តភ្លាម។

III **អង្គហេតុចាំបាច់ដើម្បីបញ្ជាក់អំពីសិទ្ធិ និងធំនាក់ធំនឹងគតិយុត្តដែលត្រូវអនុញ្ញាតការពារ**

កាលពីអំឡុងឆ្នាំ២០២១ រហូតដល់ ឆ្នាំ២០២២ កូនបំណុលឈ្មោះ: បានជំពាក់ប្រាក់យើងខ្ញុំ ថ្លៃទិញត្រីចំនួន **៣៣១២៦០០០ (សាមសិបបីលានមួយរយបីម្ភៃប្រាំមួយពាន់) រៀល** ដូចមាននៅក្នុងកិច្ចព្រមព្រៀងទទួលខុសត្រូវទូទាត់បង់ប្រាក់ដោយស្ម័គ្រចិត្តចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២។ កូនបំណុលឈ្មោះ: បានសងប្រាក់ថ្លៃទិញត្រីយើងខ្ញុំចំនួន **២៤០០០០០០ (ម្ភៃបួនលាន) រៀល** និងនៅសល់ប្រាក់ជំពាក់ចំនួន **១០០០,០០០ (ដប់លាន)រៀល** ដូចមានក្នុងលិខិត-ប្រគល់ប្រាក់ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២២។

លុះអំឡុងឆ្នាំ២០២៣ កូនបំណុលបានបន្តទិញត្រី និងជំពាក់ប្រាក់យើងខ្ញុំ ចំនួន **២៨៩៥៧០០០ (ម្ភៃប្រាំបីលានប្រាំបួនរយហាសិបប្រាំពីរពាន់) រៀល**។

ចាប់តាំងពីឆ្នាំ២០២១ រហូតដល់ ឆ្នាំ២០២៣ កូនបំណុលបានជំពាក់ប្រាក់ថ្លៃទិញត្រីទាំងថ្មី និងចាស់សរុបចំនួន **៣៨៩៥៧០០០ (សាមសិបប្រាំបីលានប្រាំបួនរយហាសិបប្រាំពីរពាន់)** ដូចមាននៅក្នុងតារាងបង់ប្រាក់។

បច្ចុប្បន្ន កូនបំណុលឈ្មោះ: ពុំបានអនុវត្តកាតព្វកិច្ចសងប្រាក់ សរុបចំនួន **៣៨៩៥៧០០០ (សាមសិបប្រាំបីលានប្រាំបួនរយហាសិបប្រាំពីរពាន់) រៀល** មកឱ្យយើងខ្ញុំតាមកិច្ចព្រមព្រៀង និងតារាងកំណត់បង់ប្រាក់នោះទេ ទោះបីជា យើងខ្ញុំខិតខំព្យាយាមដោះស្រាយជាមួយនិងកូនបំណុល ឈ្មោះ: យ៉ាងណាក៏ដោយ ក៏សហកូនបំណុលតែងតែគេចវេស យកលេសនេះលេសនោះ និងផ្តាច់ទំនាក់ទំនងជាមួយយើងខ្ញុំ។

IV **តាពចាំបាច់នៃការអនុញ្ញាតការពារ**

យើងខ្ញុំមានការព្រួយបារម្ភថាមិនអាចអនុវត្តសិទ្ធិលើបំណុល ឬ អាចបង្កឲ្យមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំនាពេលអនាគត ដោយសារតែ បច្ចុប្បន្ន កូនបំណុលឈ្មោះ: ជាអ្នកកាន់កាប់គ្រប់គ្រង ព្រមទាំងមានសិទ្ធិចាត់ចែងទៅលើរថយន្តម៉ាក HYUNDAI ចំនួន ០១ (មួយ)គ្រឿង ខាងលើ ទៅឲ្យតតិយជនដែលធ្វើឲ្យប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់យើងខ្ញុំ។

ហេតុដូច្នេះ យើងខ្ញុំស្នើសុំឲ្យតុលាការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននូវរថយន្តម៉ាក HYUNDAI ចំនួន ០១ គ្រឿង ខាងលើស្របតាមមាត្រា ៥៣១ និងមាត្រា៥៤៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

V **តស្តុតាងបញ្ជាក់អំពីការទាមទារ**

- កិច្ចព្រមព្រៀងទទួលខុសត្រូវទូទាត់បង់ប្រាក់ដោយស្ម័គ្រចិត្ត ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២។
- តារាងសម្រាប់ការបង់ប្រាក់ៈ (ប្រគល់ទទួលប្រាក់រៀល) ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២២។
-កាតគ្រឹះថយន្តម៉ាក HYUNDAI ពណ៌ខៀវ ពាក់ផ្លាកលេខ ៖ ៤ សីរីឆ្នាំ ។

អាស្រ័យដូចបានជម្រាបជូន យើងខ្ញុំសូមសំណូមពរ **ឯកឧត្តមប្រធាន** មេត្តាចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននូវរថយន្តម៉ាក HYUNDAI ចំនួន ០១ គ្រឿង ខាងលើ តាមការស្នើសុំរបស់យើងខ្ញុំ ដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីយើងខ្ញុំ។

ថ្ងៃ[illegible]...[illegible]. ខែ[illegible]ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ខេត្តកំពង់ចាម, ថ្ងៃទី[illegible]... ខែ[illegible]ឆ្នាំ២០២៤

ស្នាមមេដៃស្តាំ

រួមជូនភ្ជាប់នូវឯកសារថតចម្លង៖

- កិច្ចព្រមព្រៀងទទួលខុសត្រូវទូទាត់បង់ប្រាក់ដោយស្ម័គ្រចិត្ត ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២។
- តារាងសម្រាប់ការបង់ប្រាក់ៈ (ប្រគល់ទទួលប្រាក់រៀល) ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២២។
-កាតគ្រឹះថយន្តម៉ាក HYUNDAI ពណ៌ខៀវ ពាក់ផ្លាកលេខ[illegible]។

ឧបសម្ព័ន្ធទី២

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខាធិការដ្ឋានផ្តល់ប្រយោជន៍
សាលាដំបូងខេត្តកំពង់ចាម
ចូលថ្ងៃ ... ខែ ... ឆ្នាំ ...
ម៉ោង ... នាទី ...
បញ្ជូនទៅ ...

ក្រុមមេធាវី អេច ប៊ី អ៊ រ និង សហការី
HBR AND ASSOCIATES LAW GROUP
លេខ.. ...HBR/ .

លិខិតតំណាងដោយអាណត្តិ

ខ្ញុំបាទមេធាវី **ហេង ប៊ុន៉ា** អត្តលេខ៖ ២០២១ ជាប្រធានក្រុមមេធាវី **អេច ប៊ី អ៊ រ និង សហការី (HBR AND ASSOCIATES LAW GROUP)** ដែលមានទីស្នាក់ការស្ថិតនៅផ្ទះ៤59 បុរីរុងរឿង ភូមិគៀនឃ្លាំង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

លេខាធិការដ្ឋានផ្តល់ប្រយោជន៍
សាលាដំបូងខេត្តកំពង់ចាម
ចេញនៅថ្ងៃទី ... /
បង្កាន់ដៃលេខ៖ ...
ចូលថ្ងៃទី...ខែ ...ឆ្នាំ

ខ្ញុំសូមទំនាក់ទំនងលេខ: ០៨៩ ៩៩៩ ០៤។

សូមគោរពជូនមក

ឯកឧត្តមប្រធានសាលាដំបូងខេត្តកំពង់ចាម

កម្មវត្ថុ: ស្តីពីការតំណាងដោយអាណត្តិឲ្យឈ្មោះ និងឈ្មោះ .: ក្នុងសំណុំរឿងក្សេការពារលេខ៖.. . ចុះថ្ងៃទី. ..ខែ.. ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តកំពង់ចាម។

យោង: - មាត្រា២ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។

- មាត្រា៥២ មាត្រា៥៣ និងមាត្រា៥៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា: ឈ្មោះ ,និងឈ្មោះ .បានប្រគល់សិទ្ធិឲ្យខ្ញុំបាទ ធ្វើជាមេធាវីតំណាងដោយអាណត្តិ នៅក្នុងសំណុំរឿងក្សេការពារដូចមានឆ្លងក្នុងកម្មវត្ថុខាងលើ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមប្រធាន** មេត្តាជ្រាបដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលយកនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំបាទ។

ថ្ងៃ...ទី...ខែ...ឆ្នាំ... ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

ខេត្តកំពង់ចាម ថ្ងៃទី..ខែ..ឆ្នាំ២០២៤

មេធាវី និង ត្រា

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

មេធាវី ហេង ប៊ុន៉ា

ឧបសម្ព័ន្ធទី៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ

យើងខ្ញុំឈ្មោះ ... ភេទ ... អាយុ ... ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណ ប័ណ្ណ លេខ: ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... និងឈ្មោះ ... ភេទ ... អាយុ ... ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ: ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... មានអាសយដ្ឋាននៅភូមិ ... សង្កាត់ ... ក្រុង ... ខេត្ត ... ។

សូមធ្វើការប្រគល់សិទ្ធិជូន

លោកមេធាវី **ហោច ប៊ូរ៉ា** អត្តលេខ: ២០២១ ជា**ប្រធានក្រុមមេធាវី អេច ប៊ី អ និង សហការី** (HBR AND ASSOCIATES LAW GROUP) ដែលមានទីស្នាក់ការស្ថិតនៅផ្ទះE59 បុរីរុងរឿង ភូមិគៀនឃ្លាំង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ដើម្បីធ្វើជាអ្នកតំណាងដោយអាណត្តិឲ្យ ខ្ញុំបាទ នៅក្នុងសំណុំរឿងរក្សាការពារលេខ: ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តកំពង់ចាម។

ចាប់ពីថ្ងៃផ្តិតមេដៃនេះតទៅ លោក **ហោច ប៊ូរ៉ា** នឹងមានសិទ្ធិតំណាងដោយអាណត្តិឲ្យអាណត្តិទាយក និងមានសិទ្ធិអំណាចពេញលេញក្នុងការធ្វើរាល់សកម្មភាពដូចតទៅ:

១.ការដាក់ពាក្យបណ្តឹង ការដកពាក្យបណ្តឹង ការផ្សះផ្សា ការចចារ សម្របសម្រួល ការលះបង់ការទាមទារ ឬការទទួលស្គាល់ការទាមទារ ការផ្លាស់ប្តូរសារចំពោះបណ្តឹង ការចូលរួមអត្ថាគមន៍បណ្តឹង។

២.ការដាក់ពាក្យបណ្តឹងតប ការប្តឹងតវ៉ា បណ្តឹងទាស់ បណ្តឹងឧទ្ធរណ៍ បណ្តឹងជំទាស់ បណ្តឹងសាទុក្ខ។

៣.ការចាត់ចែងរក្សាការពារ ការអនុវត្តដោយបង្ខំ ការជ្រើសតាំងអនុតំណាង។

៤.មានសិទ្ធិបញ្ជាក់សាលក្រម ឬសាលដីកាស្តាពរ ថតចម្លងសាលក្រម ឬសាលដីកានិងរូបមន្តអនុវត្ត។

៥.ដាក់ពាក្យសុំប្រកាសផ្សាយជាសាធារណៈ និងធ្វើសេចក្តីបញ្ជាក់ជំបូង។

៦.ដាក់សេចក្តីថ្លែងការណ៍ និងលិខិតបញ្ជាក់មូលហេតុនៃបណ្តឹងសាទុក្ខ។

៧.ធ្វើគ្រប់សកម្មភាពចាំបាច់សម្រាប់ការការពារក្តី ដោយគោរពផលប្រយោជន៍ស្របច្បាប់និងមានសិទ្ធិដោះស្រាយបញ្ហាជាមួយអាជ្ញាធរ និងតុលាការគ្រប់ជាន់ថ្នាក់។

បញ្ជាក់៖ សេហ៊ុយចំណាយលើការបង់ពន្ធផ្សេងៗ នៅក្នុងសំណុំរឿងនេះ គឺជាបន្ទុករបស់យើងខ្ញុំជាអាណត្តិទាយក។ ក្នុងករណីមិនគោរពតាមកាតព្វកិច្ចនេះ យើងខ្ញុំសុខចិត្តទទួលខុសត្រូវនៃវាល់ការបាត់បង់ផលប្រយោជន៍នានាដោយផ្ទាល់។

ថ្ងៃ ... ខែ ... ឆ្នាំរោង ឆស័ក ព.ស២៥៦៨
ខេត្តកំពង់ចាម, ថ្ងៃទី ... ខែ ... ឆ្នាំ២០២៤

ស្នាមមេដៃស្តាំអាណត្តិទាយក

បានឃើញ និងយល់ព្រម
ធ្វើជាមេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ:
និងឈ្មោះ: តាមនីតិវិធីច្បាប់។
ថ្ងៃ ... ខែ ... ឆ្នាំរោង ឆស័ក ព.ស២៥៦៨
ខេត្តកំពង់ចាម, ថ្ងៃទី ... ខែ ... ឆ្នាំ២០២៤

ឯកឧត្តម និងត្រា

ព្រះរាជាណាចក្រកម្ពុជា
មេធាវី
AVOCAT
ATTORNEY AT LAW
KINGDOM OF CAMBODIA

មេធាវី ហោច-ប៊ូរ៉ា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មេធាវី អេច ប៊ី អ៊ ន៊ិង សហការី
ND ASSOCIATES LAW GROUP
.....HBR/

លេខាធិការដ្ឋានទទួលបាន
សាលាដំបូងខេត្តកំពង់ចាម
ថ្ងៃទី
ម៉ោង
បញ្ជូនមក.....

ពាក្យស្នើសុំពិនិត្យ និងថតចម្លងសំណុំរឿង

ខ្ញុំបាទមេធាវី **ហេង ប៊ុន៉ា** អត្តលេខ៖ ២០២១ ជា**ប្រធានក្រុមមេធាវី អេច ប៊ី អ៊ ន៊ិង សហការី** (HBR AND ASSOCIATES LAW GROUP) ដែលមានទីស្នាក់ការស្ថិតនៅផ្ទះE59 បុរីរុងរឿង ភូមិគៀនឃ្លាំង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

ចូរសំឡងទំនាក់ទំនងលេខ: ០៨៩ ៩៩៩៩ ០៤។

លេខាធិការដ្ឋានទទួលបាន
សាលាដំបូងខេត្ត កំពង់ចាម
បង្កាន់ដៃលេខ:
ចុះថ្ងៃទី.. ....ខែ..... ឆ្នាំ

សូមគោរពជូនមក
ឯកឧត្តមប្រធានសាលាដំបូងខេត្តកំពង់ចាម

កម្មវត្ថុ: ស្នើសុំពិនិត្យ និងថតចម្លងសំណុំរឿងក្សោកាពោរលេខ:.... .ចុះថ្ងៃទី. .ខែ ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តកំពង់ចាម។

យោង: - មាត្រា២៥៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមការអនុញ្ញាតអំពី **ឯកឧត្តមប្រធាន** ធ្វើការពិនិត្យ និងថតចម្លងសំណុំរឿងដូចបានជម្រាបជូនខាងលើ ដើម្បីឲ្យខ្ញុំបាទមានលទ្ធភាពបានសិក្សាស្រាវជ្រាវ ការពារផលប្រយោជន៍ស្របច្បាប់ឲ្យកូនក្តីខ្ញុំបាទ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាអនុញ្ញាតតាមការស្នើសុំ ដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំបាទ។

ថ្ងៃសុក្រ ១២កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
ខេត្តកំពង់ចាម ថ្ងៃទី..៣..ខែមិថុនា ឆ្នាំ២០២៤

ជាកិត្តិយស និង ក្រា

ព្រះរាជាណាចក្រកម្ពុជា
មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

មេធាវី ហេង ប៊ុន៉ា

ផ្ទះលេខE59 បុរីរុងរឿង ភូមិគៀនឃ្លាំង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ
ss: #E59, Borey Rong Roeung, Phum KienKhlang, Sangkat PrekLeap, Khan ChroyChangva, Phnom Penh, Cambodia.
· ០៨៩ ៩៩៩៩ ០៤ / ០៩១ ៨៨៨៨ ៤៩ www.Facebook.com/HBRLawyergroup Email: HBRLawyergroup@gmail.com

ឧបសម្ព័ន្ធទី៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខាធិការដ្ឋានខេត្ត...
សាលាដំបូងខេត្តកំពង់ចាម
ចូលថ្ងៃទី... ខែ... ឆ្នាំ...
លេខ... ឈ្មោះ...
បញ្ជូនទៅ...

មេធាវី អេច ប៊ី អ និង សហការី
AND ASSOCIATES LAW GROUP
....HBR....

លេខាធិការដ្ឋានដ្ឋានប្តឹងសាលាដំបូងខេត្តកំពង់ចាម
បង្កាន់ដៃលេខ:...
ចុះថ្ងៃទី... ខែ... ឆ្នាំ...

ពាក្យស្នើសុំឲ្យពិនិត្យកសុតាង

ខ្ញុំបាទមេធាវី **ហេង ប៊ុន្ន** អត្តលេខ: ២០២១ ជាប្រធានក្រុមមេធាវី **អេច ប៊ី អ និង សហការី** (HBR AND ASSOCIATES LAW GROUP) មានការិយាល័យទីតាំងស្ថិតនៅផ្ទះE59 បុរីរុងរឿង ភូមិគៀនឃ្លាំង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

សូមគោរពជូនមក

ឯកឧត្តមប្រធានសាលាដំបូងខេត្តកំពង់ចាម

កម្មវត្ថុ: ស្នើសុំឲ្យពិនិត្យកសុតាងក្នុងសំណុំរឿងក្បែការពារលេខ: ចុះថ្ងៃទី ខែ ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តកំពង់ចាម។

យោង: - សំណុំរឿងក្បែការពារលេខ: ចុះថ្ងៃទី ខែ ឆ្នាំ២០២៤របស់សាលាដំបូងខេត្តកំពង់ចាម។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា: នៅក្នុងសំណុំរឿងក្បែការពារលេខ: ចុះថ្ងៃទី ខែ ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តកំពង់ចាម កូនក្តីខ្ញុំឈ្មោះ: និងឈ្មោះ: សូមជាក់កសុតាង ជូនតុលាការពិនិត្យដូចខាងក្រោម:

+ កសុតាងជាឯកសារ:

- កិច្ចព្រមព្រៀងទទួលខុសត្រូវខូទាត់បង់ប្រាក់ដោយស្មគ្រចិត្ត របស់ ឈ្មោះ: និងឈ្មោះ: ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២។
- តារាងសម្រាប់កំណត់ការបង់ប្រាក់: ប្រគល់-ទទួលប្រាក់បៀល ៣៣,១២៦,០០០,0 (សាមសិបបីលាន មួយម្តែប្រាំមួយពាន់) បៀល ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២២។
- កាតក្រឹ របស់ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១។

អាស្រ័យដូចបានជម្រាបខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាទទួលយកនូវកសុតាង ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលយកនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំបាទ។

ថ្ងៃ...ទី...ខែ...ឆ្នាំ...ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី...ខែ...ឆ្នាំ២០២៤

មេធាវីការពារក្តី

ព្រះរាជាណាចក្រកម្ពុជា
មេធាវី
AVOCAT
ATTORNEY AT LAW
KINGDOM OF CAMBODIA

មេធាវី ហេង ប៊ុន្ន

ឧបសម្ព័ន្ធទី៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខាធិការដ្ឋានផ្ទួនផ្ទាល
សាលាដំបូងខេត្តកំពង់ចាម
ថ្ងៃទី ... ខែ ... ឆ្នាំ ...
ម៉ោង ...
បញ្ជូនទៅ ...

លេខាធិការដ្ឋានផ្ទួនផ្ទាល
សាលាដំបូងខេត្ត កំពង់ចាម
បង្គាន់ដៃពេ
ចុះថ្ងៃទី ...

មធាវី អេច ប៊ី អ និង សហការី
HBR AND ASSOCIATES LAW GROUP
....HBR/...

សេចក្តីបញ្ជាក់ដំបូង

ខ្ញុំបាទមេធាវី **ហោច ចូរ៉ា** អត្តលេខ ២០២១ ជា **ប្រធានក្រុមមេធាវី អេច ប៊ី អ និង សហការី (HBR AND ASSOCIATES LAW GROUP)** ដែលមានទីស្នាក់ការស្ថិតនៅផ្ទះលេខE59 បុរីរុងរឿង ភូមិគៀនឃ្លាំង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

ទូរស័ព្ទទំនាក់ទំនងលេខ: ០៨៩ ៩៩៩៩ ០៥/០១០ ៥៥៥៥ ៨៩។

សូមគោរពជូន

ឯកឧត្តមប្រធានសាលាដំបូងខេត្តកំពង់ចាម

អង្គន្តុះ សូមជូនសេចក្តីបញ្ជាក់ដំបូងនៅក្នុងសំណុំរឿងរក្សាការពារលេខ: ... ចុះថ្ងៃ ... ខែ ... ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តកំពង់ចាម។

យោង: សំណុំរឿងរក្សាការពារលេខ: ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តកំពង់ចាម។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា៖ កាលពីអំឡុងឆ្នាំ២០២១ រហូតដល់ ឆ្នាំ២០២២ កូនបំណុលឈ្មោះ: ... បានជំពាក់ប្រាក់យើងខ្ញុំថ្លៃទិញត្រីចំនួន **៣៣១២៦០០០ (សាមសិបបីលានមួយរយដប់ម្ភៃប្រាំមួយពាន់) រៀល** ដូចមាននៅក្នុងកិច្ចព្រមព្រៀងទទួលខុសត្រូវខុទាត់បង់ប្រាក់ដោយស្មគ្រចិត្តចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២។ កូនបំណុលឈ្មោះ ... បានសងប្រាក់ថ្លៃទិញត្រីយើងខ្ញុំចំនួន **២៤០០០០០ (ម្ភៃបួនលាន) រៀល** និងនៅសល់ប្រាក់ជំពាក់ចំនួន **១០០០០០ (ដប់លាន)រៀល** ដូចមានក្នុងលិខិត-ប្រគល់ប្រាក់ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២២។

លុះអំឡុងឆ្នាំ២០២៣ កូនបំណុលបានបន្តទិញត្រី និងជំពាក់ប្រាក់យើងខ្ញុំ ចំនួន **២៨៩៥៧០០០ (ម្ភៃប្រាំបីលានប្រាំបួនរយហាសិបប្រាំពីរពាន់) រៀល**។

ចាប់តាំងពីឆ្នាំ២០២១ រហូតដល់ ឆ្នាំ២០២៣ កូនបំណុលបានជំពាក់ប្រាក់ថ្លៃទិញត្រីទាំងប្តី និងចាស់សរុបចំនួន **៣៨៩៥៧០០០ (សាមសិបប្រាំបីលានប្រាំបួនរយហាសិបប្រាំពីរពាន់)** ដូចមាននៅក្នុងតារាងបង់ប្រាក់។

បច្ចុប្បន្ន កូនបំណុលឈ្មោះ ... ពុំបានអនុវត្តកាតព្វកិច្ចសងប្រាក់ សរុបចំនួន **៣៨៩៥៧០០០ (សាមសិបប្រាំបីលានប្រាំបួនរយហាសិបប្រាំពីរពាន់) រៀល** មកឱ្យយើងខ្ញុំតាមកិច្ចព្រមព្រៀង និងតារាងកំណត់បង់ប្រាក់នោះទេ ទោះបីជា យើងខ្ញុំខិតខំព្យាយាមជោះស្រាយជាមួយនិងកូនបំណុល ឈ្មោះ ... យ៉ាងណាក៏ដោយ ក៏កូនបំណុលតែងតែគេចវេស យកលេសនេះលេសនោះ និងផ្តាច់ទំនាក់ទំនងជាមួយយើងខ្ញុំ។

យោងតាមមាត្រា៥៣១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ បានបញ្ញត្តថា ការបែអូសជាបណ្តោះអាសន្ន គឺជាការចាត់ចែងដែលកម្រិតនូវការចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បីរក្សាការពារការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់។

មាត្រា៥៤៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ បានចែងថា ដីកាសម្រេចបើអូសជាបណ្តោះអាសន្ន អាចចេញបានចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ ក្នុងករណីដែលបារម្ភថាការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ។

ជាការពិតណាស់ ការបំពានកាតព្វកិច្ចរបស់កូនបំណុលឈ្មោះ បានធ្វើឱ្យកូនក្តីខ្ញុំជាម្ចាស់បំណុលទទួលរងនូវការខាតបង់ប្រាក់អស់ចំនួន **៣៨៥៧០០០ (សាមសិបប្រាំបីលានប្រាំបួនរយហាសិបប្រាំពីរពាន់) រៀល** កូនក្តីខ្ញុំជាម្ចាស់បំណុល មានការព្រួយបារម្ភថាមិនអាចអនុវត្តសិទ្ធិលើបំណុល ឬ អាចបង្កឱ្យមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំនាពេលអនាគត ដោយសារតែបច្ចុប្បន្ន កូនបំណុលឈ្មោះ

ជាអ្នកកាន់កាប់ គ្រប់គ្រង ព្រមទាំងមានសិទ្ធិចាត់ចែងទៅលើរថយន្តម៉ាក HYUNDAI ចំនួន ០១ (មួយ) គ្រឿង ខាងលើ ទៅឲ្យតតិយជនដែលធ្វើឲ្យប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់យើងខ្ញុំ។

ហេតុដូច្នេះយើងខ្ញុំស្នើសុំឲ្យតុលាការចេញដីកាសម្រេចបើអូសជាបណ្តោះអាសន្ននូវរថយន្តម៉ាក HYUNDAI ចំនួន ០១ គ្រឿង ខាងលើស្របតាមមាត្រា ៥៣១ និងមាត្រា៥៤៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាទទួលយកនូវសេចក្តីបញ្ជាក់ជំបុង និងចេញដីកាសម្រេចបើអូសជាបណ្តោះអាសន្ននូវរថយន្តម៉ាក HYUNDAI ចំនួន ០១ (មួយ)គ្រឿង ខាងលើ ស្របតាមស្មារតីនៃមាត្រា៥៤៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ តាមការស្នើសុំរបស់កូនក្តីខ្ញុំ ដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំបាទ។

ថ្ងៃ.....ខែ.....ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

ខេត្តត្បូងឃ្មុំ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៤

មេធាវី ឆាន ស្រីនិច

មេធាវី ឆេង-ឃួរ៉ា

ឧបសម្ព័ន្ធទី៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សៀវភៅជីងក្សាការពារលេខ
ចុះថ្ងៃទី ខែ ឆ្នាំ២០២៤
លិខិតសម្រេចលេខ
ចុះថ្ងៃទី ខែ ឆ្នាំ២០២៤

លិខិតសម្រេចរឹបអូសជាបណ្តោះអាសន្ន

យើង ទៅក្រុមសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញ មាត្រា ៥៤៥ មាត្រា ៥៤៧ និងមាត្រាពាក់ព័ន្ធ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០៦/០២០ ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៧
- បានឃើញ ពាក្យសុំលិខិតសម្រេចរក្សាការពារ ចុះថ្ងៃទី ខែ ឆ្នាំ
- បានឃើញ សំណុំរឿងរក្សាការពារលេខ ចុះថ្ងៃទី ខែ ឆ្នាំ ដែលមាន៖

ម្ចាស់ចំណុល

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានអាសយដ្ឋានស្ថិតនៅអាគារលេខ៣ មហាវិថីសហព័ន្ធរុស្សី សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

អ្នកតំណាងដោយអំណាច

ឯកឧត្តមអគ្គបណ្ឌិត និងឯកឧត្តមអគ្គបណ្ឌិត និងឯកឧត្តមអគ្គបណ្ឌិត ជាមេធាវីនៃ ការិយាល័យមេធាវី មានអាសយដ្ឋានស្ថិតនៅ ផ្លូវ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

សហចូនចំណុល

ខ-ក្រុមហ៊ុន & ( ) សហគ្រាសមានអាសយដ្ឋានស្ថិតនៅ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ចុះបញ្ជីពាណិជ្ជកម្មលេខ ចុះថ្ងៃទី ខែ ឆ្នាំ មានម្ចាស់សហគ្រាសឈ្មោះ អាយុ ។

ឃ-ឈ្មោះ អាយុ អត្តសញ្ញាណប័ណ្ណកម្ពុជាលេខ ចុះថ្ងៃទី ខែ ឆ្នាំ មានអាសយដ្ឋានស្ថិតនៅផ្ទះ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

ដីកាសារដែលគាំពារដោយមាត្រារបស់ម្ចាស់ចំណុល

សូមសុំឱ្យតុលាការចេញដីកាសម្រេចរក្សាការពារ៖

ក-រឹបអូសជាបណ្តោះអាសន្នទ្រព្យសម្បត្តិ និងសម្ភារៈទាំងអស់ដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុន មានទីតាំងស្ថិតនៅផ្ទះ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

ខ-រឹបអូសជាបណ្តោះអាសន្នទូរភាគហ៊ុនរបស់ក្រុមហ៊ុន ស្ថិតក្នុងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មលេខ ចុះថ្ងៃទី ខែ ឆ្នាំ ចេញដោយក្រសួងពាណិជ្ជកម្ម។

គ-បង្គាប់ឲ្យក្រុមប៉ាណូលាថ្លឹប្រាក់តម្កល់នៅតុលាការចំនួន ៣.២៩៥.២៩៥,៩៣ (បីលានម្ភៃប្រាំបួនម៉ឺន ប្រាំ ពាន់ពីរយកៅសិបប្រាំ និងកៅសិបបីសេន) ដុល្លារអាមេរិក ជាប្រាក់រំដោះ ដើម្បីទទួលបានការលុបបាត់លាការ រឹបអូសបណ្តោះអាសន្ន។

ឃ- ដីកាសម្រេចរក្សាការពារមានអានុភាពអនុវត្តភ្លាម។

មូលហេតុនៃការស៊ើបដីកាសម្រេចអង្កេតការពារ

កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៤ ក្រុមហ៊ុន

. មានកម្មការនិយោជិតសរុប ៤.៨៤៩ នាក់ ដែលមានម្ចាស់សហគ្រាសឈ្មោះ

អាទ ។ ជនជាតិ . រត់ចោលមិនទទួលខុសត្រូវបើកប្រាក់ខែ និងប្រាក់អត្ថប្រយោជន៍ផ្សេងៗ។ បន្ទាប់ពី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចាត់តាំងក្រុមអធិការកិច្ចការងារចុះសម្របសម្រួល និងបាន ដោះស្រាយករណីក្រុមហ៊ុនម្ចាស់រត់ចោលខាងលើ តាមរបាយការណ៍ស្តីពីអធិការកិច្ចការងារពិសេសចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ២០២៤ និងតាមកំណត់ហេតុស្តីពីអធិការកិច្ចការងារពិសេស ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ ប្រមទាំងចេញលិខិតណាត់កំហិតឈប ---- ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ ទើប ក្រុមហ៊ុន បើកប្រាក់ខែ និងប្រាក់អត្ថប្រយោជន៍ផ្សេងៗក្នុងខែកុម្ភៈ ឆ្នាំ២០២៤ ឲ្យទៅកម្មការនិយោជិតគ្រប់ចំនួន។

លុះដល់ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២៤ កម្មការនិយោជិតនៃក្រុមហ៊ុន

បានទាំគ្នាធ្វើ ក្បួនកម្មដៅបិទផ្លូវមុខអាងចក្រលើផ្លូវលេខ២០៧ និងបែមកដល់ចំណុចស្ពានព្រែកព្រៃក្នុងសង្កាត់ ស្ពានថ្ម ខណ្ឌដង្កោ រាជធានីភ្នំពេញ ក្នុងគោលបំណងដើម្បីទាមទារឲ្យក្រុមហ៊ុន

បើកប្រាក់ខែ និងប្រាក់អត្ថប្រយោជន៍ផ្សេងៗ ក្នុងខែមីនា ឆ្នាំ២០២៤ ដោយសារហួសថ្ងៃកំណត់បើកប្រាក់ខែ។

ក្នុងករណីម្ចាស់សហគ្រាសរត់ចោលមិនទទួលខុសត្រូវបើកប្រាក់ខែ និងប្រាក់អត្ថប្រយោជន៍ផ្សេងៗ កម្មការនិយោជិតនៃក្រុមហ៊ុន តាមច្បាប់ស្តីពីការងារអ្នកជា៖ ១-ប្រាក់ឈ្នួលឃើញចំ ២ ខែខែកុម្ភៈ ឆ្នាំ២០២៤ ជាប្រាក់ឈ្នួលមិនទាន់បានបើក (មាត្រា១១៦), ២-ប្រាក់បំណាច់ជួសការឈប់សម្រាកប្រចាំឆ្នាំចំនួន ១៨ថ្ងៃ (មាត្រា១៦៦ និងមាត្រា១៦៧), ៣-ប្រាក់ជួសការជូនដំណឹងមុនពី ៧ ថ្ងៃ ដល់ ៣ខែ (មាត្រា៧៥), ៤-ប្រាក់បំណាច់អតីតភាពការងារក្នុងឆមាសទី១ ឆ្នាំ២០២៤ (មាត្រា៨៩ថ្មី) គណនាសរុបចឹកប្រាក់ចំនួន ៣.២៩៥.២៩៥,៩៣ (បីលានម្ភៃប្រាំបួនម៉ឺន ប្រាំ ពាន់ពីរយកៅសិបប្រាំ និងកៅសិបបីសេន) ដុល្លារអាមេរិក ។

ក្នុងការដោះស្រាយជៀសវាងបង្កឲ្យមានបញ្ហាធ្ងន់ធ្ងរ និងអនុលោមតាមបញ្ញត្តិមាត្រា ១១៧ នៃច្បាប់ស្តីពីការងារ, អនុក្រឹត្យលេខ ៤៨៩ អនក្រ.បក ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៣ ស្តីពីការកែសម្រួលគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាក្នុងកម្មការតាមគ្រប់មុខសញ្ញាបានបង្កើតអត្ថិភាពនៃសិទ្ធិទាមទារ និងចំនាក់ចំនងគតិយុត្តិនៃការទទួលខុសត្រូវរបស់សហក្នុនចំណុលដែលមានភាពកិច្ចបើកផ្តល់ប្រាក់ឈ្នួល និងប្រាក់អត្ថប្រយោជន៍ផ្សេងៗជូនកម្មការនិយោជិតនៃក្រុមហ៊ុន ដែលជាម្ចាស់បំណុលអាទិភាព។

មូលហេតុចាំបាច់ដើម្បីបញ្ជាក់ការចោទប្រកាន់

មូលហេតុដែលម្ចាស់បំណុលបានដាក់ពាក្យសុំដីកាសម្រេចរក្សាការពារ ដោយមូលហេតុថា ដើម្បីធានាសម្រាប់ការបើកប្រាក់ឈ្នួល និងប្រាក់អត្ថប្រយោជន៍ផ្សេងៗជូនដល់កម្មការនិយោជិតនៃក្រុមហ៊ុន

ដែលជាម្ចាស់បំណុលអាទិភាព ម្ចាស់បំណុលមានសិទ្ធិស្នើសុំចាត់ការរក្សាការពារ រឹបអូសជាបណ្តោះអាសន្ន និងបង្កកទ្រព្យសម្បត្តិរបស់សហក្នុនចំណុល និងអាចកាត់ឥទ្ធិពលដែលជាឧបសគ្គក្នុងការប្រើសិទ្ធិភាព

ខ្ពស់។ ដោយសារម្ចាស់បំណុលមានការបារម្ភថា សហកូនបំណុលអាចនឹងកាន់កាប់ទ្រព្យសម្បត្តិ និងទ្រព្យសម្បត្តិទាំងអស់ដែលមាននៅក្នុងក្រុមហ៊ុនចេញក្រៅអស់ និងការពារកុំឲ្យមានការខ្ចោចខាតយ៉ាងធ្ងន់ធ្ងរនៅពេលក្រុមហ៊ុនកំពុងជាប់ស្ថានភាពជាក់ស្តែងដែលកំពុងកើតឡើងលើទីតាំងអាជីវកម្ម ជាពិសេសដោយស្ថានភាពគ្រប់គ្រង សុវត្ថិភាព សន្តិសុខល្អ និងការការពារជៀសវាងភាពអន្តរាយដល់ទ្រព្យសម្បត្តិទាំងលើដីល្អប្រសើរ។

ដោយសារម្ចាស់បំណុលមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ដែលសម្រេចរក្សាការពារអាចចេញបានចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ ដើម្បីជាទាការពារអនុវត្តសិទ្ធិស្របច្បាប់ និងការពារផលប្រយោជន៍របស់កម្មការនិយោជិត ដែលជាម្ចាស់បំណុលអាទិភាព។ ទង្វើរបស់សហកូនបំណុលបិទទ្វារកាត់ចោលក្រុមហ៊ុនមិនទទួលទុសត្រូវកាតព្វកិច្ចរបស់ខ្លួនបានធ្វើឲ្យប៉ះពាល់ដល់សេដ្ឋកិច្ចជាតិ និងផលប្រយោជន៍របស់កម្មការនិយោជិតយ៉ាងធ្ងន់ធ្ងរជាទីបំផុត។

តម្កល់តាមដែលបញ្ជាក់ពីការចោទមាត

- លិខិតប្រគល់សិទ្ធិឃាត ចុះថ្ងៃទី ខែ... ឆ្នាំ ... របស់ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។
- រាជធានីការណ៍ស្តីពីអធិការកិច្ចការងារពីសេសចុះថ្ងៃទី ... ខែ ... ឆ្នាំ ... របស់អធិការកិច្ចការងារ។
- កំណត់ហេតុស្តីពីអធិការកិច្ចការងារពីសេសចុះថ្ងៃទី ... ខែ ... ឆ្នាំ ... របស់អធិការកិច្ចការងារ។
- លិខិតជាក់កំហិតឃាត ក្រមទី ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... របស់អធិការកិច្ចការងារ។
- ពាក្យបណ្តឹងឃាត ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... របស់សហភាពមរតកជាតិកម្ពុជា។
- កំណត់ហេតុស្តីពីការសាកសួរព័ត៌មានក្រុមហ៊ុន ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... ។
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មឃាត ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... ចេញដោយក្រសួងពាណិជ្ជកម្ម។
- បញ្ជីឈ្មោះភាគទុនឆ្នាំ២០២១ ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... របស់អគ្គនាយកដ្ឋានពន្ធដារ។
- លិខិតបង្ហាញដែន ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... របស់ឃ្លាះ ... ។
- សេចក្តីបញ្ជាក់ដំបូងចុះថ្ងៃទី ... ខែ ... ឆ្នាំ២០២៤។

សំអាងហេតុ

១-ពាក្យសុំដីកាសម្រេចរក្សាការពារចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ របស់ឈ្មោះ ... ឈ្មោះមេធាវី ... និងឈ្មោះមេធាវី ... ជាអ្នកតំណាងដោយអាណត្តិឱ្យ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ផ្ញើមកតុលាការក្រែមក្រវែតាមច្បាប់តាមមាត្រា ៥៣១ មាត្រា ៥៣១ មាត្រា ៥៣២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២-ឈ្មោះមេធាវី ... ជាអ្នកតំណាងដោយអាណត្តិឱ្យម្ចាស់បំណុល ... បានធ្វើសេចក្តីបញ្ជាក់ដំបូងដូចខាងក្រោម៖

ក-សិទ្ធិ ឬចំណាត់ចំនងអតិយុត្តដែលត្រូវរក្សាការពារ

ម្ចាស់បំណុល និងសហកូនបំណុល មានចំណងទំនាក់ទំនងទៅនឹងការមិនអនុវត្តកាតព្វកិច្ចឬក៏ឥណទានមានសិទ្ធិលើបំណុល ដែលសហកូនបំណុលបានត់ចោលមិនទាន់បានទូទាត់ទៅក្រៅកម្ចីឱ្យក្រុមការងិយោជិក ... និងចំណាត់ចំនងអតិយុត្ត ដែលត្រូវរក្សាការពារ ដូចខាងក្រោម៖

- សហភ្នាន់ចំណុលទាំងពីរ: ក្រុមហ៊ុន ...)
សហគ្រាសមានអាសយដ្ឋានៅផ្ទះលេខ៧ ភូមិព្រែកព្រៃ សង្កាត់ស្ពានថ្ម ខណ្ឌដង្កោ រាជធានីភ្នំពេញ ចុះបញ្ជីពាណិជ្ជកម្ម លេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... មានម្ចាស់សហគ្រាសឈ្មោះ ... (អាទ ...) ។ កាលពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចាត់តាំងក្រុមអធិការកិច្ចការងារចុះសម្របសម្រួល និង ដោះស្រាយករណីក្រុមហ៊ុនម្ចាស់រត់ចោលខាងលើ តាមរបាយការណ៍ស្តីពីអធិការកិច្ចការងារពិសេស ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ និងតាមកំណត់ហេតុស្តីពីអធិការកិច្ចការងារពិសេស ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ ព្រមទាំងចេញលិខិតដាក់កំហិតលេខ ០២០ ក.ប/រក/អធក/ ក្រុមទី ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ ទើប ក្រុមហ៊ុន ... បើកប្រាក់ខែ និងប្រាក់អត្ថប្រយោជន៍ផ្សេងៗក្នុងខែកុម្ភៈ ឆ្នាំ២០២៤ ឲ្យទៅកម្មការនិយោជិតត្រប់ចំនួន។ ដោយហេតុនេះហើយទើបានបង្កើតឲ្យមានទំនាក់ទំនងគតិយុត្តិម្ចាស់ចំណុល និងសហភ្នាន់ចំណុល។
- អត្ថិភាពនៃសិទ្ធិក្នុងការទាមទារ ក្នុងការដោះស្រាយជៀសវាងបង្កឲ្យមានបញ្ហាច្រឡំច្រវ និងអនុលោមតាមបញ្ញត្តិមាត្រា ១០៧ នៃច្បាប់ស្តីពីការងារ, អនុក្រឹត្យលេខ ៤៨៩ អនក្រ.បក ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៣ ស្តីពីការកែសម្រួលគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាភ្នាក់ងារបញ្ជាការតាមក្រប់មុខសញ្ញា បានបង្កើតអត្ថិភាពនៃសិទ្ធិទាមទារ និងទំនាក់ទំនងគតិយុត្តិនៃការទទួលខុសត្រូវរបស់សហភ្នាន់ចំណុល ដែលមានភាពភ្ញាក់ផ្អើលបើកផ្តល់ប្រាក់ឈ្នួល និងប្រាក់អត្ថប្រយោជន៍ផ្សេងៗជូនកម្មការនិយោជិតនៃក្រុមហ៊ុន ... ដែលជាម្ចាស់ចំណុលអាទិភាព ទើបម្ចាស់ចំណុលដាក់ពាក្យសុំដើរតាសម្រេចរក្សាការពារទ្រឹបអូសជាបណ្តោះអាសន្នទ្រព្យសម្បត្តិសម្ភារៈ និងភាគហ៊ុនរបស់ ... ដែលមានភ្នាន់ចំណុលឈ្មោះ ... (ជាម្ចាស់ក្រុមហ៊ុន ...) ជាបណ្តោះអាសន្ន។

សេចក្តីបញ្ជាក់អំពីសិទ្ធិ និងទំនាក់ទំនងគតិយុត្តដែលត្រូវរក្សាការពារ ដែលជាមូលហេតុគតិយុត្ត នៃការទាមទារ នៅក្នុងពាក្យសុំខាងលើនោយផ្តែកលើភស្តុភាងដូចជា៖

ក-របាយការណ៍ស្តីពីអធិការកិច្ចការងារពិសេសចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ របស់អធិការកិច្ចការងារ។
ខ-កំណត់ហេតុស្តីពីអធិការកិច្ចការងារពិសេសចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ របស់អ្នកិច្ចការងារ។
ឆ-កំណត់ហេតុស្តីពីការសាកសួរព័ត៌មានក្រុមហ៊ុន ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... របស់អធិការកិច្ចការងារ។
ខ-ភាពចាំបាច់នៃការការពារ

ដោយមានការបារម្ភថា និងដើម្បីជានាសម្រាប់ការបើកប្រាក់ឈ្នួល និងប្រាក់អត្ថប្រយោជន៍ផ្សេងៗជូនកម្មការនិយោជិតនៃ ... ដែលជាម្ចាស់ចំណុលអាទិភាពពីម្ចាស់ចំណុលមានសិទ្ធិស្នើសុំចាត់ការរក្សាការពារទ្រឹបអូសជាបណ្តោះអាសន្ន និងបង្កភ្ជាប់ទ្រព្យសម្បត្តិរបស់សហភ្នាន់ចំណុល

និងភាគីពាក់ព័ន្ធដែលជាយន្តការមានប្រសិទ្ធភាពខ្ពស់។ ដោយម្ចាស់បំណុលមានការ បារម្ភថា អាចនឹងបាត់បង់ សម្ភារៈ ទំនិញ និងទ្រព្យសម្បត្តិទាំងអស់ដែលមាននៅក្នុងក្រុមហ៊ុនចេញក្រៅអស់ និងការពារកុំឲ្យមានការខូចខាតយ៉ាងធ្ងន់ធ្ងរនៅតែបន្តដែលស្ថានភាពជាក់ស្តែងដែលកំពុងកើតមានឡើងរវើរវាយទាំងអាងចក្រ ជាពិសេសដោយស្រួលគ្រប់គ្រង សុវត្ថិភាព សន្តិសុខល្អ និងការពារថៀរភាពអត្ថភាយដល់ទ្រព្យសម្បត្តិទាំងអស់ខាងលើនិល្អប្រសើរ។ ដោយសារម្ចាស់បំណុលមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ នីតិសម្បទាក្សាការពារអាចចេញបានចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ ដើម្បីធានាការពារអនុវត្តសិទ្ធិប្រមបច្បាប់ និងការពារផលប្រយោជន៍របស់កម្មការនិយោជិក ដែលជាម្ចាស់បំណុលអាទិភាព។ ទង្វើរបស់សហភ្នាក់បំណុលរត់ចោលក្រុមហ៊ុនមិនទទួលខុសត្រូវភាគច្រើនរបស់ខ្លួន បានធ្វើឲ្យប៉ះពាល់ដល់សេដ្ឋកិច្ចជាតិ និងផលប្រយោជន៍របស់កម្មការនិយោជិតយ៉ាងធ្ងន់ធ្ងរជាទីបំផុត។

អ.អន្តច្បាប់

-តាមបញ្ញត្តិមាត្រា ៥៣០ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានចែងអំពី "គោលគំនិត" ប្រសិនបើមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់ភ្នាក់បំណុលនៃការអនុវត្ត ឬ ប្រសិនបើមានការបារម្ភថា នឹងមានការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្តាន់ដល់ជានៈរបស់ភាគីណាមួយ ដោយសារមានវិវាទអំពីចំនាក់ចំនងនៃសិទ្ធិបុគ្គល ដែលមានចំណាងចង់ការពារសិទ្ធិរបស់ខ្លួនអាចទាមទារការចាត់ចែងរក្សាការពារ តាមបញ្ញត្តិនៃអត្ថន័យនេះ ឃើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ផ្សេង។

-តាមបញ្ញត្តិមាត្រា ៥៤៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានចែងអំពី "ភាពចាំបាច់នៃនីតិសម្រេចវិបអូសជាបណ្តោះអាសន្ន"

១.នីតិសម្រេចវិបអូសជាបណ្តោះអាសន្ន អាចចេញបានចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ក្នុងករណីដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ ភ្ជាប់នឹងលក្ខខ័ណ្ឌ ឬពេលកំណត់ក៏ដោយ។

២.នីតិសម្រេចវិបអូសជាបណ្តោះអាសន្នអាចចេញបាន ទោះបីជាសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ ភ្ជាប់នឹងលក្ខខ័ណ្ឌ ឬ ពេលកំណត់ក៏ដោយ។

-តាមបញ្ញត្តិមាត្រា ៥៤៧ នៃក្រមរដ្ឋប្បវេណី បានចែងអំពី "ប្រាក់រំដោះពីការវិបអូសជាបណ្តោះអាសន្ន"

ក.ក្នុងនីតិសម្រេចវិបអូសបណ្តោះអាសន្ន តុលាការត្រូវកំណត់ចំនួនទឹកប្រាក់ដែលភ្នាក់បំណុលត្រូវធ្វើដើម្បីទទួលបានផ្លែការលុបចោលការអនុវត្តការវិបអូសជាបណ្តោះអាសន្ន។

ខ.ការធ្វើប្រាក់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើ ត្រូវធ្វើឡើងនៅតុលាការដែលបានចេញនីតិសម្រេចវិបអូសជាបណ្តោះអាសន្ន ឬ តុលាការអនុវត្តការរក្សាការពារ ។

ជ-តាមសេចក្តីបញ្ជាក់និងបង្ហាញរបស់ម្ចាស់បំណុល និងអស្តីភាពជាឯកសារដើលបង្ហាញភ្ជាប់ជាមួយនឹងសំណើសុំ ឃើញថា [illegible] មានកម្មការនិយោជិតសរុប ៤.៨៤៩ នាក់ ដែលមានម្ចាស់សហគ្រាសជាអ្នក [illegible] បានរាប់បញ្ចូលមិនទទួលខុសត្រូវបើកប្រាក់ខែ និងប្រាក់អត្ថប្រយោជន៍ផ្សេងៗ ហើយម្ចាស់សហគ្រាសដែលបានរួមគ្នាមិនទទួលខុសត្រូវបើកប្រាក់ខែ និងប្រាក់អត្ថប្រយោជន៍ផ្សេងៗរបស់កម្មការនិយោជិតនៃក្រុមហ៊ុន"

តាមច្បាប់ស្តីពីការងារមានប្លង់ជា ខ-ប្រាក់ឈ្នួល រយៈពេល ២ ខែមុនឆ្នាំ ២០២៤ ជា ប្រាក់ឈ្នួលមិនទាន់បានបើក(មាត្រា១១៦), ឃ-ប្រាក់បំណាច់ផ្តល់ការឈប់សម្រាកប្រចាំឆ្នាំចំនួន ១៨ថ្ងៃ (មាត្រា ១១៦ និងមាត្រា ១១៧), ៣-ប្រាក់ផ្តល់ការជូនដំណឹងមុនពី ៧ថ្ងៃ ដល់ ៣ខែ (មាត្រា ៧៥), ៤-ប្រាក់បំណាច់ អតីតភាពការងារក្នុងរយៈពេល ឆ្នាំ ២០២៤ (មាត្រា ៧៩) គណនាសរុប ទឹកប្រាក់ចំនួន ៣.២៩៥.២៩៥,៩៣ (បីលាន ប្រាំពីរសែនប្រាំបួនម៉ឺនប្រាំពាន់ពីររយកាសិបប្រាំ និងកៅសិបបីសេន) ដុល្លារអាមេរិក។ ម្យ៉ាងទៀត ដោយសារ ម្ចាស់បំណុលមានការបារម្ភថា សហកូនបំណុលអាចនឹងកាន់កាប់ទ្រព្យសម្បត្តិ និងទ្រព្យសម្បត្តិទាំងអស់ដែល មានទៅក្នុងក្រុមហ៊ុនចេញក្រៅអស់ និងការពារកុំឱ្យមានការខូចខាតយ៉ាងធ្ងន់ធ្ងរទៅទៀតបន្ត ដែលស្ថានភាព ជាក់ស្តែងដែលកំពុងកើតមានឡើងលើទីតាំងក្រុមហ៊ុន ជាពិសេសដោយស្ថានភាពគ្រប់គ្រង សុវត្ថិភាព សង្គមសុខ និងជៀសវាងភាពអន្តរាយដល់ទ្រព្យសម្បត្តិទាំងលើក្នុងគោលបំណងសងជាប្រាក់ ដោយផ្អែកទៅលើសិទ្ធិលើ បំណុល និងដោយមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុង ការអនុវត្តដោយបង្ខំ។ ហេតុម្យ៉ាងទៀត ម្ចាស់បំណុលពិតជាមានអត្ថិភាពនៃសិទ្ធិលើបំណុលដែលមានគោលបំណង ឱ្យសងជាប្រាក់ចំពោះសហកូនបំណុល ដែលចាំបាច់ត្រូវមានការការពារ តាមបញ្ញត្តិមាត្រា ៥៣០ នៃក្រម នីតិវិធីរដ្ឋប្បវេណី។

៤-តាមពាក្យសុំនីតិសាស្ត្របណ្តោះអាសន្នចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ២០២៤ ដែលមានកម្មវត្ថុស្នើសុំឱ្យរឹបអូសទ្រព្យ ទ្រព្យសម្បត្តិទាំងអស់ដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុន ... និងភាគហ៊ុនរបស់ក្រុមហ៊ុន ជាបណ្តោះអាសន្នដោះ គឺមានមូលហេតុចាំបាច់ស្របតាមបញ្ញត្តិមាត្រា ៥៤៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ អ្នកឆ្លើយដើម្បីការពារផល ប្រយោជន៍រួមរបស់ភាគីនៃក្រុមហ៊ុន ដែលជា ម្ចាស់បំណុលអាទិភាព និងកុំឱ្យប្រែប្រួលទ្រព្យសកម្មនៃទ្រព្យសម្បត្តិទាំងអស់ដែលមានក្នុងក្រុមហ៊ុន និង ភាគហ៊ុនរបស់ក្រុមហ៊ុន ដែលនាំឱ្យមានការលំបាកអនុវត្តដោយបង្ខំនាពេលក្រោយ តុលាការសម្រេចតាម ពាក្យស្នើសុំរបស់ម្ចាស់បំណុល។

៥-ដើម្បីទទួលបានឆន្ទៈការលុបចោលការអនុវត្តការរឹបអូសជាបណ្តោះអាសន្នេះ សហកូនបំណុលត្រូវ ធ្វើប្រាក់នៅតុលាការចំនួន ៣.២៩៥.២៩៥,៩៣ (បីលានប្រាំបួនម៉ឺនប្រាំពាន់ពីររយកាសិបប្រាំ និងកៅសិបបី សេន) ដុល្លារអាមេរិក ជាប្រាក់រំដោះស្របតាមបញ្ញត្តិមាត្រា ៥៤៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ហេតុដូច្នេះសម្រេច

១-រឹបអូសជាបណ្តោះអាសន្នទ្រព្យសម្បត្តិ និងសម្ភារៈទាំងអស់ដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុន
មានទីតាំងស្ថិតនៅផ្ទះ ... ភូមិ ... សង្កាត់ ... ... រាជធានីភ្នំពេញ។

២-រឹបអូសជាបណ្តោះអាសន្នភាគហ៊ុនរបស់ក្រុមហ៊ុន ... ដែលមាន វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... ចេញដោយក្រសួង ពាណិជ្ជកម្ម។

៣-សហកូនបំណុល ក្រុមហ៊ុន ... និងលោក ... ជា ម្ចាស់សហគ្រាស ត្រូវផ្តើប្រាក់ចំនួន ៣.២៩៥.២៩៥,៩៣ (បីលានប្រាំបួនម៉ឺនប្រាំពាន់ពីររយកាសិបប្រាំ និង កៅសិបបីសេន) ដុល្លារអាមេរិក ជាប្រាក់រំដោះ ដើម្បីទទួលបានការលុបចោលការរឹបអូសជាបណ្តោះអាសន្ន

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហកូនបំណុល។

៥-នីតិសាស្ត្របង្គេះមានអានុភាពអនុវត្តភ្លាម។

ភាគីសហកម្មនចំណុលមានសិទ្ធិដាក់ពាក្យសុំកាត់ទីងនីការសម្រេចខាងលើនេះតាមបញ្ញត្តិមាត្រា ៥៥០ នៃ
ក្រមនីតិវិធីរដ្ឋប្បវេណី។

ថ្ងៃអង្គារ ៣កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤
ចៅក្រម

ហត្ថលេខា និងក្រា

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"
រាជធានីភ្នំពេញ,ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤

បានឃើញ
រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤
ចៅក្រម

ឧបសម្ព័ន្ធទី៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

កំណត់ហេតុអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន
លេខ ចុះថ្ងៃទី ខែ ឆ្នាំ២០២៤
របស់សាលាដំបូងខេត្តកំពង់ចាម

ឆ្នាំពីរពាន់ម្ភៃបួន ខែ ថ្ងៃទី វេលាម៉ោង ប៊ី និងសូន្យសូន្យនាទីរសៀល ។

យើង ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកំពង់ចាម ជាមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ដោយមានលោក ជាក្រឡាបញ្ជីអមផង បានចុះអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលេខ ចុះថ្ងៃទី ខែ ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តកំពង់ចាម ដល់ទីតាំងស្ថិតនៅភូមិ ឃុំ ស្រុក ខេត្ត ដែលមានសមាសភាពចូលរួមដូចខាងក្រោម៖

១.លោក	ស្នងការរងនគរបាលខេត្តកំពង់ចាម
២.លោក	នាយរងការិយាល័យព្រហ្មទណ្ឌកំរិតស្រាល
៣.លោក	នាយរងការិយាល័យព្រហ្មទណ្ឌកំរិតស្រាល
-លោក ហេង ប៊ូរ៉ា	ជាមេធាវីតំណាងដោយអាណត្តិឱ្យឈ្មោះ និងឈ្មោះ ម្ចាស់បំណុលនៃការអនុវត្ត។ (មានវត្តមាន)
-ឈ្មោះ	ជាម្ចាស់បំណុលនៃការអនុវត្ត (មានវត្តមាន)
-ឈ្មោះ	ជាកូនបំណុលនៃការអនុវត្ត (មានវត្តមាន)

នៅពេលយើងបានដឹកនាំកម្លាំងចុះអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដល់ចំណុចក្រោយ ស្ថិតភូមិ ឃុំ ស្រុក ខេត្តកំពង់ចាម បានជួបរថយន្តមួយគ្រឿងម៉ាក HYUNDAI ពណ៌ ពាក់ផ្លាកលេខ ស៊េរីឆ្នាំ គ្មានកាងខាងមុខ និងផ្លាកលេខខាងមុខ និងមានអាគុយខូចចំនួន០២គ្រឿង) ដែលបើកបរដោយឈ្មោះ ភេទប្រុស អាយុ ឆ្នាំ ជាកូនបំណុលនៃការអនុវត្ត ហើយយើងបានអានដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលេខ ចុះថ្ងៃទី ខែ ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តកំពង់ចាម ឱ្យសមាសភាពដែលមានវត្តមាននៅទីកន្លែងនោះស្តាប់នូវសេចក្តីសម្រេចទាំងស្រុង។ បន្ទាប់មក យើងបានពិនិត្យលើគ្រឿងរថយន្តឃើញថា រថយន្តនេះជាកម្មវត្ថុនៃការអនុវត្ត ក៏អនុញ្ញាតឱ្យឈ្មោះ យករបស់របរមានក្នុងរថយន្តនេះដែលមិនពាក់ព័ន្ធនឹងការអនុវត្តចេញវិញទាំងអស់ ដោយពុំកោននៅសល់របស់អ្វីទៀតទេ។ ឈ្មោះ បានឆ្លើយថារថយន្តនេះជាកម្មសិទ្ធិរបស់ខ្លួនពិតប្រាកដមែន ខ្លួនពុំតវ៉ាអ្វីទេ។

ក្រោយពីបានត្រួតពិនិត្យចប់សព្វគ្រប់ យើងសម្រេចរឹបអូសជាបណ្តោះអាសន្ននូវរថយន្តមួយគ្រឿង ម៉ាក HYUNDAI ពណ៌ខៀវ ពាក់ផ្លាកលេខ កំពង់ចាម សេរីឆ្នាំ តាមអំណាចដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលេខ ចុះថ្ងៃ ខែ ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តកំពង់ចាម និងបានយករថយន្តនេះមករក្សាទុកនៅស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម ដោយប្រគល់ជូនលោក វ.ទោ ; និងលោក នាយរងការិយាល័យព្រហ្មទណ្ឌកំរិតស្រាល ជាអ្នកមើលថែរក្សាទុក។

បញ្ឈប់កំណត់ហេតុនៅវេលាម៉ោង ពី និងសាអស៊ីរ៉ា នាទី រៀងរៃ ថ្ងៃខែឆ្នាំខាងលើ រួចបានអានសេចក្តីទាំងស្រុង នៃកំណត់ហេតុនេះឱ្យសមាសភាពចូលរួម និងគូភាគីស្តាប់ រួចបានចុះហត្ថលេខា និងជ្រិតមេដៃជាមួយយើង។

ម្ចាស់បំណុល	កូនបំណុល	ក្រឡាបញ្ជី	ព្រះរាជអាជ្ញារង
នៃការអនុវត្ត	នៃការអនុវត្ត		(មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា)

សមាសភាពចូលរួម	មន្ត្រីទទួលថែរក្សារថយន្ត
១.លោក	
២.លោក	
៣.លោក	

មេធាវី

ឧបសម្ព័ន្ធទី៨

គន្លឹះ ៧

ការចាត់ចែងរក្សាការពារ

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ៥៣០.- គោលគំនិត

ប្រសិនបើមានការចារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់ភ្នួនបំណុលនៃការអនុវត្ត ឬ ប្រសិនបើមានការចារម្ភថា នឹងមានការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដល់ឋានៈរបស់ភាគីណាមួយ ដោយសារមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិ បុគ្គលដែលមានបំណងចង់ការពារសិទ្ធិរបស់ខ្លួន អាចទាមទារការចាត់ចែងរក្សាការពារ តាមបញ្ញត្តិនៃគន្លឹះនេះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ផ្សេង ។

មាត្រា ៥៣១.- ប្រភេទនៃការចាត់ចែងរក្សាការពារ

ការចាត់ចែងរក្សាការពារសំដៅទៅលើការចាត់ចែងនីមួយៗ ដែលមានខ្លឹមសារដូចកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ :

ក-ការរឹបអូសជាបណ្តោះអាសន្ន : ការចាត់ចែងដែលកម្រិតន្ទូវការចាត់ចែងទ្រព្យសម្បត្តិរបស់ភ្នួនបំណុល ដើម្បីរក្សាការពារការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ។

ខ-ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ : ការចាត់ចែងដែលរក្សាទុកន្ទូវស្ថានភាពបច្ចុប្បន្ន នៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ ក្នុងករណីដែលមានការចារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិ ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ ។

គ-ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន : ការចាត់ចែងដែលកំណត់ស្ថានភាពជាបណ្តោះអាសន្នរហូតដល់សាលក្រម ឬ សាលដីកាចូល

ជាស្ថាពរ ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុល ចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ ។

មាត្រា ៥៣២. ស្ថាប័នចាត់ចែងរក្សាការពារជាបណ្តោះអាសន្ន

១-ជីកាសម្រេចក្នុងការចាត់ចែងរក្សាការពារ ត្រូវធ្វើឡើងដោយតុលាការតាមពាក្យសុំ ។

២-ការអនុវត្តការចាត់ចែងរក្សាការពារ ត្រូវធ្វើឡើងដោយតុលាការ ឬ អាជ្ញាសាលាតាមពាក្យសុំ ។

៣-តុលាការដែលត្រូវអនុវត្តការចាត់ចែងរក្សាការពារ តាមបញ្ញត្តិនៃគន្ថីនេះ ត្រូវហៅថា តុលាការអនុវត្តការរក្សាការពារ ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ៤ នៃមាត្រា ៣៣៦ (ស្ថាប័នអនុវត្ត) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តការចាត់ចែងរក្សាការពារ ដែលធ្វើឡើងដោយអាជ្ញាសាលា ។

មាត្រា ៥៣៣. សមត្ថកិច្ចផ្តាច់មុខ

សមត្ថកិច្ចរបស់តុលាការដែលបានកំណត់នៅក្នុងគន្ថីនេះ គឺជាសមត្ថកិច្ចផ្តាច់មុខ ។

មាត្រា ៥៣៤. របៀបដាក់ពាក្យសុំ

ពាក្យសុំដែលបានកំណត់ខាងក្រោមនេះ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ :

ក-ពាក្យសុំឱ្យចេញជីកាសម្រេចរក្សាការពារ ។

ខ-ពាក្យបណ្តឹងជំទាស់ចំពោះជីកាសម្រេចលើកចោលពាក្យសុំឱ្យចេញជីកាសម្រេចរក្សាការពារ ។

គ-ពាក្យសុំតវ៉ាចំពោះការរក្សាការពារ ។

ឃ-ពាក្យសុំឱ្យលុបចោលជីកាសម្រេចរក្សាការពារ ។

ង-ពាក្យបណ្តឹងជំទាស់ដែលបានកំណត់នៅក្នុងមាត្រា ៥៦១ (បណ្តឹងជំទាស់) នៃក្រមនេះ ។

ច-ពាក្យសុំឱ្យអនុវត្តការរក្សាការពារ ។

មាត្រា ៥៣៥.- ការសម្រេចសេចក្តីចំពោះនីតិវិធីនៃការរក្សាការពារ ជាអាទិ៍

១-ការសម្រេចសេចក្តីដែលទាក់ទងនឹងនីតិវិធីនៃដីកាសម្រេចរក្សាការពារ និងនីតិ-វិធីដែលតុលាការធ្វើចំពោះការអនុវត្តរក្សាការពារ ត្រូវធ្វើឡើងដោយដីកាសម្រេច ។

២-បើយល់ឃើញថាចាំបាច់ នៅពេលចាត់ចែងធ្វើការអនុវត្ត តុលាការអនុវត្តការរក្សា-ការពារ អាចសួរជនដែលមានផលប្រយោជន៍ពាក់ព័ន្ធ ឬជនដែលពាក់ព័ន្ធផ្សេងទៀតបាន ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសាលាជំបួងត្រូវសម្រេចសេចក្តីអំពីឧបាស្រ័យចំពោះការចាត់ចែងការ-អនុវត្ត ដែលធ្វើឡើងដោយអាជ្ញាសាលា ។

មាត្រា ៥៣៦.- ការផ្តល់ទ្វប្រាតិភោគ

ដើម្បីដាក់ប្រាតិភោគតាមបញ្ញត្តិនៃគន្ថីនេះ ភាគីត្រូវធ្វើតាមវិធីធ្វើប្រាក់ ឬឧបករណ៍-អាចជួញដូរបាន ដែលតុលាការទទួលស្គាល់ថាសមរម្យ ទៅតុលាការដែលបង្គាប់ឱ្យដាក់-ប្រាតិភោគនោះ ឬតុលាការអនុវត្តការរក្សាការពារ ។

មាត្រា ៥៣៧.- សោហ៊ុយនៃការចាត់ចែងរក្សាការពារ ជាអាទិ៍

១-ក្នុងករណីដែលដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ អ្នកដែលដាក់ពាក្យ-សុំ ត្រូវបង់ពន្ធចំនួន ៥.០០០ (ប្រាំពាន់) រៀល ទៅតុលាការ ។

២-ពេលដាក់ពាក្យសុំឱ្យធ្វើការអនុវត្តការរក្សាការពារទៅតុលាការអនុវត្តការរក្សា-ការពារ អ្នកដែលដាក់ពាក្យសុំ ត្រូវបង់ជាមុនទ្វរចំនួនទឹកប្រាក់ដែលកំណត់ដោយតុលាការ-អនុវត្តការរក្សាការពារ ដែលជាសោហ៊ុយចាំបាច់សម្រាប់នីតិវិធីអនុវត្តការរក្សាការពារ ។

៣-ប្រសិនបើអ្នកដែលដាក់ពាក្យសុំមិនបានបង់សោហ៊ុយនោះទុកជាមុនទេ តុលា-ការអនុវត្តការរក្សាការពារ អាចលើកចោលពាក្យសុំឱ្យធ្វើការអនុវត្តការរក្សាការពារ ឬអាច-លុបចោលទ្វរនីតិវិធីអនុវត្តការរក្សាការពារបាន ។

៤-ចំពោះដីកាសម្រេចលើកចោលទ្វរពាក្យសុំ តាមបញ្ញត្តិនៃកថាខណ្ឌទី ៣ អាចប្តឹង-ជំទាស់បាន ។

៥-ក្នុងករណីដែលដាក់ពាក្យសុំឱ្យអនុវត្តការរក្សាការពារចំពោះអាជ្ញាសាលា អ្នក-ដែលដាក់ពាក្យសុំត្រូវបង់ពន្ធ តាមបញ្ញត្តិដែលបានកំណត់ផ្សេង ។

មាត្រា ៥៣៨.– ការមើលសំណុំរឿងនៃការចាត់ចែងរក្សាការពារ ជាអាទិ៍

១-ជនដែលបានធ្វើសេចក្តីបញ្ជាក់ដំបូងអំពីការពាក់ព័ន្ធនឹងផលប្រយោជន៍ ចំពោះនីតិវិធីទាក់ទងនឹងជីកាសម្រេចរក្សាការពារ ឬ នីតិវិធីដែលតុលាការធ្វើឡើងចំពោះការអនុវត្តរក្សាការពារ អាចទាមទារមើលសំណុំរឿង ថតចម្លងសំណុំរឿង ឱ្យប្រគល់ឯកសារចម្លងយថាភ្លត ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឬ ឯកសារដកស្រង់នៃសំណុំរឿង ឬ អាចទាមទារឱ្យប្រគល់លិខិតបញ្ជាក់អំពីចំណុចដែលពាក់ព័ន្ធនឹងរឿងក្តី ពីតុលាការបាន ដោយបង់ពន្ធ ។

២-ជនដែលបានធ្វើសេចក្តីបញ្ជាក់ដំបូងអំពីការពាក់ព័ន្ធនឹងផលប្រយោជន៍ ចំពោះការអនុវត្តរក្សាការពារដែលធ្វើឡើងដោយអាជ្ញាសាលា អាចទាមទារមើលសំណុំរឿង ថតចម្លងសំណុំរឿង ឱ្យប្រគល់ឯកសារចម្លងយថាភ្លត ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឬ ឯកសារដកស្រង់នៃសំណុំរឿង ឬ អាចទាមទារឱ្យប្រគល់លិខិតបញ្ជាក់អំពីចំណុចដែលពាក់ព័ន្ធនឹងរឿងក្តី ពីអាជ្ញាសាលាបាន ដោយបង់ពន្ធ ។

មាត្រា ៥៣៩.– ការអនុវត្តដូចគ្នា តាមបញ្ញត្តិពីគន្លឹះទី ២ ដល់គន្លឹះទី ៤

បញ្ញត្តិពីគន្លឹះទី ២ ដល់គន្លឹះទី ៤ នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការចាត់ចែងរក្សាការពារ លើកលែងតែមានបញ្ញត្តិពិសេស ។

ជំពូកទី ២
ជីកាសម្រេចរក្សាការពារ

ផ្នែកទី ១
បទប្បញ្ញត្តិទូទៅ

មាត្រា ៥៤០.– តុលាការដែលមានសមត្ថកិច្ច

១-រឿងក្តីនៃជីកាសម្រេចរក្សាការពារ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី ឬ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្តោះអាសន្ន ឬ វត្ថុដែលជាកម្មវត្ថុនៃវិវាទ ស្ថិតនៅ ។

២-តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី គឺជាតុលាការនៃការជំនុំជម្រះលើកទី ១ ។ ប៉ុន្តែ បើអង្គសេចក្តី ត្រូវបានចាត់ការ ក្នុងនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី គឺជាតុលាការនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ។

៣-បើកម្មវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្តោះអាសន្ន ឬ កម្មវត្ថុនៃវិវាទ ជាសិទ្ធិលើបំណុល ត្រូវចាត់ទុកថា សិទ្ធិលើបំណុលនោះ ស្ថិតនៅកន្លែងរបស់កូនបំណុលទី ៣ ដែលបានកំណត់នៅក្នុងមាត្រា ៨ (សមត្ថកិច្ចសាលាជម្រះក្តីដែលបានកំណត់ទៅតាមលំនៅឋានជាអាទិ៍) នៃក្រមនេះ ។ ប៉ុន្តែ ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងប្រគល់នាវា ឬ ចលនវត្ថុ ត្រូវចាត់ទុកថា សិទ្ធិលើបំណុលនោះស្ថិតនៅទីកន្លែងដែលវត្ថុនោះស្ថិតនៅ ។

៤-បញ្ញត្តិនៃវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលកម្មវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្តោះអាសន្ន ឬ កម្មវត្ថុនៃវិវាទ ជាសិទ្ធិលើទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងមាត្រា ៤១៦ (ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត) នៃក្រមនេះ ហើយមានកូនបំណុលទី ៣ ឬ បុគ្គលដែលមានលក្ខណៈដូចជាកូនបំណុលទី ៣ ។

មាត្រា ៥៤១.- ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ និង សេចក្តីបញ្ជាក់ជំទួង

១-ក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ត្រូវសរសេរបញ្ជាក់ឱ្យច្បាស់នូវចំណុចដូចបានកំណត់ខាងក្រោមនេះ :

ក-ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ-ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ ។

គ-សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ ។

ឃ-ភាពចាំបាច់នៃការរក្សាការពារ ។

២-ចំពោះចំណុច គ និង ឃ នៃកថាខណ្ឌទី ១ ខាងលើនេះ អ្នកដែលដាក់ពាក្យសុំ គប្បីសរសេរឱ្យបានច្បាស់លាស់ និង សរសេរឱ្យវិភាគតាង តាមហេតុនីមួយៗដែលត្រូវបញ្ជាក់ ។

៣-ចំពោះចំណុច គ និង ឃ នៃកថាខណ្ឌទី ១ ខាងលើនេះ អ្នកដែលដាក់ពាក្យសុំត្រូវធ្វើសេចក្តីបញ្ជាក់ជំទួង ។

មាត្រា ៥៤២.– ប្រាតិភោគសម្រាប់ដីកាសម្រេចរក្សាការពារ

ដីកាសម្រេចរក្សាការពារ អាចធ្វើដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគបាន ។

មាត្រា ៥៤៣.– ការបញ្ជូន

តុលាការត្រូវបញ្ជូនដីកាសម្រេចរក្សាការពារទៅភាគី ។

មាត្រា ៥៤៤.– បណ្តឹងជំទាស់ចំពោះសេចក្តីសម្រេចលើកចោល

១-ចំពោះសេចក្តីសម្រេចដែលលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ម្ចាស់បំណុលអាចប្តឹងជំទាស់បាន ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ចាប់ពីថ្ងៃដែលខ្លួនបានទទួលការជូនដំណឹង ។

២-អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចពន្យារបានឡើយ ។

ផ្នែកទី ២
ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

មាត្រា ៥៤៥.– ភាពចាំបាច់នៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

១-ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន អាចចេញបានចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ ក្នុងករណីដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ។

២-ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន អាចចេញបាន ទោះបីជាសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ភ្ជាប់នឹងល័ក្ខខ័ណ្ឌ ឬ ពេលកំណត់ក៏ដោយ ។

មាត្រា ៥៤៦.– កម្មវត្ថុនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

តុលាការត្រូវចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដោយកំណត់ជាក់លាក់នូវកម្មវត្ថុ ។ ប៉ុន្តែ ចំពោះដីកាសម្រេចរឹបអូសចលនវត្ថុជាបណ្តោះអាសន្ន អាចចេញបាន

ដោយមិនចាំបាច់កំណត់កម្មវត្ថុ ។

មាត្រា ៥៤៧.- ប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន

១-ក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តុលាការត្រូវកំណត់ចំនួនទឹកប្រាក់ដែលភ្ជួនបំណុលត្រូវធ្វើ ដើម្បីទទួលបានន្យវការលុបចោលការអនុវត្តការរឹបអូសជាបណ្តោះ-អាសន្ន ។

២-ការធ្វើប្រាក់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ ត្រូវធ្វើឡើងនៅតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬ តុលាការអនុវត្តការរក្សាការពារ ។

ផ្នែកទី ៣
ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន

មាត្រា ៥៤៨.- ភាពចាំបាច់នៃដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ជាអាទិ៍

១-តុលាការអាចចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទបាន ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ ។

២-តុលាការអាចចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខ្ចប់ខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុល ចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៥៤៥ (ភាពចាំបាច់នៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ។

៤-តុលាការមិនអាចចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ បានឡើយ បើមិនឆ្លងកាត់តាមកាលបរិច្ឆេទនៃការ

ទាញហេតុផលដោយផ្ទាល់មាត់ ឬតាមកាលបរិច្ឆេទនៃការស្នើដែលភ្នែបំណុលអាចចូលរួមបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានស្ថានភាពពិសេស ដែលនាំឱ្យពុំអាចសម្រេចគោលបំណងនៃពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ដោយសារឆ្លងកាត់តាមកាលបរិច្ឆេទនោះ ។

មាត្រា ៥៤៩.- វិធីចាត់ចែងជាបណ្តោះអាសន្ន

តុលាការអាចចាត់ចែងឱ្យភ្នែបំណុលធ្វើ ឬ មិនធ្វើអំពើណាមួយជាកំណត់ ឬឱ្យភ្នែបំណុលផ្តល់តាវកាលិក ឬឱ្យអ្នកថែរក្សាគ្រប់គ្រង ថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃការចាត់ចែងជាបណ្តោះអាសន្ន ឬធ្វើការចាត់ចែងផ្សេងទៀតបាន តាមកម្រិតនៃភាពចាំបាច់ដើម្បីសម្រេចគោលបំណងនៃពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ។

ផ្នែកទី ៤
ការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

មាត្រា ៥៥០.- ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

ភ្នែបំណុលអាចដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ទៅតុលាការដែលបានចេញដីកាសម្រេចនោះ ។

មាត្រា ៥៥១.- ការសម្រេចសេចក្តីអំពីការផ្អាកការអនុវត្តរក្សាការពារជាអាទិ៍

១-ក្នុងករណីដែលមានពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការអាចបង្គាប់ឱ្យផ្អាកការអនុវត្តរក្សាការពារ ឬ លុបចោលការចាត់ចែងការអនុវត្ត តាមពាក្យសុំដោយឱ្យដាក់ប្រាតិភោគបាន រហូតដល់ធ្វើការសម្រេចសេចក្តី តាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងក្រោមនេះ ក្នុងដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ លុះត្រាតែមានសេចក្តីបញ្ជាក់ជំទ្ងួងអំពីស្ថានភាពដែលច្បាស់ថា នឹងក្លាយជាមូលហេតុនៃការលុបចោលដីកាសម្រេចរក្សាការពារ និង អំពីការដែលមានការបារម្ភថា ការខូចខាតដែលមិនអាចសងបាន នឹងកើតឡើងដោយសារការអនុវត្តរក្សាការពារ ។

២-ក្នុងករណីដែលតុលាការនៃបណ្តឹងជំទាស់បានចេញដីកាសម្រេចរក្សាការពារ បើមានសំណុំរឿងនៅតុលាការជើម តុលាការជើមនោះក៏អាចធ្វើការសម្រេចសេចក្តី តាម

បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះបានដែរ ។

៣-នៅក្នុងដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការត្រូវលុបចោល ផ្លាស់ប្តូរ ឬ ទទួលស្គាល់នូវសេចក្តីសម្រេចដែលបានធ្វើរួចហើយ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

មាត្រា ៥៥២.- ការវិនិច្ឆ័យអំពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

តុលាការមិនអាចចេញដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារបានឡើយ បើមិនបានឆ្លងកាត់តាមកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ តាមកាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន ។

មាត្រា ៥៥៣.- ការបញ្ចប់ការវិនិច្ឆ័យ

ដើម្បីបញ្ចប់ការវិនិច្ឆ័យអំពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការត្រូវសម្រេចថ្ងៃបញ្ចប់ការវិនិច្ឆ័យ ដោយកំណត់អំឡុងពេលអនុគ្រោះដ៏សមរម្យ ។ ប៉ុន្តែ នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន តុលាការអាចប្រកាសដោយភ្លាមៗថា បញ្ចប់ការវិនិច្ឆ័យ ។

មាត្រា ៥៥៤.- ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

១-នៅក្នុងដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការត្រូវទទួលស្គាល់ ផ្លាស់ប្តូរ ឬ លុបចោលនូវដីកាសម្រេចរក្សាការពារ ។

២-ចំពោះដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារដែលធ្វើឡើងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការអាចដាក់ល័ក្ខខ័ណ្ឌឱ្យភ្ជួនបំណុលដាក់ប្រាតិភោគបាន ។

៣-បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ ។

មាត្រា ៥៥៥.- ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន

បើម្ចាស់បំណុលបានទទួលការប្រគល់វត្ថុ ឬ ការបង់ប្រាក់ ឬ ប្រើប្រាស់ឬថែរក្សាគ្រប់គ្រងវត្ថុ ដោយផ្អែកលើដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន តុលាការអាចបង្គាប់

ឱ្យម្ចាស់បំណុលបង្វិលសងវត្ថុដែលកូនបំណុលបានប្រគល់ ឬ សងប្រាក់ដែលកូនបំណុលបានបង់ ឬ បង្វិលសងវត្ថុដែលម្ចាស់បំណុលកំពុងប្រើប្រាស់ឬថែរក្សាគ្រប់គ្រងបាន តាមពាក្យសុំរបស់កូនបំណុល នៅក្នុងដីកាសម្រេចដែលលុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន តាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥៤ (ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) នៃក្រមនេះ ។

មាត្រា ៥៥៦.– អានុភាពនៃដីកាសម្រេចដែលលុបចោលដីកាសម្រេចរក្សាការពារ

ដីកាសម្រេចដែលលុបចោលដីកាសម្រេចរក្សាការពារ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៥៥៤ (ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) នៃក្រមនេះ ពុំមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរ ។ ប៉ុន្តែ បើយល់ឃើញថា ចាំបាច់ពិសេស តុលាការអាចប្រកាសថា ដីកាសម្រេចនោះមានអានុភាពភ្លាមៗ ។

ផ្នែកទី ៥
ការលុបចោលដីកាសម្រេចរក្សាការពារ

មាត្រា ៥៥៧.– ការលុបចោលដីកាសម្រេចរក្សាការពារដោយសារមិនដាក់ពាក្យបណ្តឹងអង្គសេចក្តី ជាអាទិ៍

១-តុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ត្រូវបង្គាប់ឱ្យម្ចាស់បំណុលដាក់ពាក្យបណ្តឹងអង្គសេចក្តី ហើយឱ្យដាក់ឯកសារដែលបញ្ជាក់អំពីការដាក់ពាក្យបណ្តឹងនោះ ក្នុងអំឡុងពេលដែលទទួលស្គាល់ថាសមរម្យ តាមពាក្យសុំរបស់កូនបំណុល ។

២-អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវមានរយៈពេលមិនតិចជាង ២ (ពីរ) សប្តាហ៍ ។

៣-បើម្ចាស់បំណុលមិនដាក់ឯកសារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្នុងអំឡុងពេលដែលត្រូវបានកំណត់ តាមបញ្ញត្តិនៃកថាខណ្ឌដដែលនោះ តុលាការត្រូវលុបចោលដីកាសម្រេចរក្សាការពារ តាមពាក្យសុំរបស់កូនបំណុល ។

៤-ក្នុងករណីដែលពាក្យបណ្តឹងអង្គសេចក្តីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានដកវិញ ឬ ត្រូវបានលើកចោល នៅក្រោយពេលដែលឯកសារដែល

បានកំណត់នៅក្នុងកថាខណ្ឌទី ១ ដដែលនោះ ត្រូវបានដាក់ ត្រូវចាត់ទុកថា ឯកសារនោះមិនបានដាក់ឡើយ ។

៥-ចំពោះការអនុវត្តបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ៣ ខាងលើនេះ បើមានកិច្ចសន្យាមជ្ឈត្តកម្មអំពីអង្គសេចក្តី ការចាប់ផ្តើមនីតិវិធីមជ្ឈត្តកម្ម ត្រូវចាត់ទុកជាការដាក់ពាក្យបណ្តឹងអង្គសេចក្តី ។

៦-បើនីតិវិធីមជ្ឈត្តកម្មដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៥ ខាងលើនេះ បានចប់មិនមែនដោយសេចក្តីសម្រេចមជ្ឈត្តករ ម្ចាស់បំណុលត្រូវដាក់ពាក្យបណ្តឹងអង្គសេចក្តី ក្នុងអំឡុងពេលដូចគ្នានឹងអំឡុងពេលដែលបានកំណត់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ចាប់ពីថ្ងៃដែលនីតិវិធីមជ្ឈត្តកម្មនោះបានចប់ ។

៧-បញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលម្ចាស់បំណុលមិនបានដាក់ពាក្យបណ្តឹងអង្គសេចក្តីតាមបញ្ញត្តិនៃកថាខណ្ឌទី ៦ ហើយបញ្ញត្តិនៃកថាខណ្ឌទី ៤ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបណ្តឹងអង្គសេចក្តីត្រូវបានដាក់តាមបញ្ញត្តិនៃកថាខណ្ឌទី ៦ តែក្រោយមកត្រូវបានដកវិញ ឬ ត្រូវបានលើកចោល ។

៨-បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចតាមកថាខណ្ឌទី ៣ និង ទី ៧ ។

មាត្រា ៥៥៨.- ការលុបចោលដីកាសម្រេចរក្សាការពារ ដោយសារការផ្លាស់ប្តូរស្ថានភាព

១-បើមានការរលត់សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ ឬ ភាពចាំបាច់ក្នុងការរក្សាការពារ ឬ ការផ្លាស់ប្តូរផ្សេងទៀតនៃស្ថានភាព តុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ឬ តុលាការនៃបណ្តឹងអង្គសេចក្តី អាចលុបចោលដីកាសម្រេចរក្សាការពារ តាមពាក្យសុំរបស់ភ្នាក់បំណុលបាន ។

២-ចំពោះការផ្លាស់ប្តូរស្ថានភាពដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ភ្នាក់បំណុលត្រូវធ្វើសេចក្តីបញ្ជាក់ជំហ្វង ។

៣-បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) និង កថាខណ្ឌទី ២ នៃមាត្រា ៥៥៤ (ដីកា

សម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) នៃក្រមនេះ ត្រូវយកមកអនុវត្ត ដូចគ្នាផងដែរ ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

មាត្រា ៥៥៩.- ការលុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ដោយសារស្ថានភាពពិសេស

១-ប្រសិនបើមានការបារម្ភថា ការខូចខាតដែលមិនអាចសងបាន នឹងកើតឡើងដោយសារដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ឬ មានស្ថានភាពពិសេសផ្សេងទៀត តុលាការដែលបានចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ឬ តុលាការនៃបណ្តឹងអង្គសេចក្តី អាចលុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ននោះបាន ដោយមានល័ក្ខខ័ណ្ឌ តម្រូវឱ្យដាក់ប្រាតិភោគ តាមពាក្យសុំរបស់ភ្នែនបំណុល ។

២-ចំពោះស្ថានភាពពិសេសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ ភ្នែនបំណុល ត្រូវធ្វើសេចក្តីបញ្ជាក់ជំហ្ងង ។

៣-បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

មាត្រា ៥៦០.- ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ជាអាទិ៍

១-បញ្ញត្តិពីមាត្រា ៥៥១ (ការសម្រេចសេចក្តីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍) ដល់មាត្រា ៥៥៣ (ការបញ្ចប់ការវិនិច្ឆ័យ) មាត្រា ៥៥៥ (ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន) និង មាត្រា ៥៥៦ (អានុភាពនៃដីកាសម្រេចដែលលុបចោលដីកាសម្រេចរក្សាការពារ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការសម្រេចសេចក្តីអំពីការលុបចោលដីកាសម្រេចរក្សាការពារ លើកលែងតែចំពោះការសម្រេចសេចក្តី តាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥៧ (ការលុបចោលដីកាសម្រេចរក្សាការពារដោយសារមិនដាក់ពាក្យបណ្តឹងអង្គសេចក្តី ជាអាទិ៍) ។

២-ចំពោះការសម្រេចសេចក្តីតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥១ (ការសម្រេចសេចក្តីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍) នៃក្រមនេះ ដែលត្រូវយកមកអនុវត្ត

ដូចគ្នា នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្នុងករណីដែលពាក្យសុំលុបចោលជីកាសម្រេចរក្សាការពារ ត្រូវបានដាក់ទៅតុលាការនៃបណ្តឹងអង្គសេចក្តី ផ្សេងពីតុលាការដែលបានចេញជីកាសម្រេចរក្សាការពារ ហើយមានសំណុំរឿងនៅតុលាការដែលបានចេញជីកាសម្រេចរក្សាការពារ តុលាការដែលបានចេញជីកាសម្រេចរក្សាការពារនោះ ក៏អាចធ្វើការសម្រេចសេចក្តី តាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥១ នោះបានដែរ ។

ផ្នែកទី ៦
បណ្តឹងជំទាស់

មាត្រា ៥៦១._ បណ្តឹងជំទាស់

១-ចំពោះជីកាសម្រេចដែលបានកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ អាចប្តឹងជំទាស់ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ចាប់ពីថ្ងៃដែលបានទទួលការបញ្ជូននោះ :

ក-ជីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះជីកាសម្រេចរក្សាការពារ ឬ ពាក្យសុំទាមទារឱ្យលុបចោលជីកាសម្រេចរក្សាការពារ ។

ខ-ជីកាសម្រេចដែលយោងតាមបញ្ញត្តិនៃមាត្រា ៥៥៥ (ជីកាសម្រេចបង្គាប់ឱ្យធ្វើបជិទាន) នៃក្រមនេះ ។

គ-ជីកាសម្រេចដែលយោងតាមបញ្ញត្តិនៃមាត្រា ៥៥៥ (ជីកាសម្រេចបង្គាប់ឱ្យធ្វើបជិទាន) នៃក្រមនេះ ដែលត្រូវយកមកអនុវត្តដូចគ្នា នៅក្នុងកថាខណ្ឌទី ១ មាត្រា ៥៦០ (ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីការតវ៉ាចំពោះជីកាសម្រេចរក្សាការពារ ជាអាទិ៍) ។

ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសេចក្តីសម្រេចអំពីពាក្យសុំតវ៉ាចំពោះជីកាសម្រេចរក្សាការពារ ដែលបានធ្វើឡើងដោយតុលាការនៃបណ្តឹងជំទាស់ ។

២-អំឡុងពេលដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ ពុំអាចពន្យារបានទេ ។

៣-បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) និង មាត្រា ៥៥៤ (ជីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះជីកាសម្រេចរក្សាការពារ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះជីកាសម្រេចអំពីបណ្តឹងជំទាស់ ហើយបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៥៥១ (ការសម្រេចសេចក្តីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍) មាត្រា ៥៥២ (ការវិនិច្ឆ័យអំពីការតវ៉ា

ចំពោះជីកាសម្រេចរក្សាការពារ) មាត្រា ៥៥៣ (ការបញ្ចប់ការវិនិច្ឆ័យ) និង មាត្រា ៥៥៥ (ជីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការសម្រេចសេចក្តីដែលពាក់ព័ន្ធនឹងបណ្តឹងជំទាស់ ហើយបញ្ញត្តិនៃមាត្រា ៣១៧ (ពាក្យសុំឱ្យជំនុំជម្រះសាជាថ្មីចំពោះជីកាសម្រេច) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសេចក្តីសម្រេចដែលអាចប្តឹងជំទាស់បាន បានចូលជាស្ថាពរ ។

៤-ចំពោះការសម្រេចសេចក្តីតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥១ (ការសម្រេចសេចក្តីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍) នៃក្រមនេះ ដែលត្រូវយកមកអនុវត្តដូចគ្នា នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ក្នុងករណីដែលមានសំណុំរឿងនៅតុលាការដើម តុលាការដើមនោះក៏អាចធ្វើការសម្រេចសេចក្តីតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥១ នោះបានដែរ ។

ជំពូកទី ៣

ការអនុវត្តរក្សាការពារ

មាត្រា ៥៦២. លក្ខខ័ណ្ឌនៃការអនុវត្តរក្សាការពារ

១-ការអនុវត្តរក្សាការពារត្រូវធ្វើឡើងដោយផ្អែកលើឯកសារចម្លងយថាភ្ជុតនៃជីកាសម្រេចរក្សាការពារ ។ ប៉ុន្តែ ការអនុវត្តរក្សាការពារចំពោះ ឬ សម្រាប់ជនក្រៅពីភាគី ដែលត្រូវបានកំណត់នៅក្នុងជីកាសម្រេចរក្សាការពារ ត្រូវធ្វើឡើង ដោយផ្អែកលើឯកសារចម្លងយថាភ្ជុតនៃជីកាសម្រេចរក្សាការពារដែលភ្ជាប់នឹងរូបមន្តអនុវត្ត ។

២-ការអនុវត្តរក្សាការពារ មិនត្រូវធ្វើឡើយ បើអំឡុងពេល ២ (ពីរ) សប្តាហ៍ បានកន្លងហួសចាប់ពីថ្ងៃដែលជីកាសម្រេចរក្សាការពារ ត្រូវបានបញ្ជូនទៅម្ចាស់បំណុល ។

៣-ទោះបីនៅមុនពេលដែលជីកាសម្រេចរក្សាការពារ ត្រូវបានបញ្ជូនទៅភ្នែនបំណុលក៏ដោយ ក៏ការអនុវត្តរក្សាការពារ អាចធ្វើបានដែរ ។

មាត្រា ៥៦៣.- ករណីពិសេសនៃតុលាការដែលមានសមត្ថកិច្ចលើបណ្តឹងតវ៉ារបស់តតិយជន

ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣៦៥ (បណ្តឹងតវ៉ារបស់តតិយជន) នៃក្រមនេះក៏ដោយ ក៏បណ្តឹងតវ៉ារបស់តតិយជន ចំពោះដីកាសម្រេចរក្សាការពារដែលសាលាឧទ្ធរណ៍បានធ្វើ ក្នុងនាមជាតុលាការអនុវត្តរក្សាការពារ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែង ដែលវត្ថុត្រូវរឹបអូសជាបណ្តោះអាសន្ន ឬ វត្ថុដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅ ។

មាត្រា ៥៦៤.- ការអនុវត្តដូចគ្នា តាមបញ្ញត្តិនៃគន្លឹះទី ៦

លើកលែងតែករណីដែលមានបញ្ញត្តិពិសេសក្នុងជំពូកនេះ បញ្ញត្តិពីមាត្រា ៣៣៨ (ការធានាក្នុងការបំពេញមុខនាទីរបស់អាជ្ញាសាលា ជាអាទិ៍) ដល់មាត្រា ៣៤៥ (បណ្តឹងជំទាស់ចំពោះដីកាសម្រេចលុបចោល ជាអាទិ៍) បញ្ញត្តិនៃមាត្រា ៣៤៨ (អ្នកតំណាងដោយអាណត្តិក្នុងនីតិវិធីទាក់ទងនឹងការអនុវត្តដោយបង្ខំ) បញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ៣៤៩ (របៀបដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ) កថាខណ្ឌទី ១ នៃមាត្រា ៣៥១ (វិសាលភាពនៃអ្នកដែលអាចអនុវត្តដោយបង្ខំ) កថាខណ្ឌទី ២ នៃមាត្រា ៣៥៤ (ភាពចាំបាច់នៃរូបមន្តអនុវត្ត និង ស្ថាប័នផ្តល់រូបមន្តអនុវត្ត) កថាខណ្ឌទី ១ និង ទី ៣ នៃមាត្រា ៣៥៥ (ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្ត) ពីកថាខណ្ឌទី ២ ដល់កថាខណ្ឌទី ៤ នៃមាត្រា ៣៥៦ (រូបមន្តអនុវត្តពិសេស) ពីមាត្រា ៣៥៧ (ចំណុចដែលត្រូវសរសេរក្នុងរូបមន្តអនុវត្ត) ដល់មាត្រា ៣៥៩ (ការសរសេរចូលទៅក្នុងច្បាប់ដើមនៃលិខិតអនុវត្ត) មាត្រា ៣៦២ (ពាក្យសុំតវ៉ាអំពីការផ្តល់រូបមន្តអនុវត្ត ជាអាទិ៍) បញ្ញត្តិនៃមាត្រា ៣៦៤ (បណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត) និង មាត្រា ៣៦៥ (បណ្តឹងតវ៉ារបស់តតិយជន) និង បញ្ញត្តិពីមាត្រា ៣៦៧ (ការសម្រេចសេចក្តីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ ជាអាទិ៍) ដល់មាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ) នៃក្រមនេះ ត្រូវយកមកអនុវត្ត ដូចគ្នាផងដែរ ចំពោះការអនុវត្តរក្សាការពារ ។

មាត្រា ៥៦៥.- ការអនុវត្តវិបអ្វសជាបណ្តោះអាសន្នចំពោះចលនវត្ថុ

១-ការអនុវត្តវិបអ្វសជាបណ្តោះអាសន្នចំពោះចលនវត្ថុ ត្រូវធ្វើតាមរបៀបកាន់កាប់វត្ថុដែលជាកម្មវត្ថុ ដោយអាជ្ញាសាលានៃសាលាជំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលវត្ថុដែលជាកម្មវត្ថុនោះស្ថិតនៅ។

២-អាជ្ញាសាលាត្រូវធ្វើប្រាក់ដែលបានមកពីការអនុវត្តវិបអ្វសជាបណ្តោះអាសន្ន នៅតុលាការដែលខ្លួនស្ថិតនៅ។

៣-បើមានការបារម្ភថា ចលនវត្ថុដែលការវិបអ្វសជាបណ្តោះអាសន្នត្រូវបានអនុវត្តនឹងចុះតម្លៃយ៉ាងខ្លាំង ឬ បើត្រូវការសោហ៊ុយច្រើនហួសហេតុដើម្បីរក្សាទុកចលនវត្ថុនោះ អាជ្ញាសាលាត្រូវលក់ចលនវត្ថុនោះ តាមនីតិវិធីលក់នៃការអនុវត្តចំពោះចលនវត្ថុដែលបានកំណត់នៅក្នុងផ្នែកទី ២ ជំពូកទី ២ នៃគន្ថីទី ៦ នៃក្រមនេះ តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការវិបអ្វសជាបណ្តោះអាសន្ន ឬ ក្ងនបំណុល ហើយធ្វើប្រាក់ដែលបានមកពីការលក់នោះនៅតុលាការដែលខ្លួនស្ថិតនៅ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៣៨៤ (ការចាប់ផ្តើមអនុវត្តចំពោះចលនវត្ថុ) ពីមាត្រា ៣៨៥ (ការវិបអ្វសចលនវត្ថុដែលកាន់កាប់ដោយក្ងនបំណុលនៃការអនុវត្ត) ដល់មាត្រា ៣៩២ (ការហាមឃាត់មិនឱ្យវិបអ្វសក្នុងករណីដែលប៉ាន់ប្រមាណឃើញថា គ្មានចំនួនសេសសល់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តវិបអ្វសជាបណ្តោះអាសន្នចំពោះចលនវត្ថុ។

មាត្រា ៥៦៦.- ការអនុវត្តវិបអ្វសជាបណ្តោះអាសន្ន ចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត

១-ការអនុវត្តវិបអ្វសជាបណ្តោះអាសន្ន ចំពោះសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងមាត្រា ៤០២ (អត្ថន័យនៃការអនុវត្តចំពោះសិទ្ធិលើបំណុល និង តុលាការអនុវត្ត) នៃក្រមនេះ ត្រូវធ្វើតាមរបៀបដែលតុលាការអនុវត្តរក្សាការពារ ចេញដីកាសម្រេចដែលហាមឃាត់មិនឱ្យក្ងនបំណុលទី ៣ សងទៅក្ងនបំណុល។

២-ចំពោះការអនុវត្តវិបអ្វសជាបណ្តោះអាសន្នដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការដែលបានចេញដីកាសម្រេចវិបអ្វសបណ្តោះអាសន្ន ត្រូវមានសមត្ថ-

កិច្ចជាតុលាការអនុវត្តរក្សាការពារ ។

៣-ក្នុងករណីដែលការរឹបអូសជាបណ្តោះអាសន្ន ត្រូវបានអនុវត្តចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ បើភ្នក់បំណុលទី៣បានធ្វើប្រាក់ដែលស្មើនឹងចំនួនប្រាក់នៃសិទ្ធិលើបំណុលនៅតុលាការ ត្រូវចាត់ទុកថា ភ្នក់បំណុលបានធ្វើប្រាក់ដែលស្មើនឹងចំនួនប្រាក់ដែលត្រូវបានកំណត់តាមបញ្ញត្តិនៃមាត្រា ៥៤៧ (ប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន) នៃក្រមនេះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះភាគដែលលើសពីចំនួនប្រាក់នោះ ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ត្រូវយកមកអនុវត្តផ្គួចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ។

៥-បញ្ញត្តិនៃកថាខណ្ឌទី ២ ទី ៣ ទី ៦ ទី៧ ទី ៨ ទី ១០ និង កថាខណ្ឌទី ១១ នៃមាត្រា ៤០៣ (ជីកាសម្រេចរឹបអូស) បញ្ញត្តិពីមាត្រា ៤០៤ (ទំហំនៃការរឹបអូស) ដល់មាត្រា ៤០៨ (ការជូនដំណឹងអំពីការដកពាក្យសុំ ជាអាទិ៍) មាត្រា ៤១១ (ការធ្វើប្រាក់ទុកដោយភ្នក់បំណុលទី ៣) និងមាត្រា ៤១៦ (ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត) នៃក្រមនេះ ត្រូវយកមកអនុវត្តផ្គួចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្តោះ-អាសន្នចំពោះសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ។

មាត្រា ៥៦៧. ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

១-ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៤១៧ (កម្មវត្ថុ និង វិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ) នៃក្រមនេះ ត្រូវធ្វើតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ។

២-ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្ន តុលាការដែលបានចេញជីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាកាពារ ។

៣-ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៤២០ (ការផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូស

ជាអាទិ៍) វាក្យខណ្ឌទី ១ កថាខណ្ឌទី ៣ នៃមាត្រា ៤២១ (អានុភាពនៃការរឹបអូស) កថាខណ្ឌទី ១ នៃមាត្រា ៤២៤ (ជីកាសម្រេចចាប់ផ្តើមត្រួតគ្នា) មាត្រា ៤២៥ (ជីកាសម្រេចចាប់ផ្តើមត្រួតគ្នា នៃការអនុវត្តសិទ្ធិប្រាតិភោគ និង ការអនុវត្តចំពោះអចលនវត្ថុ) មាត្រា ៤២៧ (ការលុបចោលនីតិវិធីនៃការលក់ដោយបង្ខំដោយសារការចាត់បង់ ជាអាទិ៍ នៃអចលនវត្ថុ) និង មាត្រា ៤២៨ (ការផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូស) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ។

មាត្រា ៥៦៨.- ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះនាវា

១-ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះនាវា ត្រូវធ្វើតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ឬ តាមរបៀបដែលបង្គាប់ឱ្យអាជ្ញាសាលាដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ហើយផ្តល់លិខិតនោះទៅ តុលាការអនុវត្តរក្សាការពារ ។ របៀបទាំងនេះ អាចអនុវត្តរួមគ្នាបាន ។

២-ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្នតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន តុលាការដែលបានចេញជីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ រីឯការអនុវត្តរឹបអូសជាបណ្តោះអាសន្នតាមរបៀបដែលបង្គាប់ឱ្យដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនាវានោះស្ថិតនៅ ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ ។

៣-ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ៤៥៥ (ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះនាវា និង របៀបអនុវត្ត) មាត្រា ៤៦៥ (ការលុបចោលនីតិវិធីលក់ដោយបង្ខំ ដោយការវិនាសចាត់បង់នាវា ជាអាទិ៍) និង មាត្រា ៤៦៦ (ការផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូស) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្នតាមរបៀបចុះបញ្ជី ហើយបញ្ញត្តិនៃកថាខណ្ឌទី ៣ នៃមាត្រា ៤៥៥ (ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះនាវា និង របៀបអនុវត្ត) កថាខណ្ឌទី ៧ នៃមាត្រា ៤៥៧ (ជីកាសម្រេចចាប់ផ្តើម ជាអាទិ៍) មាត្រា ៤៦០ (ការជ្រើសតាំងអ្នកថែរក្សាគ្រប់គ្រង ជាអាទិ៍) និង

មាត្រា ៤៦២ (ការអនុញ្ញាតឱ្យនាវាធ្វើដំណើរ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តវិបអូសជាបណ្តោះអាសន្ន តាមរបៀបដែលបង្គាប់ឱ្យដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ។

មាត្រា ៥៦៩.- ការលុបចោលការអនុវត្តវិបអូសជាបណ្តោះអាសន្ន ដោយផ្ទៀប្រាក់រំដោះពីការវិបអូសជាបណ្តោះអាសន្ន

១-បើកូនបំណុលបានផ្ទៀប្រាក់ស្មើនឹងចំនួនប្រាក់ដែលបានកំណត់តាមបញ្ញត្តិនៃមាត្រា ៥៤៧ (ប្រាក់រំដោះពីការវិបអូសជាបណ្តោះអាសន្ន) នៃក្រមនេះ នៅតុលាការ តុលាការអនុវត្តរក្សាការពារ ឬ សាលាជំបួងដែលអាជ្ញាសាលាស្ថិតនៅ ត្រូវលុបចោលនូវការអនុវត្តវិបអូសជាបណ្តោះអាសន្ន ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៣៨៥ (បណ្តឹងជំទាស់ចំពោះដីកាសម្រេចលុបចោល ជាអាទិ៍) នៃក្រមនេះ ដែលត្រូវយកអនុវត្តដូចគ្នា នៅក្នុងមាត្រា ៥៦៤ (ការអនុវត្តដូចគ្នា តាមបញ្ញត្តិនៃគន្លឹទី ៦) ក៏ដោយ ក៏ដីកាសម្រេចដែលធ្វើឡើង តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មានអានុភាពភ្លាមៗដែរ ។

មាត្រា ៥៧០.- ការអនុវត្តចាត់ចែងជាបណ្តោះអាសន្ន

ការអនុវត្តចាត់ចែងជាបណ្តោះអាសន្ន ត្រូវអនុវត្តតាមវិធីដូចគ្នានឹងវិធីអនុវត្តវិបអូសជាបណ្តោះអាសន្ន ឬវិធីអនុវត្តដោយបង្ខំ ។

មាត្រា ៥៧១.- អានុភាពនៃការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់

១-បើដីកាសម្រេចដែលហាមឃាត់មិនឱ្យកូនបំណុលផ្ទេរការកាប់កាប់វត្ថុ និង បង្គាប់ឱ្យកូនបំណុលប្រគល់វត្ថុទៅអាជ្ញាសាលា ដោយដកហូតការកាន់កាប់នោះ ហើយបង្គាប់ឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុនោះ ដើម្បីរក្សាការពារសិទ្ធិទាមទារឱ្យប្រគល់វត្ថុនោះ ត្រូវបានចេញ អាជ្ញាសាលាត្រូវប្រកាសជាសាធារណៈថា កូនបំណុលត្រូវបានហាមឃាត់ការផ្ទេរការកាប់កាប់វត្ថុនោះ ហើយអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុនោះ ដោយបិទលិខិតប្រកាសជាសាធារណៈ តាមរបៀបដែលពុំងាយបកចេញ ឬតាមរបៀបសមរម្យផ្សេងទៀត ។

២-បើការចាត់ចែងជាបណ្តោះអាសន្នដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានអនុវត្ត ម្ចាស់បំណុលអាចធ្វើការអនុវត្តដោយបង្ខំឱ្យប្រគល់វត្ថុបាន ដោយផ្អែកលើលិខិតអនុវត្តនៃអង្គសេចក្តី។ ប៉ុន្តែ ម្ចាស់បំណុលអាចអនុវត្តបានតែចំពោះជនដែលកាន់កាប់វត្ថុនោះ ដោយដឹងថា ការអនុវត្តការចាត់ចែងជាបណ្តោះអាសន្ននោះត្រូវបានធ្វើហើយ។

៣-ជនដែលកាន់កាប់វត្ថុដែលពាក់ព័ន្ធក្រោយពេលការអនុវត្តចាត់ចែងជាបណ្តោះ-អាសន្ន ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានសន្មតថា កាន់កាប់វត្ថុនោះ ដោយដឹងថា ការអនុវត្តចាត់ចែងជាបណ្តោះអាសន្ននោះ ត្រូវបានធ្វើហើយ។

ឧបសម្ព័ន្ធទី៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ :..0.6.2.តស.ប្រក.19

ប្រកាស

ស្តីពី

បែបបទសម្រាប់អនុវត្តការងាររបស់មន្ត្រីអាជ្ញាសាលា នៃក្រសួងយុត្តិធម៌

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/0918/803 ចុះថ្ងៃទី06 ខែកញ្ញា ឆ្នាំ2018 ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/0618/012 ចុះថ្ងៃទី28 ខែមិថុនា ឆ្នាំ2018 ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/0706/021 ចុះថ្ងៃទី06 ខែកក្កដា ឆ្នាំ2007 ដែលប្រកាសឱ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/0807/024 ចុះថ្ងៃទី10 ខែសីហា ឆ្នាំ2007 ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/0196/04 ចុះថ្ងៃទី24 ខែមករា ឆ្នាំ1996 ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ2014 ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញប្រកាសលេខ ៣០ កយប្រក ០៧ ចុះថ្ងៃទី19 ខែកក្កដា ឆ្នាំ2007 របស់ក្រសួងយុត្តិធម៌ ស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា
- បានឃើញប្រកាសលេខ 093 កយប្រក/18 ចុះថ្ងៃទី10 ខែមេសា ឆ្នាំ2018 របស់ក្រសួងយុត្តិធម៌ ស្តីពីការកែសម្រួល និងផ្ទេរភារកិច្ចមន្ត្រីអាជ្ញាសាលាក្នុងក្របខណ្ឌក្រសួងយុត្តិធម៌
- យោងតាមតម្រូវការចាំបាច់ក្នុងការអនុវត្តការងាររបស់មន្ត្រីអាជ្ញាសាលា នៃក្រសួងយុត្តិធម៌

សម្រេច

ប្រការ1.

1.1.មន្ត្រីអាជ្ញាសាលា ត្រូវទទួលបន្ទុកអនុវត្តកិច្ចការអាជ្ញាសាលានៅក្នុងដែនសមត្ថកិច្ច នៃសាលាដំបូងដែលខ្លួនប្រចាំការ។

១.២.សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ត្រូវប្រគល់កិច្ចការទាំងឡាយណាដែលជាសមត្ថកិច្ចរបស់អាជ្ញាសាលា ជូនទៅមន្ត្រីអាជ្ញាសាលា ដែលកំពុងប្រចាំការនៅទីនោះ ដើម្បីអនុវត្តការងារតាមច្បាប់ជាធរមាន លើកលែងតែ សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ដែលមិនទាន់មានមន្ត្រីអាជ្ញាសាលាប្រចាំការ ត្រូវបន្តអនុវត្តតាមប្រកាសលេខ ៣០ កយប្រក ០៧ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧ របស់ក្រសួងយុត្តិធម៌ស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា។

ប្រការ២.

២.១. សាលាដំបូងរាជធានី-ខេត្ត មានការកិច្ចជួយសម្របសម្រួលនូវរាល់កិច្ចការរដ្ឋបាលរបស់មន្ត្រីអាជ្ញាសាលា ដោយត្រូវចេញដីកាសម្រេចស្តីពីការបែងចែកសំណុំរឿង និងលេខលំដាប់សំណុំរឿង សម្រាប់ប្រគល់ជូនមន្ត្រីអាជ្ញាសាលាដែលកំពុងប្រចាំការនៅទីនោះ។

២.២.មន្ត្រីអាជ្ញាសាលាដែលប្រចាំការនៅសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត មានសិទ្ធិប្រើប្រាស់ត្រារបស់សាលាដំបូងរាជធានី-ខេត្តនោះជាបណ្តោះអាសន្ន រហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មី ឬច្បាប់ស្តីពីលក្ខន្តិកៈអាជ្ញាសាលាចូលជាធរមាន។

ប្រការ៣.

មន្ត្រីអាជ្ញាសាលាដែលប្រចាំការនៅសាលាដំបូងរាជធានី-ខេត្ត ត្រូវស្នើសុំគោលការណ៍ណែនាំជាមុនពីក្រសួងយុត្តិធម៌ រាល់ការអនុវត្តដោយបង្ខំទាំងឡាយណាដែលអាចនឹងមានការប្រឆាំង ជាហេតុបង្កអោយមានភាពចលាចល រឹកវែ ឬអសន្តិសុខដល់សង្គម និងប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈធ្ងន់ធ្ងរដែលមិនអាចគ្រប់គ្រងបាន។

ប្រការ៤.

សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ត្រូវធ្វើរបាយការណ៍ ស្តីពីកិច្ចការអាជ្ញាសាលាប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ជូនក្រសួងយុត្តិធម៌តាមកាលកំណត់។

ប្រការ៥.

ឧទ្ធកាល័យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋានកិច្ចការតុលាការ គ្រប់អគ្គនាយកដ្ឋាន គ្រប់អង្គភាពចំណុះក្រសួងយុត្តិធម៌ សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ១០រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០១៨

រដ្ឋមន្ត្រី

អង្គ វច្ឆ វឌ្ឍានា

កន្លែងទទួល៖
-ទីស្តីការគណៈរដ្ឋមន្ត្រី
-តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល
-សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍
-គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
« ដើម្បីជូនជ្រាប »
-ដូចប្រការ៥
« ដើម្បីអនុវត្ត »
-ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី១០